# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ


០៣-៤-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៤១៤/៤១៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ លោកជំទាវ អស់លោក លោកស្រី និងកញ្ញា ចំនួន ២៩ រូប ៣៨៩៤

០៣-៤-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៤១៤/៤១៥ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ទោ ជូនលោកឧត្តមសេនីយ៍ត្រី **សូ ម៉ាន់នី** នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៣៨៩៥

០៣-៤-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៤១៤/៤១៦ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ទោ ជូនលោកឧត្តមសេនីយ៍ត្រី **ឃុត សារតន** នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៣៨៩៦

០៣-៤-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៤១៤/៤១៧ ស្តីពី ការផ្តល់សញ្ជាតិខ្មែរតាមសញ្ញាតូបនីយកម្មដល់លោក **ប្រាឆា ម៉ាលីណុន** (PRACHA MALEENONT) ជនជាតិថៃ សញ្ជាតិថៃ កើតនៅទីក្រុងបាងកកព្រះរាជាណាចក្រថៃ ៣៨៩៧

០៣-៤-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៤១៤/៤១៨ ស្តីពី ការតែងតាំងឥស្សរជន ចំនួន ០២ រូប ជាទីប្រឹក្សារាជរដ្ឋាភិបាល ៣៨៩៨

០៣-៤-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៤១៤/៤១៩ ស្តីពី ការតែងតាំងឯកឧត្តម **ម៉ូ រតនា** ជាអគ្គលេខាធិការរង គណៈកម្មាធិការជាតិជម្រុញចលនាភូមិមួយ ផលិតផលមួយ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ៣៨៩៩

០៣-៤-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៤១៤/៤២០ ស្តីពី ការតែងតាំងឯកឧត្តម **សួន វ៉ាសិទ្ធ** ជាទីប្រឹក្សាក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ៣៩០០

០៣-៤-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៤១៤/៤២១ ស្តីពី ការតែងតាំងមន្ត្រីរាជការ ចំនួន ០៩ រូប នៃគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ៣៩០១

០៣-៤-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៤១៤/៤២២ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ អស់លោក និងលោកស្រី ចំនួន ៥០ រូប ៣៩០៣

០៣-៤-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៤១៤/៤២៣ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ អស់លោក និងលោកស្រី ចំនួន ៩៩ រូប ៣៩០៥

០៤-៤-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៤១៤/៤២៤ ស្ដីពី ការតម្លើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ជូនសពនាយទាហាន ថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០៨ រូប ៣៩១០

០៤-៤-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៤១៤/៤២៥ ស្ដីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ទោ នាយទាហានថ្នាក់ឧត្តមសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ចំនួន ១៣ រូប ៣៩១២

០៤-៤-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៤១៤/៤២៦ ស្ដីពី ការតម្លើងឋានន្តរស័ក្តិ ជូននាយទាហានថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ចំនួន ១១ រូប ៣៩១៤

## II. រាជរដ្ឋាភិបាល

### អនុក្រឹត្យ

១៨-៤-២០១៤ -អនុក្រឹត្យលេខ ១៦៦ អនក្រ.បក ស្ដីពី ការកាត់ដីសរុបទំហំ ៥.៦៥០,៣៣ ហិកតា នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ក្នុងនោះកាត់ចេញពីដីដែនជម្រកសត្វព្រៃគូលេនព្រហ្មទេព កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន នេតឆ័រ ផ្លេនថេសិន កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន បេស៊្វីយ៉ាល់ កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន តៃនីញ សៀមរាប អភិវឌ្ឍន៍កៅស៊ូ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ព្រមទាំងផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី ៣៩១៦

២៨-៤-២០១៤ -អនុក្រឹត្យលេខ ១៦៧ អនក្រ.បក ស្ដីពី ការកាត់ដីទំហំ ៣.១៦៣,៧០ ហិកតា នៅស្រុកកំពង់សីលា ខេត្តព្រះសីហនុ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៣៦ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ៣៩១៩

០៥-៣-២០១៤ -អនុក្រឹត្យលេខ ៣៦១ អនក្រ.តត ស្ដីពី ការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ៣៩២២

០៥-៣-២០១៤ -អនុក្រឹត្យលេខ ៣៦២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣៩២៣
០៦-៣-២០១៤ -អនុក្រឹត្យលេខ ៣៦៣ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣៩២៤
០៦-៣-២០១៤ -អនុក្រឹត្យលេខ ៣៦៤ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៣៩២៥
០៦-៣-២០១៤ -អនុក្រឹត្យលេខ ៣៦៥ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣៩២៦
០៦-៣-២០១៤ -អនុក្រឹត្យលេខ ៣៦៦ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៣៩២៩
០៦-៣-២០១៤ -អនុក្រឹត្យលេខ ៣៦៧ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣៩៣០
០៦-៣-២០១៤ -អនុក្រឹត្យលេខ ៣៦៨ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣៩៣១
០៦-៣-២០១៤ -អនុក្រឹត្យលេខ ៣៦៩ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយសសុវត្ថារា ៣៩៣៤
២៥-៣-២០១៤ -អនុក្រឹត្យលេខ ៣៧០ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៣៩៣៥
២៥-៣-២០១៤ -អនុក្រឹត្យលេខ ៣៧១ អនក្រ.តត ស្តីពី ការសម្រួលភារកិច្ច និងតែងតាំងមន្ត្រីរាជការ ៣៩៣៧
២៥-៣-២០១៤ -អនុក្រឹត្យលេខ ៣៧២ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ ៣៩៣៩
២៥-៣-២០១៤ -អនុក្រឹត្យលេខ ៣៧៣ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣៩៤១
២៥-៣-២០១៤ -អនុក្រឹត្យលេខ ៣៧៤ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៣៩៤៣
២៥-៣-២០១៤ -អនុក្រឹត្យលេខ ៣៧៥ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៣៩៤៤
២៥-៣-២០១៤ -អនុក្រឹត្យលេខ ៣៧៦ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៣៩៤៧
២៥-៣-២០១៤ -អនុក្រឹត្យលេខ ៣៧៧ អនក្រ.តត ស្តីពី ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ៣៩៥៣
២៥-៣-២០១៤ -អនុក្រឹត្យលេខ ៣៧៨ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៣៩៥៥

## III-ភាគខាងបណ្តាក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៧-៣-២០១៤ -ប្រកាសលេខ ៣២៥ សហវ.ប្រក ស្តីពី ការដាក់ឱ្យប្រើប្រាស់គំរូឯកសារដេញថ្លៃ ពិគ្រោះថ្លៃ និងស្តង់តម្លៃ សម្រាប់លទ្ធកម្មទំនិញ និងសំណង់ ៣៩៥៦

### ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម

២៨-០២-២០១៤ -ប្រកាសលេខ ០៩១ MIH/2014 ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជិនយុន ហ័រ បង្កើត រោងចក្រផលិត សម្លៀកបំពាក់ ៣៩៩៧
២៨-០២-២០១៤ -ប្រកាសលេខ ០៩២ ឧស.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ម៉ារុ-ធី អូស៊ុកា (ភ្នំពេញ) ឧបភើរេសិន បង្កើតរោងចក្រផលិត សម្ភារៈសម្រាប់លាបថ្នាំ ៤០០១

ឃ


២៨-០២-២០១៤ -ប្រកាសលេខ ០៩៣ MIH/2014 ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ភ្នំពេញ ព្រីខាស ផ្លេន បង្កើតរោងចក្រផលិត បង្គោលភ្លើង និងលូគ្រប់ប្រភេទ (ពីស៊ីម៉ង់ត៍) ៤០០៥

២៨-០២-២០១៤ -ប្រកាសលេខ ០៩៤ MIH/2014 ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស្ទេល្សិន ស៊្ទីល បង្កើតរោងចក្រផលិត បំពង់ទីបដែក ៤០០៩

១០-៣-២០១៤ -ប្រកាសលេខ ១១៩ ឧស.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន លូ ថៃ (ខេមបូឌា) បង្កើតរោងចក្រផលិត សម្លៀកបំពាក់ ៤០១៣

# ព្រះរាជក្រឹត្យ

នស/រកត/០៤១៤/៤១៤

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា )

## ប្រោសព្រះរាជទាន

**នូវ**

**ក-គ្រឿងឥស្សរិយយស ជាតូបការ**

-លោកជំទាវ ហ៊ុន ម៉ុនធឿន

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍**

| | | | | | |
|---|---|---|---|---|---|
| ១-លោក | ហ៊ាន | ស៊ាងហុង | ២-លោកស្រី | ហេង | ច័ន្ទបុប្ផា |

**គ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍**

| | | | | | |
|---|---|---|---|---|---|
| ១-លោក | ហេង | សារ៉ាត | ៦-លោក | គង់ | ជរ |
| ២-លោក | មាស | ជន្លហេង | ៧-លោក | សោម | រស្មី |
| ៣-លោក | ហេង | ម៉ុនខេង | ៨-លោកជំទាវ | ហ៊ុន | ចាន់ធី |
| ៤-លោក | សៅ | ចន្ថា | ៩-លោកស្រី | ហ៊ុន | សុភា |
| ៥-លោក | ម៉ីន | ម៉ុនធី | ១០-លោកស្រី | ហ៊ុន | ចាន់ថុន |

**ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា**

| | | | | | |
|---|---|---|---|---|---|
| ១-លោក | សួន | វណ្ណារិទ្ធ | ៦-លោក | ចេង | សុវណ្ណ |
| ២-លោក | ឃុន | ចាន់ថុល | ៧-លោក | ហ៊ុន | សុផាត |
| ៣-លោក | លុយ | កេត្តនា | ៨-លោកស្រី | ហ៊ុន | ចាន់មករា |
| ៤-លោក | ឡាយ | សុភក្រ្ត | ៩-កញ្ញា | ហ៊ុន | ចាន់បុប្ផា |
| ៥-លោក | លឹម | ជីលុច | ១០-លោក | ហ៊ុន | សុភក្រ្ត |

**ង-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា**

| | | | | | |
|---|---|---|---|---|---|
| ១-លោកស្រី | លឹម | ឆាក់ជូ | ៣-លោក | ជួង | សុវណ្ណ |
| ២-លោកស្រី | គឹម | ហ៊ួយ | | | |

**ច-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ**

| | | | | | |
|---|---|---|---|---|---|
| ១-លោក | អ៊ឹម | រចនា | ៣-លោក | ឈិត | សារុន |
| ២-កញ្ញា | សៅ | សុម៉ាលី | | | |

**ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ**
**នរោត្ដម សីហមុនី**

៣៧៧. ១៤០៤.៤២០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១៤

លេខ: ៤៤៥ ស.ណ
សំណៅដើមមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ មេសា ឆ្នាំ២០១៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
គឹម សុខា

នស/រកត/០៤១៤/៤១៥

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រតនខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ទោ** ជូនលោកឧត្តមសេនីយ៍ត្រី **សូ ច័ន្ទធី** អត្តលេខ ០២៣០៤ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣១៥.១៤០៤.៤២១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៤

លេខៈ ៤ ៥ ១ ស.ណ
**សំណៅចម្លងត្រឹមត្រូវតាមច្បាប់ដើម**
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៤១៤/៤១៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តម្លើងឋានន្តរស័ក្តិ**ឧត្តមសេនីយ៍ទោ** ជូនលោកឧត្តមសេនីយ៍ត្រី **ឃុត សារុន** អត្តលេខ ០៣២៣ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

[illegible]

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៤

[illegible] ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ស៊ុយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៤១៤/៤១៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្មដល់លោក **ប្រាឆា ម៉ាលីណុន** (PRACHA MALEENONT ) ជនជាតិ ថៃ សញ្ជាតិ ថៃ កើតថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៤៧ នៅទីក្រុងបាងកក ព្រះរាជាណាចក្រថៃ ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣០៧.១៤០៤.៤២៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៤

លេខ: [illegible] ស.ណ
**សំណៅដែលមានតម្លៃដូចការចេញផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មេសា ឆ្នាំ២០១៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៤១៤/៤១៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពុហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឥស្សរជនចំនួន ០២រូប ជាទីប្រឹក្សារាជរដ្ឋាភិបាល :

១- លោក **ឌូ សុខ** មានឋានៈស្មើ រដ្ឋលេខាធិការ

២- លោក **ម៉ុង គីមហេង** មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរកប.១៤០៤.៤២៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ២០១៤

លេខ: ៤៤៩ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៤១៤/៤១៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៩/៨៧៦ ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១០៦/០៤៣ ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិជម្រុញ" ភូមិមួយផលិតផលមួយ"
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/១០៥៩ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការផ្ទេរគណៈកម្មាធិការជាតិជម្រុញចលនា" ភូមិមួយផលិតផលមួយ" ឱ្យស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម ម៉ូ រតនា ជាអគ្គលេខាធិការរង គណៈកម្មាធិការជាតិជម្រុញចលនាភូមិមួយផលិតផលមួយ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧៣.១៤០៤.៤២៥

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៤

លេខ: ៤១៥ ស.ណ
សំណៅដែលបានចម្លងត្រឹមត្រូវសម្រាប់ការចែកផ្សាយ
រាជធានីភ្នំពេញ ... ឆ្នាំ២០១៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៤១៤/៤២០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៩/៨៣៦ ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម **សុន រ៉ាសិទ្ធ** ជាទីប្រឹក្សាក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរស.១៤០៤.៤២៦

លេខៈ ៥៥៧ ស.ណ
**សំណៅចម្លងមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ២០១៤

**ស៊ិយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៤១៤/៤៤១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៥/៣៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ទៅជា គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០០៨/១១៣០ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលសមាសភាពថ្នាក់ដឹកនាំគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១១/៣៤០ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១១ ស្តីពីការកែសម្រួលមុខតំណែង សមាសភាពថ្នាក់ដឹកនាំនៃគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងមន្ត្រីរាជការ ចំនួន ០៥រូប នៃគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ :

១- ឯកឧត្តម **សាំង រតនា** ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

២- ឯកឧត្តម **ពុំ ប៊ុនច័ន្ទរ័ត្ន** ជាទីប្រឹក្សាអមគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

៣- ឯកឧត្តម **ហាឡូ សុខណ្ណ** ជាទីប្រឹក្សាអមគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

៤- លោកជំទាវ **សម នីថាវី** ជាទីប្រឹក្សាអមគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

៥- លោកជំទាវ **ទិន ម៉ាលីន** ជាទីប្រឹក្សាអមគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

៦-ឯកឧត្តម **អាំ ឆន** ជាជំនួយការគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ មានឋានៈស្មើ **អគ្គនាយក** ។

៧-ឯកឧត្តម **រាត់ គីមស៊្រឿន** ជាជំនួយការគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ មានឋានៈស្មើ **អគ្គនាយក** ។

៨-ឯកឧត្តម **អ៊ុត តាំត្រា** ជាជំនួយការគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន ។

៩-ឯកឧត្តម **អ៊ុម ខេមគោ** ជាជំនួយការគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្ត ឱ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកត.០៤១៤.៤២៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៤

លេខៈ ៤៥៤ ស.ណ

**សំណៅចម្លងចេញពីច្បាប់ដើម សម្រាប់ការចែកផ្សាយ**

រាជធានីភ្នំពេញ ,ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៤/៤២៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា )

**ទ្រង់ប្រោសប្រទាន**

**នូវ**

ក- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១-លោក **ភូ លិ**
២-លោក **ភូ សុផល**
៣-លោក **ស៊ីវ ឈាន់**
៤-លោក **ឡឹក វណ្ណះ**

ខ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** :

១-លោក **សុខ ហ៊ី**
២-លោក **ឡេង សុផាន**
៣-លោក **ខៀវ សុខ**
៤-លោក **អ៊ុម ពុធទិរា**
៥-លោក **អ៊ី វិជ្ជា**
៦-លោក **ស្វរ ឫទ្ធី**
៧-លោក **ឡេង សុភាព**
៨-លោក **ម៉ៅ សុវណ្ណារិទ្ធ**
៩-លោក **ពាន់ មីសស្សែល**
១០-លោក **ឃុន មណ្ឌល**
១១-លោកស្រី **វីរក្ស វិជ្ជនី**
១២-លោក **ច័ន្ទ វិទ្ធី**
១៣-លោក **សុខ ថា**
១៤-លោក **សោម សាមុត**
១៥-លោក **ស៊ាង សាមាន**
១៦-លោក **លឹម សុខា**
១៧-លោក **នួន ភារិទ្ធិ**
១៨-លោក **ស៊ិន វាសនា**
១៩-លោក **សុខ សុគន្ធា**

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

គ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** :

១-លោក **ភូ សុផល**
២-លោក **ផា សុផាត**
៣-លោក **ម៉ន មូលីសុវណ្ណា**
៤-លោក **សោម ដាវិន**
៥-លោកស្រី **វិន ម៉ារីណា**
៦-លោក **គង់ ណាខ្សៀន**
៧-លោក **ឌួន សារិន**
៨-លោក **សុខ វិសិទ្ធ**
៩-លោក **សែម វិតឹក**
១០-លោក **សែម ថេន**
១១-លោក **ពុធ ធារ៉ា**
១២-លោក **ខៀន ចាន់សុភក្រ្ត**
១៣-លោក **អ៊ិន សារិទ្ធ**
១៤-កញ្ញា **វីរក្ស វិជ្ជតា**
១៥-លោក **វីរក្ស បរិញ្ញាពេជ្រ**

ឃ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** :

១-កញ្ញា **មាស ផល្លី**
២-លោក **ឆាយ វណ្ណារី**
៣-លោកស្រី **សៀ ធវិន្ត**
៤-លោក **ឌី រ៉ាឌូ**

ង- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** :

១-លោក **កៃ កុសល**
២-លោក **ស៊ិន មុន្នី**
៣-លោក **ឈុន លី**
៤-លោក **ឆាយ សំបូរ**
៥-លោក **ថុក យ៉ារ៉ាក់**
៦-លោក **ណុប រដ្ឋា**
៧-លោក **គិន ភុណា**
៨-លោក **ក្លូ សុវណ្ណី**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចារ. ១៤០៤.៤២៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១៤

លេខៈ ៤៤១ ស.ណ
**សំណៅចម្លងចេញពីច្បាប់ដើម សម្រាប់ផ្សព្វផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ [illegible] ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៨/៤២៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា )

## ប្រោសព្រះរាជទាន

នូវ

### ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍

| | | | | | |
|---|---|---|---|---|---|
| ១- | វរសេនីយ៍ឯក | គុណា | សាឡឿន | អត្តលេខ | ០០៣០[illegible] |
| ២- | វរសេនីយ៍ឯក | អួន | លុច | អត្តលេខ | ០១២៨[illegible] |
| ៣- | វរសេនីយ៍ឯក | ស៊ុន | លីមហេង | អត្តលេខ | ០៣៩២[illegible] |
| ៤- | វរសេនីយ៍ទោ | សម | ប្រាជ្ញា | អត្តលេខ | ០០៣០៨៨ |
| ៥- | វរសេនីយ៍ទោ | អ៊ូ | គីមឈុន | អត្តលេខ | ០០៥២៥៩ |
| ៦- | វរសេនីយ៍ទោ | ស៊ិន | ម៉ិច | អត្តលេខ | ០០១២៦៣ |
| ៧- | វរសេនីយ៍ត្រី | សុខ | រស្មី | អត្តលេខ | ០៣០៣៦៩ |
| ៨- | វរសេនីយ៍ត្រី | ឡេង | សាម៉ន | អត្តលេខ | ០០២៩៥៨ |

### ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍

| | | | | | |
|---|---|---|---|---|---|
| ១- | ឧត្តមសេនីយ៍ទោ | ឈាង | ប៊ុនធី | អត្តលេខ | ០០០៩៥២ |
| ២- | លោកស្រី | ស៊ុ | កាន់យ៉ា | | |
| ៣- | លោក | ឃឹន | ម៉េង | | |
| ៤- | លោក | ឃិន | ម៉ាក់ | | |

### គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា

| | | | | | |
|---|---|---|---|---|---|
| ១- | វរសេនីយ៍ទោ | ម៉ែន | សាលី | អត្តលេខ | ០១០៧[illegible] |
| ២- | វរសេនីយ៍ទោ | គឹម | ឃឹម | អត្តលេខ | ០០៣[illegible] |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

| | | | | | |
|---|---|---|---|---|---|
| ៣- | វរសេនីយ៍ទោ | យុទ្ធ | សានី | អត្តលេខ | ០០៣០៧០ |
| ៤- | វរសេនីយ៍ទោ | នួច | សារិទ្ធ | អត្តលេខ | ០១៥៨៩៥ |
| ៥- | វរសេនីយ៍ទោ | សាំង | លឹមហេង | អត្តលេខ | ០១៥៩៣៥ |
| ៦- | វរសេនីយ៍ត្រី | ជ័យ | ឧទ្ធី | អត្តលេខ | ០១០៧០៤ |
| ៧- | វរសេនីយ៍ត្រី | គុជ | ប៊ុនឆាំ | អត្តលេខ | ០១១៨៧២ |
| ៨- | វរសេនីយ៍ត្រី | ខ៉ែត | សារឿន | អត្តលេខ | ០១១៩០២ |
| ៩- | វរសេនីយ៍ត្រី | លី | សេង | អត្តលេខ | ០៣៧១១៨ |
| ១០- | វរសេនីយ៍ត្រី | ដួង | យ៉ាន់ | អត្តលេខ | ០០៣៧១៩ |
| ១១- | វរសេនីយ៍ត្រី | មាឃ | សារឹម | អត្តលេខ | ០១៥៩២០ |
| ១២- | វរសេនីយ៍ត្រី | ទ៉េត | ទ៉ាត់ | អត្តលេខ | ០១៦៤១៣ |
| ១៣- | វរសេនីយ៍ត្រី | ឆន | ឌីម៉ា | អត្តលេខ | ០១០៦៩៨ |
| ១៤- | វរសេនីយ៍ត្រី | ឃុត | ឃីម | អត្តលេខ | ០១៥៩៥៨ |
| ១៥- | វរសេនីយ៍ត្រី | ព្រៃ | សាវ៉ុន | អត្តលេខ | ០១១៨២៥ |
| ១៦- | វរសេនីយ៍ត្រី | សុខ | សុភ័ក្រ | អត្តលេខ | ៥៤០៩១ |
| ១៧- | វរសេនីយ៍ត្រី | ឈឹម | គឹមហួង | អត្តលេខ | ១៥៩៦១ |
| ១៨- | លោក | ឆ្វ | ចាន់ដារ៉ា | | |
| ១៩- | លោក | ស្រុយ | ម៉ៅ | | |

**ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ**

| | | | | | |
|---|---|---|---|---|---|
| ១- | វរសេនីយ៍ត្រី | ឆាយ | ប៊ុនសេង | អត្តលេខ | ០៣២៦៩៧ |
| ២- | វរសេនីយ៍ត្រី | ប៉ាន់ | ឌិត | អត្តលេខ | ០៣២៨៥២ |
| ៣- | វរសេនីយ៍ត្រី | កែវ | ធឿន | អត្តលេខ | ០១១៨៨២ |
| ៤- | វរសេនីយ៍ត្រី | ប្រាក់ | សាវ៉ន | អត្តលេខ | ០៤៤០៨៤ |
| ៥- | វរសេនីយ៍ត្រី | ស៊ិន | សៀងម៉ាន់ | អត្តលេខ | ០១១៨៥៥ |
| ៦- | វរសេនីយ៍ត្រី | ឱះ | ចន | អត្តលេខ | ០២១២៩៥ |
| ៧- | វរសេនីយ៍ត្រី | ជា | រឿង | អត្តលេខ | ០២១៤៣៨ |
| ៨- | វរសេនីយ៍ត្រី | ហេង | សឿន | អត្តលេខ | ០១៥៩០៣ |
| ៩- | វរសេនីយ៍ត្រី | នោម | វណ្ណារិទ្ធ | អត្តលេខ | ០១៥៩៧២ |
| ១០- | វរសេនីយ៍ត្រី | យ៉ម | ហាក់ | អត្តលេខ | ០៤៤១១៨ |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

| | | | | | |
|---|---|---|---|---|---|
| ១១- | វរសេនីយ៍ត្រី | ម៉ៅ | សុខុន | អត្តលេខ | ០១៥៨៩១ |
| ១២- | វរសេនីយ៍ត្រី | ឳក | សំអូន | អត្តលេខ | ០១៥៩០២ |
| ១៣- | វរសេនីយ៍ត្រី | កែវ | គឹមហោន | អត្តលេខ | ០១៥៩១០ |
| ១៤- | វរសេនីយ៍ត្រី | ហាច្យ | យឿន | អត្តលេខ | ០០៣៧២៥ |
| ១៥- | វរសេនីយ៍ត្រី | ទន់ | សុខ | អត្តលេខ | ០១១៦៩១ |
| ១៦- | វរសេនីយ៍ត្រី | សេង | សារី | អត្តលេខ | ០១១៨៣៦ |
| ១៧- | វរសេនីយ៍ត្រី | ម៉ែន | សារ៉ាល់ | អត្តលេខ | ១៣៧២២៣ |
| ១៨- | វរសេនីយ៍ត្រី | កែវ | ធី | អត្តលេខ | ០០៣៦៩៩ |
| ១៩- | អនុសេនីយ៍ឯក | ខាត់ | សុជាតិ | អត្តលេខ | ០៣២៨០៧ |
| ២០- | អនុសេនីយ៍ឯក | សែម | សុគុណ្ណា | អត្តលេខ | ០៣០៤១២ |
| ២១- | អនុសេនីយ៍ឯក | សែម | សារ៉េត | អត្តលេខ | ០៣២៧៤៤ |
| ២២- | អនុសេនីយ៍ឯក | ចាន់ | ស៊ឿន | អត្តលេខ | ០៣២៧៤៨ |
| ២៣- | អនុសេនីយ៍ឯក | ស្អួន | សុខហ៊ន | អត្តលេខ | ២១៥៥៣៩ |
| ២៤- | អនុសេនីយ៍ឯក | ឡាយ | សៅ | អត្តលេខ | ០២១៣១៧ |

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា

| | | | | | |
|---|---|---|---|---|---|
| ១- | វរសេនីយ៍ត្រី | គឹម | ទេង | អត្តលេខ | ០១៣១៦៦ |
| ២- | វរសេនីយ៍ត្រី | ញឹក | លីន | អត្តលេខ | ០៣២៨៥២ |
| ៣- | វរសេនីយ៍ត្រី | ស្អួស | ទឿន | អត្តលេខ | ០១១៨៧៤ |
| ៤- | វរសេនីយ៍ត្រី | ទេព | វិសាល | អត្តលេខ | ០៧៣៥៣៣ |
| ៥- | អនុសេនីយ៍ឯក | រិន | ឆេន | អត្តលេខ | ០១៦៥៧០ |
| ៦- | អនុសេនីយ៍ឯក | ជួន | ចេក | អត្តលេខ | ០៣២៨០៨ |
| ៧- | អនុសេនីយ៍ឯក | ញឹម | ពៅ | អត្តលេខ | ០៣០៣៩៨ |
| ៨- | អនុសេនីយ៍ឯក | ខេង | ឡុច | អត្តលេខ | ០១៥៩១៩ |
| ៩- | អនុសេនីយ៍ឯក | សាមុត | សារុន | អត្តលេខ | ០៨៣៣៤៩ |
| ១០- | អនុសេនីយ៍ឯក | ម៉ី | សុមន្តា | អត្តលេខ | ០៣០៣៦០ |
| ១១- | អនុសេនីយ៍ឯក | ជា | តួចម៉ុងឡេង | អត្តលេខ | ០៥៣៩៣១ |
| ១២- | អនុសេនីយ៍ឯក | ទេព | វណ្ណា | អត្តលេខ | ០៣២៨៥៦ |

**ច-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ**

| | | | | | |
|---|---|---|---|---|---|
| ១- | វរសេនីយ៍ទោ | យ៉ែម | ចាន់ធឿន | អត្តលេខ | ០៤៧០៨៦ |
| ២- | វរសេនីយ៍ត្រី | ចេង | សេងហាក់ | អត្តលេខ | ០១១៨៨៨ |
| ៣- | វរសេនីយ៍ត្រី | កែវ | គះទីន | អត្តលេខ | ០១១៨៣៧ |
| ៤- | វរសេនីយ៍ត្រី | គាន | រី | អត្តលេខ | ១៩៨២៨៥ |
| ៥- | វរសេនីយ៍ត្រី | ជា | ហាំងទី | អត្តលេខ | ២២៧៩៩៨ |
| ៦- | អនុសេនីយ៍ឯក | ស្នួរ | ស | អត្តលេខ | ០១៥៩៦១ |
| ៧- | អនុសេនីយ៍ឯក | សារ៉ែត | ទិសេដ្ឋ | អត្តលេខ | ១០១៦១ |
| ៨- | អនុសេនីយ៍ឯក | អ៊ុក | គក់ | អត្តលេខ | ០១៥៩១៤ |
| ៩- | អនុសេនីយ៍ឯក | ចេស | ចិន្តា | អត្តលេខ | ០៤៣៩៩៣ |
| ១០- | អនុសេនីយ៍ឯក | នី | ធឿន | អត្តលេខ | ០២១៣៤៣ |
| ១១- | អនុសេនីយ៍ឯក | ប្រាំង | ផា | អត្តលេខ | ០២១៣៤០ |
| ១២- | អនុសេនីយ៍ឯក | ផាន់ | សារុន | អត្តលេខ | ១០៨០៨៧ |
| ១៣- | អនុសេនីយ៍ឯក | កែ | ប្រាសាទ | អត្តលេខ | ០៥២៨៩៧ |
| ១៤- | អនុសេនីយ៍ឯក | ហូ | ហាង | អត្តលេខ | ០៨៣៣៦៦ |
| ១៥- | អនុសេនីយ៍ឯក | ឡេង | ម៉ុនលីម | អត្តលេខ | ១៣៤៣១៣ |
| ១៦- | អនុសេនីយ៍ទោ | ហាម | រ៉ា | អត្តលេខ | ០៣៧៤៦៣ |
| ១៧- | អនុសេនីយ៍ទោ | គង់ | ម៉ុនលៀង | អត្តលេខ | ០៤២១២២ |
| ១៨- | អនុសេនីយ៍ទោ | លឹម | តាច | អត្តលេខ | ០២១៣៣៦ |
| ១៩- | អនុសេនីយ៍ទោ | ជឹម | សុខា | អត្តលេខ | ០៧៥១៤៧ |
| ២០- | អនុសេនីយ៍ទោ | ចាន់ | ថា | អត្តលេខ | ០៨៣០៧៦ |
| ២១- | អនុសេនីយ៍ទោ | អ៊ឹម | សម្បត្តិ | អត្តលេខ | ០៤២១៦៨ |
| ២២- | អនុសេនីយ៍ទោ | អឿង | សុខ | អត្តលេខ | ១៣១៤៨៤ |
| ២៣- | អនុសេនីយ៍ឯក | ទឹម | អេងហុក | អត្តលេខ | ០៣០៣៤១ |
| ២៤- | អនុសេនីយ៍ត្រី | ឡាំ | ញឹក | អត្តលេខ | ០៥២៧៧៥ |
| ២៥- | អនុសេនីយ៍ត្រី | កែង | លីនេង | អត្តលេខ | ០៤៤១២០ |
| ២៦- | អនុសេនីយ៍ត្រី | ហេង | អ៊ារី | អត្តលេខ | ០៨៣០៧៧ |
| ២៧- | អនុសេនីយ៍ត្រី | ចាន់ | រី | អត្តលេខ | ០៥៤៣៨២ |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

| | | | | | |
|---|---|---|---|---|---|
| ២៨- | អនុសេនីយ៍ត្រី | កែវ | តុត | អត្តលេខ | ០៥៤៣៧៣ |
| ២៩- | អនុសេនីយ៍ត្រី | សាម | មិន | អត្តលេខ | ០៥៣៨៣១ |
| ៣០- | អនុសេនីយ៍ត្រី | ម៉ូ | ថន | អត្តលេខ | ១៣១៤៤១ |
| ៣១- | អនុសេនីយ៍ត្រី | ឡូន | ឆុន្នី | អត្តលេខ | ០៥២៨៣៦ |
| ៣២- | នាយចំណង់ | ចេង | ពីន | អត្តលេខ | ១៣១៤៧៤ |

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧.១៤០៤.៤២៥

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៤

លេខ: ៤៤០ ស.ណ

សំណៅចម្លងដែលមានឥទ្ធិពលជាការចែកផ្សាយ

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ [illegible] ឆ្នាំ២០១៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៤/៤២៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តម្លើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ជូនសព នាយទាហាន ថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ៖

**ក-ឋានន្តរស័ក្តិឧត្តមសេនីយ៍ឯក**

- ឧត្តមសេនីយ៍ទោ **ម៉ែន សុខុម** អត្តលេខ ០០២១៨៣

**ខ-ឋានន្តរស័ក្តិឧត្តមសេនីយ៍ទោ**

- ឧត្តមសេនីយ៍ត្រី **សំរិទ្ធ សិលា** អត្តលេខ ០០០៥០០

**គ-ឋានន្តរស័ក្តិឧត្តមសេនីយ៍ត្រី**

១-វរសេនីយ៍ឯក **ប៉ោ សារី** អត្តលេខ ០១៨៩៧៥
២-វរសេនីយ៍ឯក **ហៃ ទិដ្ឋា** អត្តលេខ ០០២៧១៧
៣-វរសេនីយ៍ឯក **ម៉ុក សាលី** អត្តលេខ ០០២២២៣
៤-វរសេនីយ៍ឯក **ណុប បូណារ** អត្តលេខ ០០៨៥១៤
៥-វរសេនីយ៍ឯក **សុខ សុមិន្ត** អត្តលេខ ០១១០៩៧

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**ឃ-ឋានន្តរស័ក្តិឧត្តមនាវីត្រី**

- វរនាវីឯក **ញ៉ាត់ តារាម្សៀ** អត្តលេខ ០២៩៣៩៦

**មាត្រា២:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស.រកត.០៤១៤.៤៣០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០១៤

លេខ: ៤៥៩ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៤/៤២៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ទោ** នាយទាហានថ្នាក់ឧត្តមសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ៖

| | | | |
|---|---|---|---|
| ១-ឧត្តមសេនីយ៍ត្រី | **មាស** | **សុគន្ធ** | អត្តលេខ ០០៣២៦៥ |
| ២-ឧត្តមសេនីយ៍ត្រី | **ហេង** | **សុផល** | អត្តលេខ ០០១៧២៦ |
| ៣-ឧត្តមសេនីយ៍ត្រី | **សុខ** | **ខួន** | អត្តលេខ ០១៧៥៦៩ |
| ៤-ឧត្តមសេនីយ៍ត្រី | **ជ្រឹង** | **សុផល** | អត្តលេខ ០០១៨៣៤ |
| ៥-ឧត្តមសេនីយ៍ត្រី | **ឡាង** | **នឹន** | អត្តលេខ ០០១៦៤២ |
| ៦-ឧត្តមសេនីយ៍ត្រី | **ចាន់** | **សារឿន** | អត្តលេខ ០០១៤៨០ |
| ៧-ឧត្តមសេនីយ៍ត្រី | **កែម** | **សម្បត្តិ** | អត្តលេខ ០០១៨៣៥ |
| ៨-ឧត្តមសេនីយ៍ត្រី | **អៀម** | **ហេង** | អត្តលេខ ០០១៥៤៥ |
| ៩-ឧត្តមសេនីយ៍ត្រី | **គង់** | **សំណាង** | អត្តលេខ ០០២៨៣៧ |
| ១០-ឧត្តមសេនីយ៍ត្រី | **យឹម** | **រតនា** | អត្តលេខ ០១៣៨០៥ |
| ១១-ឧត្តមសេនីយ៍ត្រី | **រស់** | **ចន្ធា** | អត្តលេខ ០០១៣៨៩ |
| ១២-ឧត្តមសេនីយ៍ត្រី | **ម៉ុច** | **រដ្ឋិរក្ស** | អត្តលេខ ០១៣៧៩៣ |

១៣-ឧត្តមសេនីយ៍ត្រី **ប្រាក់ ស៊ីដារ៉ាឌុង** អត្តលេខ ០០១៦៥១

**មាត្រា២:** សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

**នរោត្ដម សីហមុនី**

៣៣៥ ១៤០៤.៤៣១

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤

លេខ: ៥៧១ ស.ណ

**សំណៅចម្លងមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៤/៤២៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តម្លើងឋានន្តរស័ក្តិ ជូន នាយទាហាន ថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពល ខេមរភូមិន្ទ ៖

**ក-ឋានន្តរស័ក្តិឧត្តមសេនីយ៍ទោ**

| | | | |
|---|---|---|---|
| ១-ឧត្តមសេនីយ៍ត្រី | ទៀ | នីហា | អត្តលេខ ០១៩៨៦៤ |
| ២-ឧត្តមសេនីយ៍ត្រី | រ៉ែន | ផល្លា | អត្តលេខ ០០១៩៣៨ |
| ៣-ឧត្តមសេនីយ៍ត្រី | កែវ | ចាន់តារា | អត្តលេខ ០០៨៣៧០ |

**ខ-ឋានន្តរស័ក្តិឧត្តមសេនីយ៍ត្រី**

| | | | |
|---|---|---|---|
| ១-វរសេនីយ៍ឯក | ជា | ច័ន្ទត្រីស្នា | អត្តលេខ ០២៥៧០៤ |
| ២-វរសេនីយ៍ឯក | ដួង | តារា | អត្តលេខ ០០១៣៤៤ |
| ៣-វរសេនីយ៍ឯក | អ៊ឹង | ជុន | អត្តលេខ ០២៣៨១៣ |
| ៤-វរសេនីយ៍ឯក | ផូង | គឹមវណ្ណៈ | អត្តលេខ ០០២១៨៥ |
| ៥-វរសេនីយ៍ឯក | កែវ | គឹមសាន | អត្តលេខ ០៤២៩៨៤ |
| ៦-វរសេនីយ៍ឯក | ញាណ | ម៉ន | អត្តលេខ ០០៤២៥៦ |
| ៧-វរសេនីយ៍ឯក | សាត | សុចត្ថិឌី | អត្តលេខ ០០១៤៣៦ |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៨-វរសេនីយ៍ឯក **ចៅ** **សុរិការ** អត្តលេខ ០០១១៦៥

**មាត្រា២**: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរ.១៤០៤.៤៣២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០១៤

លេខ: ៤៧០ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែមេសា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៦៤ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការកាត់ដីសរុបទំហំ ៥.៦៥០,៣៣ ហិកតា នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្ដរមានជ័យ ក្នុងនោះ កាត់ចេញពីដីដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន នេគង់ ផ្លេនថេសិន កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន បេសរ៉ូយ៉ាល់ កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ ក្រុមហ៊ុន តៃនីញ សៀមរាប អភិវឌ្ឍន៍កៅស៊ូ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ព្រមទាំងផ្ដល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៤/៤៧៧ ចុះថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ២០១៤
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ០៨៨ លស/ឧជ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៤ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១**: ត្រូវបានកាត់ដីសរុបទំហំ ៥.៦៥០,៣៣ ហិកតា ក្នុងនោះ (១) ទំហំ ៧៨៣,៥៩ ហិកតា កាត់ចេញពីដីដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៤១៤/៤៧៧ ចុះថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ២០១៤ (២) ទំហំ ២.៦៦៧,០៧ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន នេតស័រ ផ្លេនថេសិន (៣) ទំហំ ១.៣៣២,៩៥ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន បេសរ៉ូយ៉ាល់ (៤) ទំហំ ៨៦៦,៧២ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន តៃនីញ សៀមរាប អភិវឌ្ឍន៍កៅស៊ូ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដែលទំហំ ៥.២៦០,៥៨ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងទំហំ ៣៨៩,៧៥ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ (អូរ បឹង ត្រពាំង និងហេដ្ឋារចនាសម្ព័ន្ធ) នៅភូមិថ្នល់កែង ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (១) និង (២) នៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិថ្នល់កែង ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។

**មាត្រា ៣**: ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសរុប ១.៥៥២ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិ លើដីឯកជន ១.៥៥១ ក្បាលដី ជូនប្រជាពលរដ្ឋ ១.០៨៦ គ្រួសារ និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើដី សាធារណៈរបស់រដ្ឋ ០១ ក្បាលដី (ដីបន្ទាយកងពលតូចអន្តរាគមន៍លេខ ០៦) ។

**មាត្រា ៤** : ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និង អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៦៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ៣ ១៦៣,៧០ហិកតា នៅស្រុកកំពង់សីលា ខេត្តព្រះសីហនុ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៣៦ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១១៨អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៤៦អនក្រ.បក ចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ០៦៨សណ/១៤ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៤ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះសីហនុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# សម្រេច

**មាត្រា ១**: ត្រូវបានកាត់ដីទំហំ ៣ ១៦៣,៧០ ហិកតា ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋដែលទំហំ ៣ ០៥២,៦២ ហិកតា សម្រាប់ប្រទានកម្មដីជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងដីទំហំ ១១១,០៨ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅស្រុកកំពង់សីលា ខេត្តព្រះសីហនុ ក្នុងភូមិ ឃុំ ដូចខាងក្រោម ៖

-ផ្ទៃដីទំហំ ១៥៨,១៨ ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ ដែលទំហំ ១៥៧,៧៦ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងដីទំហំ ០,៤២ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិចំការហ្លួង ឃុំចំការហ្លួង

-ផ្ទៃដីទំហំ ១៨៧៦,៧១ ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ ដែលទំហំ ១៨៣២,៦៥ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងដីទំហំ ៤៤,០៦ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិបឹងគ្រាច ឃុំចំការហ្លួង

-ផ្ទៃដីទំហំ ១១២៨,៨១ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ ដែលទំហំ ១០៦២,២១ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងដីទំហំ ៦៦,៦០ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិសម្តេចតា ឃុំចំការហ្លួង

តាមប្រព័ន្ធកូអរដោណេ Projection UTM Zone 48N Datum WGS 84 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី១ ទី២ ទី៣ និងឧបសម្ព័ន្ធទី៤នៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះសីហនុធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូន

ប្រជាពលរដ្ឋចំនួន ៣៣៦គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅស្រុកកំពង់សីលា ខេត្តព្រះសីហនុ ក្នុងភូមិ ឃុំ ដូចខាងក្រោម៖

-ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៣គ្រួសារ នៅភូមិចំការហ្លួង ឃុំចំការហ្លួង

-ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២២១គ្រួសារ នៅភូមិបឹងគ្រាច ឃុំចំការហ្លួង

-ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៩២គ្រួសារ នៅភូមិសម្តេចតា ឃុំចំការហ្លួង ។

**មាត្រា ៣:** ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ខេត្តព្រះសីហនុ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤:** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល៖*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៣៦១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ .–**

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ** ថ្នាក់អស្សរឫទ្ធិ ប្រគេន និងផ្តល់ជូនសប្បុរសជនចំនួន ០៣ រូប ដែលបានលះបង់កំលាំងកាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា និងអប់រំ នៅ**វត្តប្រាសាទ** ស្ថិតក្នុងឃុំជ្រៃឃ្មុំ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង ដែលមានរាយព្រះនាម និង នាមដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | **កែ អ៊ិន** | ចៅអធិការវត្តប្រាសាទ | បច្ច័យចំនួន ១៥.០០០ ដុល្លារ |
| ២-ព្រះតេជគុណធម្មបណ្ឌិតោ | **ជុំ សុវណ្ណា** | គង់នៅវត្តប្រាសាទ | បច្ច័យចំនួន ១៣.០០០ ដុល្លារ |
| ៣-លោក | **នួន ទិចិត្រ** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន ៤៤.៣០០ ដុល្លារ |

**មាត្រា ២ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តព្រៃវែង និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣៦៤ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ .–**

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** ផ្តល់ជូនសប្បុរសជនចំនួន ០៣ រូប ដែលបានលះបង់កំលាំងកាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា និងអប់រំ នៅ**វត្តប្រាសាទ** ស្ថិតក្នុងឃុំជ្រៃឃ្មុំ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង ដែលមានរាយនាមដូចខាងក្រោម :

**ក- មេដាយមាសកស្ថាបនាជាតិ ចំនួន០២ គ្រឿង ផ្តល់ជូន :**

| | | | |
|---|---|---|---|
| ១-ឧបាសក | **គៀន គក់** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន ១០.៣០០ ដុល្លារ |
| ២-លោក | **ហុង វណ្ណាន** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន ១៧.០០០ ដុល្លារ |

**ខ- មេដាយសិរីវឌ្ឍិស្ថាបនាជាតិ ចំនួន ០១ គ្រឿង ផ្តល់ជូន**

| | | | |
|---|---|---|---|
| ទាយិកា | **អ៊ុច សារ៉ុម** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន ២.៥០០ ដុល្លារ |

**មាត្រា ២ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តព្រៃវែង និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣៦៣ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## សម្រេច

**មាត្រា ១.-** បំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនក្រុមគ្រួសារសប្បុរសជន ចំនួន០៦រូប ដែលមានឈ្មោះ HOME FOUNDATION រស់នៅប្រទេសន័រវេស ដោយបានផ្តល់ដីទំហំ ១៦$^{m}$ x ២៨$^{m}$ និងសាងសង់អគារមណ្ឌលសុខភាព ០១ខ្នង ទំហំ៩.៥$^{m}$ x ១៥$^{m}$ ព្រមទាំងបំពាក់គ្រឿងសង្ហារឹម និងបរិក្ខារពេទ្យមួយចំនួន ស្ថិតនៅភូមិត្រពាំងអំពិល ឃុំតាអោម ស្រុកត្រាំកក់ ខេត្តតាកែវ ដូចមានរាយនាមខាងក្រោម ៖

១-លោក Gunstein Stray
២-លោក Jahn Arild Stray
៣-លោក Arne Stray
៤-លោក Kjell Røme
៥-លោក Sivun Pen
៦-លោកស្រី Sophath Prak

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល អភិបាលនៃគណៈអភិបាលខេត្តតាកែវ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ [illegible] ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣៦៤ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ /រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តកណ្ដាល

**សម្រេច**

**មាត្រា ១.-** បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ចំនួន ០៣គ្រឿង ប្រគេន និងជូនសប្បុរសជន ចំនួន ០៣រូប ដែលបានបរិច្ចាគបច្ច័យ និងធនធាន ចូលរួមកសាង សមិទ្ធផលនានា នៅវត្តព្រែកឫស្សី ឃុំព្រែកឫស្សី ស្រុកល្វាឯម ខេត្តកណ្ដាល កន្លងមក សម្រេចបានលទ្ធផលល្អប្រសើរ ដូចមានរាយ ព្រះនាម និងនាមខាងក្រោម៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ**

- លោក **សុខ ម៉ិនអ៊ែត** សប្បុរសជន នៅរាជធានីភ្នំពេញ

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សប្រិទ្ធិ**

១- ព្រះតេជគុណ **ឌឹម ចន្ទ្រាជា** គ្រូសូត្រស្តាំវត្តពាមតាឯក

២- លោក **សួស លន់** ប្រធានការិយាល័យធម្មការ និងសាសនាស្រុកល្វាឯម

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អភិបាលនៃគណៈអភិបាលខេត្តកណ្ដាល និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...៣៦៥...សសរក.តត

ជាតិ សាសនា ព្រះមហាក្សត្រ

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ /រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តកណ្តាល

### សម្រេច

**មាត្រា ១.-** បំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន ៦១គ្រឿង ប្រគេន និងជូនសប្បុរសជន ចំនួន ៦១រូប ដែលបានបរិច្ចាគបច្ច័យ និងធនធាន ចូលរួមកសាង សមិទ្ធផលនានា នៅវត្តព្រែកឫស្សី ឃុំព្រែកឫស្សី ស្រុកល្វាឯម ខេត្តកណ្តាល កន្លងមក សម្រេចបានលទ្ធផលល្អប្រសើរ ដូចមានរាយព្រះនាម និងនាមខាងក្រោម៖

**ក-មេដាយមាសស្ថាបនាជាតិ**

| | | | |
|---|---|---|---|
| ១- | ព្រះតេជគុណ | **ស៊ឹម យុត្ត** | ចៅអធិការស្តីទី វត្តព្រែកឫស្សី |
| ២- | ព្រះតេជគុណ | **អ៊ឹម ប៉ាន់** | គ្រូសូត្រស្តាំ វត្តព្រែកឫស្សី |
| ៣- | ព្រះតេជគុណ | **ហាស់ ហ៊ុយ** | គ្រូសូត្រឆ្វេង វត្តព្រែកឫស្សី |
| ៤- | ព្រះតេជគុណ | **ប៉ាន់ រស់** | សប្បុរសជន អូស្ត្រាលី |
| ៥- | លោក | **ព្រហ្ម ហាយ** | សប្បុរសជន នៅឃុំព្រែកឫស្សី |
| ៦- | ឧបាសិកា | **សៅ ញ៉ឹក** | សប្បុរសជន នៅឃុំព្រែកឫស្សី |
| ៧- | ឧបាសិកា | **សួន ហួន** | សប្បុរសជន នៅឃុំព្រែកឫស្សី |
| ៨- | ឧបាសក | **រស់ ធុន** | សប្បុរសជន នៅបន្ទាយដែក |
| ៩- | ព្រះតេជគុណ | **អឿង គីមថេត** | ចៅអធិការវត្តពាមស្តី |
| ១០- | ព្រះតេជគុណ | **សុត ថា** | ចៅអធិការវត្តអន្លង់ទ្រា |
| ១១- | ព្រះតេជគុណ | **អ៊ុំ ឡៀក** | ចៅអធិការវត្តពោធិវនារាម |
| ១២- | ព្រះតេជគុណ | **គីម ពៅ** | ចៅអធិការវត្តសេរីមង្គលប្រាជុំ |

| | | | |
|---|---|---|---|
| ១៣- | ព្រះតេជគុណ | ញៀម ញាក់ | ចៅអធិការវត្តវិហារខ្ពស់ |
| ១៤- | ព្រះតេជុណា | លន់ គីមសាន | ចៅអធិការវត្តព្រៃកគង់រាជ |
| ១៥- | ព្រះតេជគុណ | យូ សារ៉េន | ចៅអធិការវត្តមុនីរស្មី |
| ១៦- | ព្រះតេជគុណ | មុំ ខ្វាន់ | ចៅអធិការស្តីទីវត្តកែវកុមារនេត្រ |
| ១៧- | ព្រះតេជគុណ | ឈួន កុសល | ចៅអធិការវត្តបារ៉ុង |
| ១៨- | ព្រះតេជគុណ | សឺខ សាមី | ចៅអធិការវត្តខ្មោការ |
| ១៩- | ព្រះតេជគុណ | រិន បូរី | ចៅអធិការវត្តអរិយក្សត្រ |
| ២០- | ព្រះតេជគុណ | កែម សុផាន់ណា | ចៅអធិការវត្តសុវណ្ណសាគរ |
| ២១- | ព្រះតេជគុណ | នួន កុសល | ចៅអធិការវត្តពេជ្រម្កុដ |
| ២២- | ព្រះតេជគុណ | ស៊ឹម មឿន | ចៅអធិការស្តីទីវត្តសារិកាកែវ |
| ២៣- | ព្រះតេជគុណ | ស្វាយ ខុន្ធី | ចៅអធិការវត្តសុវណ្ណតេជោ |
| ២៤- | ព្រះតេជគុណ | សឿន សយ | ចៅអធិការវត្តមាត់ក្រសាស់ |
| ២៥- | ព្រះតេជគុណ | ម៉ិន សាខុន | ចៅអធិការវត្តសំពោង |
| ២៦- | ព្រះតេជគុណ | ម៉ិន ស៊ីណាត | ចៅអធិការវត្តជ្រោយពិសី |
| ២៧- | ព្រះតេជគុណ | ខាត់ ឃឹម | ចៅអធិការវត្តជ្រៃ |
| ២៨- | ព្រះតេជគុណ | សេខ ខន | ចៅអធិការស្តីទីវត្តយសមន្ត្រី |
| ២៩- | ព្រះតេជគុណ | យ៉ាន ឌិត្យ | ចៅអធិការស្តីទីវត្តបន្ទាយម្លូ |

ខ-មេដាយប្រាក់ស្ថាបនាជាតិ

| | | | |
|---|---|---|---|
| ១- | ព្រះតេជគុណ | ជា ប៊ុនធឿន | គ្រូសូត្រឆ្វេងវត្តស្វាយអណ្តែត |
| ២- | ព្រះតេជគុណ | ស្រ៊ុន គីមស្រេង | គ្រូសូត្រស្តាំវត្តស្វាយអណ្តែត |
| ៣- | ព្រះតេជគុណ | យ៉ាន់ រដ្ឋា | គ្រូសូត្រស្តាំវត្តពោធិ៍មាស |
| ៤- | ព្រះតេជគុណ | ទេស សុចាន់ | គ្រូសូត្រឆ្វេងវត្តពោធិ៍មាស |
| ៥- | ព្រះតេជគុណ | ជាន ត្រុញ | ភិក្ខុគង់ក្នុងវត្តពោធិ៍មាស |
| ៦- | ព្រះតេជគុណ | មាស សុតី | ភិក្ខុគង់ក្នុងវត្តពោធិ៍មាស |
| ៧- | ឧបាសក | សុខ ភន | អាចារ្យវត្តព្រៃកឬស្សី |
| ៨- | លោក | ព្រហ្ម ម៊ី | សប្បុរសជន នៅបន្ទាយដែក |
| ៩- | ឧបាសក | អុខ មិន | សប្បុរសជន នៅព្រៃកឬស្សី |
| ១០- | អ្នកស្រី | ខួន ម៉ាលី | សប្បុរសជន នៅរាជធានីភ្នំពេញ |
| ១១- | ឧបាសក | ហ៊ាង ហ៊ុន | សប្បុរសជន នៅព្រៃកឬស្សី |
| ១២- | ឧបាសិកា | ជាម ធន់ | សប្បុរសជន នៅសហរដ្ឋអាមេរិក |
| ១៣- | លោកតា | ឃឹម ខៀវ | អាចារ្យវត្តព្រៃកឬស្សី |
| ១៤- | លោកតា | ម៉ៅ ចឹក | អាចារ្យវត្តព្រៃកឬស្សី |
| ១៥- | លោកតា | ពត សាន់ | អាចារ្យវត្តព្រៃកឬស្សី |
| ១៦- | លោកតា | ស៊ិន សាន | អាចារ្យវត្តព្រៃកឬស្សី |
| ១៧- | លោកតា | សុក ម៉េត | គណៈកម្មការវត្តព្រៃកឬស្សី |

| | | | |
|---|---|---|---|
| ១៨- | លោកតា | ជែក ផែត | គណៈកម្មការវត្តព្រែកឬស្សី |
| ១៩- | លោក | ឆូ សម្បត្តិ | គណៈកម្មការវត្តព្រែកឬស្សី |
| ២០- | លោក | ប៊ុត ខុម | គណៈកម្មការវត្តព្រែកឬស្សី |
| ២១- | លោក | សុក ឆុក | គណៈកម្មការវត្តព្រែកឬស្សី |
| ២២- | លោក | អ៊ី ជា | គណៈកម្មការវត្តព្រែកឬស្សី |
| ២៣- | លោក | ម៉ន ម៉ៃ | គណៈកម្មការវត្តព្រែកឬស្សី |
| ២៤- | លោក | ឌឹម អុល | គណៈកម្មការវត្តព្រែកឬស្សី |
| ២៥- | លោក | ហង់ គីម | គណៈកម្មការវត្តព្រែកឬស្សី |

**គ-មេដាយសិរីវឌ្ឍនាជាតិ**

| | | | |
|---|---|---|---|
| ១- | ឧបាសិកា | ទ៊ុង អយ | សមាជិកគណៈកម្មការវត្តព្រែកឬស្សី |
| ២- | ឧបាសិកា | អ៊ុម អុល | សមាជិកគណៈកម្មការវត្តព្រែកឬស្សី |
| ៣- | លោក | ស៊ឹម ផូ | សមាជិកគណៈកម្មការវត្តព្រែកឬស្សី |
| ៤- | លោក | ហាន ទង់ | សមាជិកគណៈកម្មការវត្តព្រែកឬស្សី |
| ៥- | លោក | មឿន ស្លា | សមាជិកគណៈកម្មការវត្តព្រែកឬស្សី |
| ៦- | លោក | ឈួន យ៉ឹន | សមាជិកគណៈកម្មការវត្តព្រែកឬស្សី |
| ៧- | លោក | ឆេង ផាន | សមាជិកគណៈកម្មការវត្តព្រែកឬស្សី |

**មាត្រា ២.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អភិបាលនៃគណៈអភិបាលខេត្តកណ្តាល និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ មេសា ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣៦៦ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ /រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តកណ្តាល

**សម្រេច**

**មាត្រា ១.-** បំពាក់ **មេដាយមាសការងារ** ចំនួន ០២គ្រឿង ជូនមន្ត្រីរាជការ នៃការិយាល័យធម្មការ និងសាសនាស្រុកល្វាឯម ចំនួន ០២រូប ដែលបានបរិច្ចាគកម្លាំងកាយ-ចិត្ត ព្រមទាំងធនធាន ចូលរួមកសាង សមិទ្ធផលនានា នៅឃុំព្រែកឫស្សី ស្រុកល្វាឯម ខេត្តកណ្តាល កន្លងមក សម្រេចបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១- | លោក | **ទ្រាំ** | **ណយ** | អនុប្រធានការិយាល័យធម្មការ និងសាសនាស្រុកល្វាឯម |
| ២- | លោក | **ខំ** | **រតន** | មន្ត្រីការិយាល័យធម្មការ និងសាសនាស្រុកល្វាឯម |

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អភិបាលនៃគណៈអភិបាលខេត្តកណ្តាល និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០[illegible] ខែ មីនា ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៣៦៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ

## សម្រេច

**មាត្រា១.-** បំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០៥រូប ដែលបានបរិច្ចាគធនធានចូលរួមជួយកសាងព្រះវិហារ ០១ខ្នង រួមចំណែកក្នុងការអភិវឌ្ឍវិស័យព្រះពុទ្ធសាសនា នៅវត្តមុនីរតនារាម ហៅ **វត្តអន្លង់ថ្នាន់** ឃុំបត់ត្រង់ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-ឧបាសក | **គា** | **ម៉ក** | ថវិកាចំនួន ៩៧.៦៥០ ដុល្លារ |
| ២-អ្នកស្រី | **ឈឿង** | **ហុង** | ថវិកាចំនួន ៥៥.៣៧២ ដុល្លារ |
| ៣-លោក | **ពិន** | **ប៊ុនរ៉េត** | ថវិកាចំនួន ១៣.៣៥០ ដុល្លារ |
| ៤-លោក | **ឈឿង** | **ឡី** | ថវិកាចំនួន ១២.៧០០ ដុល្លារ |
| ៥-ឧបាសក | **ចេក** | **ឃាន** | ថវិកាចំនួន ១១.២១០ ដុល្លារ |

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៦៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.—**

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេននិងផ្តល់ជូនសប្បុរសជនចំនួន ៥១រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា នៅ**វត្តសុវណ្ណសិលា វត្តលោមព្រលឹង វត្តប្រាសាទច័ន្ទសីមា វត្តបញ្ចគោល** និង**វត្តប្រាសាទអណ្តែត** ស្ថិតនៅក្នុងឃុំដានរុន និងឃុំចាន់ស ស្រុកសូទ្រនិគម ខេត្តសៀមរាប ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

**ក. មេដាយមាសស្ថាបនាជាតិចំនួន ១៦ គ្រឿង ប្រគេន និងផ្តល់ជូន :**

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណចន្ទបជ្ជោតោ | **គ្រួច ផាន់** | ព្រះចៅអធិការវត្តប្រាសាទអណ្តែត | បច្ច័យចំនួន ២៥.០០០ ដុល្លារ |
| ២-ព្រះតេជគុណចិត្តសំវរោ | **ត្រូប់ រិទ្ធី** | ព្រះគ្រូសូត្រស្តាំ | បច្ច័យចំនួន ១២.៥០០ ដុល្លារ |
| ៣-ព្រះតេជគុណចង្គមរក្ខិ | **ម៉ៅ ថៅ** | ព្រះគ្រូសូត្រឆ្វេង | បច្ច័យចំនួន ១២.៥០០ ដុល្លារ |
| ៤-ព្រះតេជគុណនាគត្ថេរ | **ហង្ស ហៃ** | ព្រះចៅអធិការវត្តសុវណ្ណសិលា | បច្ច័យចំនួន ១៥.២៧៣ ដុល្លារ |
| ៥-ព្រះតេជគុណឥន្ទធម្មោ | **ឡូត ហាន** | ព្រះគ្រូសូត្រស្តាំ | បច្ច័យចំនួន ១៥.២៥០ ដុល្លារ |
| ៦-ព្រះតេជគុណជោតិសុកោ | **ស្វោភ ម៉ុនជា** | ព្រះគ្រូសូត្រឆ្វេង | បច្ច័យចំនួន ១៥.២៥០ ដុល្លារ |
| ៧-ឧបាសក | **ឈឿម នុង** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ២០.០០០ ដុល្លារ |
| ៨-ឧបាសិកា | **ហឿង គីមហ៊ាក់** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ១៦.៧៥០ ដុល្លារ |

| | | | |
|---|---|---|---|
| ៩-លោក | ថាំង សម្បត្តិ | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ១៦.០០០ ដុល្លារ |
| ១០-ឧបាសក | ម៉ម សុខ | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ១២.០០០ ដុល្លារ |
| ១១-ឧបាសិកា | លី យក់យន់ | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ១២.០០០ ដុល្លារ |
| ១២-លោកស្រី | ចិន មុំ | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ១២.០០០ ដុល្លារ |
| ១៣-លោក | ជឿ ដាំ | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ១០.៩០០ ដុល្លារ |
| ១៤-ឧបាសក | ម៉ុក ឆាន់ | អាចារ្យវត្តលោមព្រលឹង | ថវិកាចំនួន ១០.០៤០ ដុល្លារ |
| ១៥-ឧបាសក | ជា ឈង់ | គណៈកម្មការវត្តលោមព្រលឹង | ថវិកាចំនួន ១០.០៤០ ដុល្លារ |
| ១៦-ឧបាសក | ម៉ែន សាន | គណៈកម្មការវត្តលោមព្រលឹង | ថវិកាចំនួន ១០.០៣០ ដុល្លារ |

**ខ_មេដាយប្រាក់ស្ថាបនាជាតិចំនួន ០៨ គ្រឿង ផ្តល់ជូន :**

| | | | |
|---|---|---|---|
| ១-ឧបាសក | មឹង ផន | អាចារ្យវត្ត | ថវិកាចំនួន ៥.៩០០ ដុល្លារ |
| ២-ឧបាសក | លួង ណែម | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ៥.៨០០ ដុល្លារ |
| ៣-ឧបាសក | ហេង រឿន | អាចារ្យវត្តរង | ថវិកាចំនួន ៥.៧៥០ ដុល្លារ |
| ៤-ឧបាសក | សួន ឡូរី | គណៈកម្មការវត្ត | ថវិកាចំនួន ៥.៧៥០ ដុល្លារ |
| ៥-ឧបាសក | ហាម គ្រប់ | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ៥.៧២២ ដុល្លារ |
| ៦-ឧបាសក | ឈង់ ប៊ុញ | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ៥.៥៦០ ដុល្លារ |
| ៧-ឧបាសក | តាន់ នឹងហួ | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ៥.០៨៥ ដុល្លារ |
| ៨-ឧបាសិកា | ស៊ុន ចិត | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ៥.០៧០ ដុល្លារ |

**គ_មេដាយសំរិទ្ធិស្ថាបនាជាតិចំនួន ២៧ គ្រឿង ផ្តល់ជូន :**

| | | | |
|---|---|---|---|
| ១-ឧបាសិកា | តាន់ ញ៉ុង | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ៤.៩៩៨ ដុល្លារ |
| ២-ឧបាសិកា | អ៊ឹម នន់ | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ៤.៩៩៧ ដុល្លារ |
| ៣-ឧបាសិកា | ចិន មិន | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ៤.៩៩៦ ដុល្លារ |
| ៤-ឧបាសក | មឹង សិន់ | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ៤.៩៩៥ ដុល្លារ |
| ៥-លោក | អឿ ដាំ | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ៤.៩៩៥ ដុល្លារ |
| ៦-ឧបាសក | ឈិញ ជី | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ៤.៩៩៥ ដុល្លារ |
| ៧-ឧបាសក | ស្រី យឿន | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ៤.៩៩៥ ដុល្លារ |
| ៨-ឧបាសិកា | ជាក សាលី | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ៤.៩៩៥ ដុល្លារ |
| ៩-ឧបាសក | ម៉ឹង អ៊ែម | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ៤.៩៩៣ ដុល្លារ |
| ១០-ឧបាសក | ភង ណៃ | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ៤.៩៩២ ដុល្លារ |

| | | |
|---|---|---|
| ១១-ឧបាសិកា **ឃួន ហូ** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ៤.៩៩១ ដុល្លារ |
| ១២-ឧបាសិកា **ខិន ជា** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ៤.៩៩០ ដុល្លារ |
| ១៣-ឧបាសក **តាន់ តាតគន់** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ៤.៩៩០ ដុល្លារ |
| ១៤-ឧបាសក **ហៀក ម៉ុញ** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ៤.៩៩០ ដុល្លារ |
| ១៥-លោក **ស៊ុយ សារឿន** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ៤.៩៨០ ដុល្លារ |
| ១៦-ឧបាសក **ធិន ថន** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ៤.៩៨០ ដុល្លារ |
| ១៧-ឧបាសក **ឈុយ ឈឿង** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ៤.៩៨០ ដុល្លារ |
| ១៨-ឧបាសក **មាស លេខ** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ៤.៩៨០ ដុល្លារ |
| ១៩-ឧបាសិកា **មឹង ណែម** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ៤.៩៨០ ដុល្លារ |
| ២០-ឧបាសក **ស្រី គី** | អាចារ្យវត្តលោមព្រលឹង | ថវិកាចំនួន ៤.៩៨០ ដុល្លារ |
| ២១-ឧបាសក **យឹម យឿម** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ៤.៩៧០ ដុល្លារ |
| ២២-ឧបាសិកា **យ៉ែម ទឿន** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ៤.៩៧០ ដុល្លារ |
| ២៣-ឧបាសក **យឹប ហ៊ត់** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ៤.៩៧០ ដុល្លារ |
| ២៤-ឧបាសក **ហុក យន់** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ៤.៩៦០ ដុល្លារ |
| ២៥-ឧបាសក **លុយ ហូ** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ៤.៩៥០ ដុល្លារ |
| ២៦-ឧបាសក **ហ៊ិន ពូ** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ៤.៩៥០ ដុល្លារ |
| ២៧-ឧបាសក **ខួន យន់** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ៤.៩០០ ដុល្លារ |

**មាត្រា២.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៤*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ៣៦៩ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនគ្រឿងឥស្សរិយយសសុវត្ថារា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.—**

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ធិបឌិន្ទ** ប្រគេនព្រះតេជគុណចំនួន ០២ ព្រះអង្គ ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា នៅ**វត្តសុវណ្ណសិលា វត្តលោមព្រលឹង វត្តប្រាសាទច័ន្ទសីមា** និង**វត្តប្រាសាទអណ្តែត** ស្ថិតនៅក្នុងឃុំដានរុន និងឃុំចាន់ស ស្រុកសូទ្រនិគម ខេត្តសៀមរាប ដែលមានរាយព្រះនាមដូចខាងក្រោម :

១-ព្រះតេជគុណចរណធម្មោ **ទិន ថៃ** ព្រះចៅអធិការវត្តលោមព្រលឹង បច្ច័យចំនួន ១០១.៧៥០ ដុល្លារ

២-ព្រះតេជគុណបញ្ញាធរោ **ហៀង ណារិទ្ធ** ព្រះសមុហ៍អគុណស្រុកសូទ្រនិគម បច្ច័យចំនួន ៩៥.៦១០ ដុល្លារ

**មាត្រា ២.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>**កន្លែងទទួល**</u> :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៣៩៧០ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីសហលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងលោក **នឹម នីរ៉ាដេត** បាំងទន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៣ ជាអភិបាលស្រុកអង្គស្នួល នៃខេត្តកណ្តាល ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៤*

**<u>កន្លែងទទួល</u> :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣៧១...អនក្រ-ទទ

# អនុក្រឹត្យ

## ស្តីពី

## ការសម្រួលភារកិច្ច និងតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈ ដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែ មករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានសម្រួលភារកិច្ចអភិបាលក្រុង ស្រុកចំនួន ០២រូប នៅខេត្តកំពង់ស្ពឺ ដូចមានរាយនាមខាងក្រោម :

១-លោក **ខួន ឡាញ់** ឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ១៤ ពីអភិបាលស្រុកថ្ពង ឱ្យមកបម្រើការងារនៅសាលាខេត្តកំពង់ស្ពឺ

២-លោក **ហ៊ុយ ស៊ីឡើន** ឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ៧ ពីអភិបាលក្រុងច្បារមន ឱ្យមកបម្រើការងារនៅសាលាខេត្តកំពង់ស្ពឺ ។

**មាត្រា ២ :** ត្រូវបានតែងតាំងមន្ត្រីរាជការចំនួន ០២រូប ជាអភិបាលក្រុង ស្រុក នៅខេត្តកំពង់ស្ពឺ ដូចមានរាយនាមខាងក្រោម :

១-លោក **អេង ស្រ៊ុន** ឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ៩ ជាអភិបាលស្រុកថ្ពង

២-លោកស្រី **ប៉ោក សេដ្ឋា** ឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ៩ ជាអភិបាលក្រុងច្បារមន។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ និងមាត្រា២ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៥ ខែ មីនា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ   សាសនា   ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:**...៣៧២...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈ ដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែ មករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានផ្ទេរភារកិច្ចលោក **លី ឡេង** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៧ ពីអភិបាលរងនៃគណៈអភិបាលខេត្តកំពង់ចាម ឱ្យមកបម្រើការងារនៅទីស្តីការក្រសួងមហាផ្ទៃ។

**មាត្រា ២ :** តែងតាំងលោក **អ៊ុំតឿន គុណវឌ្ឍ** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៧ ជាអភិបាលរង នៃគណៈអភិបាលខេត្តកំពង់ចាម។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ និងមាត្រា២ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៤*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u> :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..៣.៧.៣..អន.ក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា

### សម្រេច

**មាត្រា១.**.បំពាក់មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន១៩រូប ដែលបានបរិច្ចាគធនធានចូលរួមជួយកសាងសមិទ្ធផលលើវិស័យព្រះពុទ្ធសាសនា នៅវត្តបន្ទាប់ ឃុំមហាសាំង ស្រុកភ្នំស្រួច និងវត្តអង្គខ្មៅ ឃុំសំបួរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមាសស្ថាបនាជាតិ**

| | | | |
|---|---|---|---|
| ១-លោក | តូច | សុគន្ធិ | ថវិកាចំនួន ១២.០០០ ដុល្លារ |
| ២-អ្នកស្រី | អ៊ឹង | ឡាងហៀង | ថវិកាចំនួន ១០.៤០០ ដុល្លារ |
| ៣-អ្នកស្រី | ស៊ុន | គីមឡេង | ថវិកាចំនួន ១០.៣៥០ ដុល្លារ |
| ៤-លោក | លី | យូឃុន | ថវិកាចំនួន ១០.៣២០ ដុល្លារ |
| ៥-លោក | សៀម | ឡាយ | ថវិកាចំនួន ១០.៣០០ ដុល្លារ |
| ៦-លោក | ឡាំ | គៀត | ថវិកាចំនួន ១០.២៩០ ដុល្លារ |
| ៧-អ្នកស្រី | គល់ | គីមស្រស់ | ថវិកាចំនួន ១០.២៥០ ដុល្លារ |
| ៨-លោក | អៀ | ឈុនឡេង | ថវិកាចំនួន ១០.២៣០ ដុល្លារ |
| ៩-លោក | ឌុយ | ច័ន្ទឌីណា | ថវិកាចំនួន ១០.២០០ ដុល្លារ |
| ១០-លោក | តាំង | ម៉ីហួរ | ថវិកាចំនួន ១០.១៨០ ដុល្លារ |
| ១១-លោក | ជា | ម៉ិន | ថវិកាចំនួន ១០.១៥០ ដុល្លារ |
| ១២-លោក | ចិន | សំ | ថវិកាចំនួន ១០.១០០ ដុល្លារ |
| ១៣-លោក | មុំ | ឡៃ | ថវិកាចំនួន ១០.១០០ ដុល្លារ |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ**

| | |
|---|---|
| ១-លោក **សុក សុន** | ថវិកាចំនួន ៩.០០០ ដុល្លារ |
| ២-លោក **ប៊ិច អន** | ថវិកាចំនួន ៩.០០០ ដុល្លារ |

**គ-មេដាយសំរិទ្ធស្ថាបនាជាតិ**

| | |
|---|---|
| ១-លោក **ឡាយ សុខ** | ថវិកាចំនួន ២.៥០០ ដុល្លារ |
| ២-លោក **នាង គីមសេង** | ថវិកាចំនួន ២.៥០០ ដុល្លារ |
| ៣-លោកវេជ្ជបណ្ឌិត **ជា ខួន** | ថវិកាចំនួន ២.៥០០ ដុល្លារ |
| ៤-លោក **ម៉ម គួង** | ថវិកាចំនួន ២.៥០០ ដុល្លារ |

**មាត្រា២..** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា អភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ និងសាមីខ្លួន ត្រូវទទួលបន្ទុក អនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ [illegible] ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣៧៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា

## សម្រេច

**មាត្រា១.-** បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ប្រគេននិងជូនសប្បុរសជន ចំនួន០២រូប ដែលបានបរិច្ចាគធនធានចូលរួមជួយកសាងសមិទ្ធផលលើវិស័យព្រះពុទ្ធសាសនា នៅវត្តបន្ទាប់ ឃុំមហាសាំង ស្រុកភ្នំស្រួច និងវត្តអង្គខ្មៅ ឃុំសំបួរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ដូចមានរាយព្រះនាមនិងនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណបវរោ | **សៅ** | **សាត** | បច្ច័យចំនួន ២២.០០០ ដុល្លារ |
| ២-លោក | **ឡុង** | **សាន** | ថវិកាចំនួន ២១.៥០០ ដុល្លារ |

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា អភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៧៥ អនក.បក - ១៤

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## សម្រេច

**មាត្រា១.-** បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃក្រសួងយុត្តិធម៌ ចំនួន៩៦រូប ដែលមានស្នាដៃល្អនិងស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការបំពេញភារកិច្ចជូនក្រសួង កន្លងមក ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ**

| | | | |
|---|---|---|---|
| ១ | -លោក | ទិត សារឿន | ប្រធាននាយកដ្ឋានកិច្ចការបុគ្គលិក |
| ២ | -លោក | សុច សុជាន់ណារ៉ា | ប្រធាននាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ |
| ៣ | -លោកស្រី | ជាន់ ច័ន្ទលី | ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| ៤ | -លោក | លិន សីលា | អធិការ នៃអគ្គាធិការដ្ឋានកិច្ចការតុលាការ |
| ៥ | -លោក | បូន កុសល | អធិការ នៃអគ្គាធិការដ្ឋានកិច្ចការតុលាការ |
| ៦ | -លោក | ផ្ញង់ ពិសិដ្ឋ | អធិការ នៃអគ្គាធិការដ្ឋានកិច្ចការតុលាការ |
| ៧ | -លោក | ស៊ឺ ពិសេដ្ឋ | អនុប្រធាននាយកដ្ឋានកិច្ចការហិរញ្ញវត្ថុ |
| ៨ | -លោក | សេង សុវណ្ណ | អនុប្រធាននាយកដ្ឋានកិច្ចការនីតិកម្ម |
| ៩ | -លោក | សេង ពុទ្ធី | អនុប្រធាននាយកដ្ឋានកិច្ចការនីតិកម្ម |
| ១០ | -លោកស្រី | យុន ច័ន្ទសោភា | អនុប្រធាននាយកដ្ឋានអប់រំ និងផ្សព្វផ្សាយច្បាប់ |
| ១១ | -លោក | ទុំ សោភ័ណ | អនុប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង |

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា**

| | | | |
|---|---|---|---|
| ១ | -លោកស្រី | និល ហ៊ីលីប | ប្រធាននាយកដ្ឋានអប់រំ និងផ្សព្វផ្សាយច្បាប់ |
| ២ | -លោក | សៀ គុង | អធិការ នៃអគ្គាធិការដ្ឋានកិច្ចការតុលាការ |
| ៣ | -លោក | ចេង គីមហ៊ាង | អនុប្រធាននាយកដ្ឋានកិច្ចការហិរញ្ញវត្ថុ |
| ៤ | -លោក | ម៉ៅ គុយលីម | អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ |
| ៥ | -លោក | សៀង ហ៊ី | អនុប្រធាននាយកដ្ឋានស្រាវជ្រាវ និងបណ្តុះបណ្តាល |
| ៦ | -លោក | ជា សំបូរ | ប្រធានការិយាល័យ នៃនាយកដ្ឋានអប់រំ និងផ្សព្វផ្សាយច្បាប់ |
| ៧ | -លោកស្រី | វ៉ាន់ យ៉ានីន | ប្រធានការិយាល័យ នៃនាយកដ្ឋានស្រាវជ្រាវ និងបណ្តុះបណ្តាល |
| ៨ | -លោក | ថេង ជាង | ប្រធានការិយាល័យ នៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| ៩ | -លោក | ស៊ូ សុវណ្ណារ៉ា | នាយកក្រឡាបញ្ជី នៃសាលាដំបូងខេត្តកោះកុង |
| ១០ | -លោក | លឹម ស៊ីណាត | នាយកក្រឡាបញ្ជី នៃសាលាដំបូងខេត្តបន្ទាយមានជ័យ |

**គ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ**

| | | | |
|---|---|---|---|
| ១ | -លោក | ហេង សេង | អធិការ នៃអគ្គាធិការដ្ឋានកិច្ចការតុលាការ |
| ២ | -លោក | សុន ស៊ី | អធិការ នៃអគ្គាធិការដ្ឋានកិច្ចការតុលាការ |
| ៣ | -លោក | ង៉ែត ដារុធ | អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ |
| ៤ | -លោក | ចែម វាសនា | អនុប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| ៥ | -លោក | ចេង សុភា | ប្រធានការិយាល័យ នៃនាយកដ្ឋានកិច្ចការហិរញ្ញវត្ថុ |
| ៦ | -លោក | សុខ សាន | ប្រធានការិយាល័យ នៃនាយកដ្ឋានកិច្ចការបុគ្គលិក |
| ៧ | -លោក | ឆាយ សុភាព | ប្រធានការិយាល័យ នៃនាយកដ្ឋានកិច្ចការបុគ្គលិក |
| ៨ | -លោក | ជាម សត្យា | ប្រធានការិយាល័យ នៃនាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ |
| ៩ | -លោក | ពៅ វិបុល | ប្រធានការិយាល័យ នៃនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ |
| ១០ | -លោកស្រី | ជុន ចំរើន | ប្រធានការិយាល័យ នៃនាយកដ្ឋានអប់រំ និងផ្សព្វផ្សាយច្បាប់ |
| ១១ | -លោក | ស៊ឹម កល្យាណ | អនុប្រធានការិយាល័យ នៃនាយកដ្ឋានកិច្ចការបុគ្គលិក |
| ១២ | -លោក | ឱ ពេជ្រវាសនា | អនុប្រធានការិយាល័យ នៃនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ |
| ១៣ | -លោក | ញឹម សុធា | អនុប្រធានការិយាល័យ នៃនាយកដ្ឋានស្រាវជ្រាវ និងបណ្តុះបណ្តាល |
| ១៤ | -លោកស្រី | ដាន់ ចន្ទ្រាវតី | នាយកក្រឡាបញ្ជី នៃសាលាដំបូងខេត្តកណ្តាល |
| ១៥ | -លោក | ឈាវ រិនឌី | នាយកក្រឡាបញ្ជី នៃអយ្យការអមសាលាដំបូងខេត្តកណ្តាល |
| ១៦ | -លោក | សូ ធីដា | នាយកក្រឡាបញ្ជី នៃសាលាដំបូងខេត្តស្វាយរៀង |
| ១៧ | -លោក | ហ៊ី រត្ន័ | ក្រឡាបញ្ជី នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ |
| ១៨ | -លោក | សួស ចិន្តា | ក្រឡាបញ្ជី នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ |
| ១៩ | -លោក | នួន ចំរើន | ក្រឡាបញ្ជី នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ |
| ២០ | -លោក | ថោង ស៊ីថាន់ | ក្រឡាបញ្ជី នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ |
| ២១ | -លោក | ហាក់ ប៊ុនហោ | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកំពង់ឆ្នាំង |
| ២២ | -លោក | ចេង មុនីរ័ត្ន | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកោះកុង |

| | | | |
|---|---|---|---|
| ២៣ | -លោក | តាំង សុជា | មន្ត្រីគ្រប់គ្រងរដ្ឋបាល នៃនាយកដ្ឋានស្រាវជ្រាវ និងបណ្តុះបណ្តាល |
| ២៤ | -លោក | ហួន ចិន្តា | មន្ត្រីក្រមការ នៃសាលាដំបូងខេត្តកំពង់ឆ្នាំង |
| ២៥ | -លោក | យឹម តុងខូង | លេខាធិការរដ្ឋបាល នៃនាយកដ្ឋានស្រាវជ្រាវ និងបណ្តុះបណ្តាល |

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ៤ ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៧៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## សម្រេច

**មាត្រា១.**- បំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃក្រសួងយុត្តិធម៌ ចំនួន១៤៥រូប ដែលមានស្នាដៃល្អនិងស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការបំពេញភារកិច្ចជូនក្រសួង កន្លងមក ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមាសការងារ**

| | | | |
|---|---|---|---|
| ១ | -លោក | សូ សុខហុង | អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល |
| ២ | -លោក | ចេង សុខមាន | ប្រធានការិយាល័យ នៃនាយកដ្ឋានកិច្ចការហិរញ្ញវត្ថុ |
| ៣ | -លោក | សុទ្ធ ម៉ូលីណា | ប្រធានការិយាល័យ នៃនាយកដ្ឋានកិច្ចការនីតិកម្ម |
| ៤ | -លោក | ប៉ាវ វណ្ណៈ | ប្រធានការិយាល័យ នៃនាយកដ្ឋានកិច្ចការនីតិកម្ម |
| ៥ | -លោក | លី សុវណ្ណ | ប្រធានការិយាល័យ នៃនាយកដ្ឋានអប់រំ និងផ្សព្វផ្សាយច្បាប់ |
| ៦ | -លោកស្រី | ហ៊ិន សុភាព | ប្រធានការិយាល័យ នៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| ៧ | -លោកស្រី | ចិន បូនី | អនុប្រធានការិយាល័យ នៃនាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ |
| ៨ | -លោក | ង៉ែត ផេង | អនុប្រធានការិយាល័យ នៃនាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ |

| | | | |
|---|---|---|---|
| ៩ | -លោក | ជាក វុត្ថា | អនុប្រធានការិយាល័យ នៃនាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ |
| ១០ | -លោកស្រី | ជា ករុណា | អនុប្រធានការិយាល័យ នៃនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ |
| ១១ | -លោក | វឿន លីណា | អនុប្រធានការិយាល័យ នៃនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ |
| ១២ | -លោក | ជិន មុនី | អនុប្រធានការិយាល័យ នៃនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ |
| ១៣ | -លោក | ឃួន វ៉ា | នាយកក្រឡាបញ្ជី នៃអយ្យការអមសាលាដំបូងខេត្តស្វាយរៀង |
| ១៤ | -លោក | ឈួន ស៊ីវិន | នាយកក្រឡាបញ្ជី នៃសាលាដំបូងខេត្តកំពង់ឆ្នាំង |
| ១៥ | -លោក | ហ៊ឹម ពុទ្ធាសុរិយៈ | នាយកក្រឡាបញ្ជី នៃអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង |
| ១៦ | -លោក | ឈិន ឡុង | នាយកក្រឡាបញ្ជី នៃអយ្យការអមសាលាដំបូងខេត្តកោះកុង |
| ១៧ | -លោក | មាស ប្រុស | នាយកក្រឡាបញ្ជី នៃអយ្យការអមសាលាដំបូងខេត្តមណ្ឌលគិរី |
| ១៨ | -លោកស្រី | ម៉ែន សុវ៉ា៉ | ក្រឡាបញ្ជី នៃនាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ |
| ១៩ | -លោកស្រី | សែម សុធារី | ក្រឡាបញ្ជី នៃនាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ |
| ២០ | -លោកស្រី | ជៀប គឹមលុច | ក្រឡាបញ្ជី នៃនាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ |
| ២១ | -លោកស្រី | ស្វន សុវណ្ណ | ក្រឡាបញ្ជី នៃនាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ |
| ២២ | -លោកស្រី | វ៉ាយ សុផល | ក្រឡាបញ្ជី នៃសាលាដំបូងរាជធានីភ្នំពេញ |
| ២៣ | -លោក | សេង ស | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកណ្តាល |
| ២៤ | -លោក | សាយ វៃ | ក្រឡាបញ្ជី នៃអយ្យការអមសាលាដំបូងខេត្តកណ្តាល |
| ២៥ | -លោក | ឯន សារ៉េត | ក្រឡាបញ្ជី នៃអយ្យការអមសាលាដំបូងខេត្តកណ្តាល |
| ២៦ | -លោក | ម៉ែន ណូវ៉ា | ក្រឡាបញ្ជី នៃអយ្យការអមសាលាដំបូងខេត្តកំពង់ចាម |
| ២៧ | -លោក | អេង ម៉េងឈៀង | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកំពង់ឆ្នាំង |
| ២៨ | -លោក | មាំង ហ៊ីង | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកំពង់ឆ្នាំង |
| ២៩ | -លោក | ឡុច សាមីឌី | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកំពង់ឆ្នាំង |
| ៣០ | -លោក | ឡាង ធៀង | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកំពង់ឆ្នាំង |
| ៣១ | -លោកស្រី | សំ ស៊ីណា | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកំពង់ឆ្នាំង |
| ៣២ | -លោក | ហេង សាម៉ន | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកំពង់ឆ្នាំង |
| ៣៣ | -លោក | នូ ធីរុន | ក្រឡាបញ្ជី នៃអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង |
| ៣៤ | -លោក | អ៊ូច ជ្រិន | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកោះកុង |
| ៣៥ | -លោក | សឹន សៀ | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកោះកុង |
| ៣៦ | -លោកស្រី | ម៉ិច សុជាតា | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកោះកុង |
| ៣៧ | -លោកស្រី | រិទ្ធ សីហា | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកោះកុង |
| ៣៨ | -លោក | ជា ចំរ៉ុង | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកោះកុង |
| ៣៩ | -លោក | ប្រាក់ សារ៉េត | ក្រឡាបញ្ជី នៃអយ្យការអមសាលាដំបូងខេត្តកោះកុង |
| ៤០ | -លោក | អ៊ី រិទ្ធ | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តបន្ទាយមានជ័យ |
| ៤១ | -លោកស្រី | ហ៊ូ លីសុភាព៉ | មន្ត្រីគ្រប់គ្រងរដ្ឋបាល នៃនាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ |
| ៤២ | -លោកស្រី | សំអឿន ធីតា | មន្ត្រីគ្រប់គ្រងរដ្ឋបាល នៃនាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ |

| | | | |
|---|---|---|---|
| ៤៣ | -លោកស្រី | ឈិន ចរិយា | មន្ត្រីក្រមការ នៃនាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ |
| ៤៤ | -លោកស្រី | ទី សុភាព | មន្ត្រីក្រមការ នៃនាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ |
| ៤៥ | -លោក | មៀង សយ | មន្ត្រីក្រមការ នៃសាលាដំបូងខេត្តបន្ទាយមានជ័យ |

**ខ-មេដាយប្រាក់ការងារ**

| | | | |
|---|---|---|---|
| ១ | -លោកស្រី | ពាវ សុរម្យ | ប្រធានការិយាល័យ នៃនាយកដ្ឋានកិច្ចការហិរញ្ញវត្ថុ |
| ២ | -លោកស្រី | ពម នារតី | ប្រធានការិយាល័យ នៃនាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ |
| ៣ | -លោក | ស្វ សារិន | ប្រធានការិយាល័យ នៃនាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ |
| ៤ | -លោក | ហួន វណ្ណហាន | អនុប្រធានការិយាល័យ នៃនាយកដ្ឋានកិច្ចការនីតិកម្ម |
| ៥ | -លោក | លី វ៉ាន់ហេង | ក្រឡាបញ្ជី នៃសាលាដំបូងរាជធានីភ្នំពេញ |
| ៦ | -លោក | ស៊ុន ប៉ែត | ក្រឡាបញ្ជី នៃសាលាដំបូងរាជធានីភ្នំពេញ |
| ៧ | -លោក | នឹម ធារ៉ា | ក្រឡាបញ្ជី នៃសាលាដំបូងរាជធានីភ្នំពេញ |
| ៨ | -លោក | បាន វ៉ាត | ក្រឡាបញ្ជី នៃសាលាដំបូងរាជធានីភ្នំពេញ |
| ៩ | -លោក | អ៊ុច សុខា | ក្រឡាបញ្ជី នៃសាលាដំបូងរាជធានីភ្នំពេញ |
| ១០ | -លោក | ហេង ម៉េងហួ | ក្រឡាបញ្ជី នៃសាលាដំបូងរាជធានីភ្នំពេញ |
| ១១ | -លោក | ជោត វ៉ាន់ចាន់ | ក្រឡាបញ្ជី នៃសាលាដំបូងរាជធានីភ្នំពេញ |
| ១២ | -លោកស្រី | ចន្ទ សុភា | ក្រឡាបញ្ជី នៃសាលាដំបូងរាជធានីភ្នំពេញ |
| ១៣ | -លោកស្រី | អ៊ូ គាវ៉ាន់ | ក្រឡាបញ្ជី នៃសាលាដំបូងរាជធានីភ្នំពេញ |
| ១៤ | -លោកស្រី | ធន់ វណ្ណធឿន | ក្រឡាបញ្ជី នៃសាលាដំបូងរាជធានីភ្នំពេញ |
| ១៥ | -លោក | ជា ប៊ុននាង | ក្រឡាបញ្ជី នៃសាលាដំបូងរាជធានីភ្នំពេញ |
| ១៦ | -លោក | វ៉េង ជូហ៊ុត | ក្រឡាបញ្ជី នៃសាលាដំបូងរាជធានីភ្នំពេញ |
| ១៧ | -លោកស្រី | លន់ ស៊ីធូ | ក្រឡាបញ្ជី នៃសាលាដំបូងរាជធានីភ្នំពេញ |
| ១៨ | -លោក | ស៊ូ សុទ្ធី | ក្រឡាបញ្ជី នៃសាលាដំបូងរាជធានីភ្នំពេញ |
| ១៩ | -លោកស្រី | ទិន សុធាមុនី | ក្រឡាបញ្ជី នៃសាលាដំបូងរាជធានីភ្នំពេញ |
| ២០ | -លោកស្រី | ជា បញ្ញា | ក្រឡាបញ្ជី នៃសាលាដំបូងរាជធានីភ្នំពេញ |
| ២១ | -លោក | សុក ប៊ុន្នី | ក្រឡាបញ្ជី នៃសាលាដំបូងរាជធានីភ្នំពេញ |
| ២២ | -លោកស្រី | ខេន សុខន | ក្រឡាបញ្ជី នៃសាលាដំបូងរាជធានីភ្នំពេញ |
| ២៣ | -លោកស្រី | នង ស្រីមុំយ | ក្រឡាបញ្ជី នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ |
| ២៤ | -លោក | ឡាច បុជា | ក្រឡាបញ្ជី នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ |
| ២៥ | -លោក | ឌិក យូវ៉ាន់ | ក្រឡាបញ្ជី នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ |
| ២៦ | -លោក | សុខ សាត | ក្រឡាបញ្ជី នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ |
| ២៧ | -លោក | ឈារ ស៊ីវុត្ថា | ក្រឡាបញ្ជី នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ |
| ២៨ | -លោក | នូ សារិ | ក្រឡាបញ្ជី នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ |
| ២៩ | -លោក | ជាន់ ពិសិដ្ឋ | ក្រឡាបញ្ជី នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ |
| ៣០ | -លោក | ហាង វុទ្ធី | ក្រឡាបញ្ជី នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ |

| | | | |
|---|---|---|---|
| ៣១ | -លោក | ហុង សុធី | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកណ្ដាល |
| ៣២ | -លោក | អ៊ឹង ងួនសា | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកណ្ដាល |
| ៣៣ | -លោក | មាស ស្អាង | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកណ្ដាល |
| ៣៤ | -លោកស្រី | ឯក តារា | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកណ្ដាល |
| ៣៥ | -លោក | គង់ វិបុល | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកណ្ដាល |
| ៣៦ | -លោក | អ៊ុំ ស្រី | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកណ្ដាល |
| ៣៧ | -លោក | ទេព សុវាត្ថិ | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកណ្ដាល |
| ៣៨ | -លោក | ជូ ចាន់ធីរ៉ា | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកណ្ដាល |
| ៣៩ | -លោក | ហេង សុវណ្ណ | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកណ្ដាល |
| ៤០ | -លោក | ថន ផល | ក្រឡាបញ្ជី នៃអយ្យការអមសាលាដំបូងខេត្តកណ្ដាល |
| ៤១ | -លោក | យ៉ាន ណារ៉ា | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តបាត់ដំបង |
| ៤២ | លោក | ប៉ោ សុកនី | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តបាត់ដំបង |
| ៤៣ | -លោកស្រី | ព្រំ ខីផាណេត | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តបាត់ដំបង |
| ៤៤ | -លោក | កុំ សូភី | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តសៀមរាប |
| ៤៥ | -លោក | ឃឹង សុជាថា | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តសៀមរាប |
| ៤៦ | -លោក | អ៊ី ស៊ីប៉ូ | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តសៀមរាប |
| ៤៧ | -លោកស្រី | ឈារ ប៊ុនណារី | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តសៀមរាប |
| ៤៨ | -លោកស្រី | ឈុន លក្ខិណា | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តសៀមរាប |
| ៤៩ | -លោក | អឿន សំអាត | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តសៀមរាប |
| ៥០ | -លោក | កែវ វី | ក្រឡាបញ្ជី នៃអយ្យការអមសាលាដំបូងខេត្តសៀមរាប |
| ៥១ | -លោក | តូច សារ៉ា | ក្រឡាបញ្ជី នៃអយ្យការអមសាលាដំបូងខេត្តសៀមរាប |
| ៥២ | -លោក | ទេព ផល្លា | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តស្វាយរៀង |
| ៥៣ | -លោក | ម៉ុញ សារ៉េន | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តស្វាយរៀង |
| ៥៤ | -លោក | សូ សីហា | ក្រឡាបញ្ជី នៃអយ្យការអមសាលាដំបូងខេត្តស្វាយរៀង |
| ៥៥ | -លោក | ជា សារ៉េន | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកំពង់ឆ្នាំង |
| ៥៦ | -លោក | ម៉ម សេនាឫទ្ធី | ក្រឡាបញ្ជី នៃអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង |
| ៥៧ | -លោក | ញ៉េប ចន្ថា | ក្រឡាបញ្ជី នៃអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង |
| ៥៨ | -លោក | គុយ ជិ | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកំពត |
| ៥៩ | -លោក | កន នឿងសារ៉ាវុធ | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកំពត |
| ៦០ | -លោកស្រី | ឃិន សុធី | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកំពត |
| ៦១ | -លោក | ចៅ ឃីម | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកំពត |
| ៦២ | -លោក | សេង គឹមសួ | មន្ត្រីគ្រប់គ្រងរដ្ឋបាល នៃនាយកដ្ឋានកិច្ចការបុគ្គលិក |
| ៦៣ | -លោកស្រី | គិន ចន្ថា | មន្ត្រីក្រមការ នៃសាលាដំបូងខេត្តកំពត |
| ៦៤ | -លោក | ហៃល ឆេងហុង | មន្ត្រីក្រមការ នៃសាលាដំបូងខេត្តឧត្ដរមានជ័យ |

| | | | |
|---|---|---|---|
| ៦៥ | -លោក | ប៊ុន ពិសិដ្ឋ | លេខាធិការរដ្ឋបាល នៃនាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ |
| ៦៦ | -លោក | គង់ ឈឿន | ភ្នាក់ងាររដ្ឋបាល នៃសាលាដំបូងខេត្តកំពត |
| ៦៧ | -លោក | ងួន កក្កដា | ភ្នាក់ងាររដ្ឋបាល នៃសាលាដំបូងខេត្តកំពត |
| ៦៨ | -លោក | យុត រតនៈ | ភ្នាក់ងាររដ្ឋបាល នៃសាលាដំបូងខេត្តប៉ៃលិន |

**គ-មេដាយសំរឹទ្ធិការងារ**

| | | | |
|---|---|---|---|
| ១ | -លោក | ផ្ទង ប្រុស | ប្រធានការិយាល័យ នៃនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី |
| ២ | -លោកស្រី | កែប សុខេម៉ា | អនុប្រធានការិយាល័យ នៃនាយកដ្ឋានកិច្ចការហិរញ្ញវត្ថុ |
| ៣ | -លោកស្រី | ឡាយ លីនណា | អនុប្រធានការិយាល័យ នៃនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី |
| ៤ | -លោក | ឡុង សុជាតិ | ក្រឡាបញ្ជី នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ |
| ៥ | -លោកស្រី | ជា ដាវីន | ក្រឡាបញ្ជី នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ |
| ៦ | -លោក | សោម វិរៈ | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកណ្តាល |
| ៧ | -លោកស្រី | ថូ រតនា | ក្រឡាបញ្ជី នៃអយ្យការអមសាលាដំបូងខេត្តកណ្តាល |
| ៨ | -លោក | ថា សាម្មុនី | ក្រឡាបញ្ជី នៃអយ្យការអមសាលាដំបូងខេត្តកំពង់ចាម |
| ៩ | -លោក | រ៉េត សារិន | ក្រឡាបញ្ជី នៃអយ្យការអមសាលាដំបូងខេត្តកំពង់ចាម |
| ១០ | -លោក | ឃិន វិទូរ្យ | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តបាត់ដំបង |
| ១១ | -លោក | សន តុលា | ក្រឡាបញ្ជី នៃអយ្យការអមសាលាដំបូងខេត្តសៀមរាប |
| ១២ | -លោក | ហ៊ីវ សុភា | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តស្វាយរៀង |
| ១៣ | -លោកស្រី | ឯម ស្រីធា | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកំពង់ឆ្នាំង |
| ១៤ | -លោក | មាស សុគន្ធា | ក្រឡាបញ្ជី នៃអយ្យការអមសាលាដំបូងខេត្តរតនគិរី |
| ១៥ | -លោកស្រី | អៀង គឹមណម | ក្រឡាបញ្ជី នៃអយ្យការអមសាលាដំបូងខេត្តស្ទឹងត្រែង |
| ១៦ | -លោក | ខាន់ សុខា | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តប៉ៃលិន |
| ១៧ | -លោកស្រី | ឌី លីឡា | ក្រឡាបញ្ជី នៃសាលាដំបូងខេត្តប៉ៃលិន |
| ១៨ | -លោកស្រី | ឈុំ សុគន្ធា | មន្ត្រីគ្រប់គ្រងរដ្ឋបាល នៃនាយកដ្ឋានកិច្ចការហិរញ្ញវត្ថុ |
| ១៩ | -លោក | ម៉ែន ចំណាន | មន្ត្រីគ្រប់គ្រងរដ្ឋបាល នៃនាយកដ្ឋានកិច្ចការហិរញ្ញវត្ថុ |
| ២០ | -លោក | កែវ លីគង់ | មន្ត្រីគ្រប់គ្រងរដ្ឋបាល នៃនាយកដ្ឋានកិច្ចការបុគ្គលិក |
| ២១ | -លោក | ផុន ចាន់សុធា | មន្ត្រីគ្រប់គ្រងរដ្ឋបាល នៃនាយកដ្ឋានកិច្ចការអយ្យការ |
| ២២ | -លោក | ខាត់ ច័ន្ទណា | មន្ត្រីគ្រប់គ្រងរដ្ឋបាល នៃនាយកដ្ឋានកិច្ចការអយ្យការ |
| ២៣ | -លោក | លាំង គន្ធី | មន្ត្រីគ្រប់គ្រងរដ្ឋបាល នៃនាយកដ្ឋានកិច្ចការអយ្យការ |
| ២៤ | -លោក | ខៀវ ទិត្យវណ្ណៈ | មន្ត្រីគ្រប់គ្រងរដ្ឋបាល នៃនាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ |
| ២៥ | -លោកស្រី | សុន ស្រីពៅ | មន្ត្រីគ្រប់គ្រងរដ្ឋបាល នៃនាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ |
| ២៦ | -លោកស្រី | ឈឹម ដាវី | មន្ត្រីគ្រប់គ្រងរដ្ឋបាល នៃនាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ |
| ២៧ | -លោក | ពុត្រ រតនៈ | មន្ត្រីគ្រប់គ្រងរដ្ឋបាល នៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| ២៨ | -លោក | ហួយ សេរីវឌ្ឍនពិសិដ្ឋ | មន្ត្រីគ្រប់គ្រងរដ្ឋបាល នៃសាលាដំបូងរាជធានីភ្នំពេញ |
| ២៩ | -លោក | ផាន់ វ័ឌ្ឍវិត្យា | មន្ត្រីគ្រប់គ្រងរដ្ឋបាល នៃសាលាដំបូងរាជធានីភ្នំពេញ |

| | | | |
|---|---|---|---|
| ៣០ | -លោក | លី ចាន់ដាវ៉ា | មន្ត្រីគ្រប់គ្រងរដ្ឋបាល នៃសាលាដំបូងរាជធានីភ្នំពេញ |
| ៣១ | -លោក | ធា វ៉ាដេត | លេខាធិការរដ្ឋបាល នៃនាយកដ្ឋានកិច្ចការបុគ្គលិក |
| ៣២ | -លោកស្រី | នួន ស៊ីវត្ថា | លេខាធិការរដ្ឋបាល នៃអយ្យការអមសាលាដំបូងខេត្តស្ទឹងត្រែង |

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**កន្លែងទទួលៈ**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ៤ ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣៧៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងមុខងារសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១.-** ត្រូវបានដាក់មន្ត្រីរាជការ ចំនួន ០២ រូប របស់ក្រសួងមុខងារសាធារណៈ ដែលបានដល់អាយុឱ្យចូលនិវត្តន៍ ក្នុងឋានន្តរស័ក្តិវរមន្ត្រីនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ដូចមានរាយនាមខាងក្រោម ៖

| ល.រ | គោត្តនាម និងនាម | មុខតំណែង | ឋានន្តរស័ក្តិ និងថ្នាក់ | ថ្ងៃ-ខែ-ឆ្នាំ ចូលនិវត្តន៍ |
|---|---|---|---|---|
| ១ | លោក **អ៊ុន ព្រំ** | អនុប្រធាននាយកដ្ឋាន | វរមន្ត្រី ថ្នាក់លេខ ៥ | ០១-០៦-២០១៤ |
| ២ | លោក **ជួប សុផាន** | អគ្គាធិការរង | វរមន្ត្រី ថ្នាក់លេខ ២ | ០១-១០-២០១៤ |

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ៤ ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា "២"*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៣៧៧..អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង

## សម្រេច

**មាត្រា ១.**. បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនសប្បុរសជន នៅក្នុងនិងក្រៅប្រទេស ចំនួន០៧រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានាជាច្រើន នៅក្នុងពុទ្ធសីមាវត្តសន្សំកុសលមានរិទ្ធ ហៅវត្តព្រៃប្រង់ ស្ថិតនៅឃុំស្តៅខ ស្រុកបាភ្នំ ខេត្តព្រៃវែង ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-លោកយាយ | **កែវ វណ្ណា** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន៦០.២៥០ ដុល្លារ |
| ២-លោកយាយ | **ទ៉ាន់ ណារី** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន៥១.០០០ ដុល្លារ |
| ៣-លោកយាយ | **គៀត គីមស៊ីន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន៥០.៧០០ ដុល្លារ |
| ៤-លោកយាយ | **តាំង ស៊ួហេង** | សប្បុរសជននៅប្រទេសកាណាដា | ថវិកាចំនួន៥០.៥៥០ ដុល្លារ |
| ៥-លោក | **ហង្ស ប៊ុនហេង** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន៥០.៤០០ ដុល្លារ |
| ៦-លោក | **ស៊ាវ ស៊ុនហេង** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន៥០.១០០ ដុល្លារ |
| ៧-អ្នកស្រី | **កៅ អរុណរដ្ឋ** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន៥០.០៥០ ដុល្លារ |

**មាត្រា២.**. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ [illegible] ឆ្នាំ ២០១៤
នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៣៧៥ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់គំរូឯកសារដេញថ្លៃ ពិគ្រោះថ្លៃ និងស្ទង់តម្លៃ សម្រាប់លទ្ធកម្មទំនិញ និងសំណង់

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ
- តាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ១.-**

ត្រូវបានដាក់ឱ្យប្រើប្រាស់នូវកម្រងគំរូឯកសារដេញថ្លៃ ពិគ្រោះថ្លៃ និងស្ទង់តម្លៃ សម្រាប់លទ្ធកម្មទំនិញ និងសំណង់។

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៣.-**

រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រធានសហគ្រាសសាធារណៈ ប្រធានគ្រឹះស្ថានសាធារណៈរដ្ឋបាល និងប្រធានអង្គភាពចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៤

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ដូចក្នុងប្រការ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កម្រងគំរូឯកសារ
# ដេញថ្លៃ ពិគ្រោះថ្លៃ និងស្ទង់តម្លៃ
# សម្រាប់លទ្ធកម្មទំនិញ និងសំណង់

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ឆ្នាំ២០១៤**

# គំរូឯកសារដេញថ្លៃ ពិគ្រោះថ្លៃ និងស្ទង់តម្លៃ
# សម្រាប់លទ្ធកម្មទំនិញ និងសំណង់

## មាតិកា

| ល.រ | បរិយាយ | ទំព័រ |
|---|---|---|
| ១ | ឯកសារដេញថ្លៃប្រកួតប្រជែងជាសាធារណៈស្តីពីការផ្គត់ផ្គង់....(លទ្ធកម្មទំនិញ) | ១ |
| | -សេចក្តីជូនដំណឹងស្តីពីការអញ្ជើញចូលរួមដេញថ្លៃ | ៣ |
| | -សេចក្តីណែនាំចំពោះអ្នកដេញថ្លៃ | ៤ |
| | -លក្ខខណ្ឌនៃកិច្ចសន្យា | ១១ |
| | -ពាក្យសុំដេញថ្លៃ | ១៧ |
| | -សេចក្តីប្រកាសស្តីពីក្រមសីលធម៌លទ្ធកម្មរបស់អ្នកដេញថ្លៃ | ១៨ |
| | -តារាងតម្លៃ និងបញ្ជាក់លក្ខណៈបច្ចេកទេស | ១៩ |
| | -ទម្រង់លិខិតធានាប្រាក់កក់ធានាការដេញថ្លៃ | ២០ |
| | -ទម្រង់លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា | ២១ |
| | -បញ្ជីឈ្មោះអ្នកទិញឯកសារដេញថ្លៃ | ២២ |
| | -បញ្ជីឈ្មោះអ្នកដាក់សំណើដេញថ្លៃ | ២៣ |
| | -បញ្ជីវត្តមានអ្នកចូលរួមបើកសំណើដេញថ្លៃ | ២៤ |
| | -កំណត់ហេតុបើកសំណើដេញថ្លៃ | ២៥ |
| | -សេចក្តីប្រកាសស្តីពីក្រមសីលធម៌លទ្ធកម្មរបស់គណៈកម្មាធិការលទ្ធកម្ម | ២៧ |
| | -កំណត់ហេតុវាយតម្លៃប្រគល់កិច្ចសន្យា | ២៨ |
| | -លិខិតសម្រេច ប្រគល់កិច្ចសន្យា | ៣៣ |
| | -លិខិតអញ្ជើញចុះកិច្ចសន្យា | ៣៤ |
| | -ទម្រង់ឯកសារកិច្ចសន្យា | ៣៥ |
| | -កំណត់ហេតុប្រគល់ ទទួល | ៤២ |
| ២ | ឯកសារពិគ្រោះថ្លៃស្តីពីការផ្គត់ផ្គង់........(លទ្ធកម្មទំនិញ) | ៤៤ |
| | -សេចក្តីជូនដំណឹងស្តីពីការអញ្ជើញចូលរួមពិគ្រោះថ្លៃ | ៤៦ |
| | -សេចក្តីណែនាំចំពោះអ្នកពិគ្រោះថ្លៃ | ៤៧ |
| | -លក្ខខណ្ឌនៃកិច្ចសន្យា | ៥៤ |
| | -ពាក្យសុំពិគ្រោះថ្លៃ | ៥៩ |
| | -សេចក្តីប្រកាសស្តីពីក្រមសីលធម៌លទ្ធកម្មរបស់អ្នកពិគ្រោះថ្លៃ | ៦០ |
| | -តារាងតម្លៃ និងបញ្ជាក់លក្ខណៈបច្ចេកទេស | ៦១ |
| | -ទម្រង់លិខិតធានាប្រាក់កក់ធានាការដេញថ្លៃ | ៦២ |

| | | |
|---|---|---|
| | -ទម្រង់លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា | ៦៣ |
| | -បញ្ជីឈ្មោះអ្នកទិញឯកសារពិគ្រោះថ្លៃ | ៦៤ |
| | -បញ្ជីឈ្មោះអ្នកដាក់សំណើពិគ្រោះថ្លៃ | ៦៥ |
| | -បញ្ជីវត្តមានអ្នកចូលរួមបើកសំណើពិគ្រោះថ្លៃ | ៦៦ |
| | -កំណត់ហេតុបើកសំណើពិគ្រោះថ្លៃ | ៦៧ |
| | -សេចក្តីប្រកាសស្តីពីក្រមសីលធម៌លទ្ធកម្មរបស់គណៈកម្មាធិការលទ្ធកម្ម | ៦៩ |
| | -កំណត់ហេតុវាយតម្លៃប្រគល់កិច្ចសន្យា | ៧០ |
| | -លិខិតសម្រេច ប្រគល់កិច្ចសន្យា | ៧៤ |
| | -លិខិតអញ្ជើញចុះកិច្ចសន្យា | ៧៥ |
| | -ទម្រង់ឯកសារកិច្ចសន្យា | ៧៦ |
| | -កំណត់ហេតុប្រគល់ ទទួល | ៨២ |
| ៣ | **ឯកសារស្នងតម្លៃស្តីពីការផ្គត់ផ្គង់............(លទ្ធកម្មទំនិញ)** | ៨៤ |
| | -សេចក្តីជូនដំណឹងស្តីពីការអញ្ជើញចូលរួមស្នងតម្លៃ | ៨៦ |
| | -សេចក្តីណែនាំចំពោះអ្នកស្នងតម្លៃ | ៨៧ |
| | -ពាក្យសុំស្នងតម្លៃ | ៩០ |
| | -សេចក្តីប្រកាសស្តីពីក្រមសីលធម៌លទ្ធកម្មរបស់អ្នកស្នងតម្លៃ | ៩១ |
| | -តារាងតម្លៃ និងបញ្ជាក់លក្ខណៈបច្ចេកទេស | ៩២ |
| | -បញ្ជីឈ្មោះអ្នកទទួលឯកសារស្នងតម្លៃ | ៩៣ |
| | -បញ្ជីឈ្មោះអ្នកដាក់សំណើស្នងតម្លៃ | ៩៤ |
| | -បញ្ជីវត្តមានអ្នកចូលរួមបើកសំណើស្នងតម្លៃ | ៩៥ |
| | -កំណត់ហេតុបើកសំណើស្នងតម្លៃ | ៩៦ |
| | -សេចក្តីប្រកាសស្តីពីក្រមសីលធម៌លទ្ធកម្មរបស់គណៈកម្មាធិការលទ្ធកម្ម | ៩៩ |
| | -កំណត់ហេតុវាយតម្លៃប្រគល់កិច្ចសន្យា | ១០០ |
| | -លិខិតសម្រេច ប្រគល់កិច្ចសន្យា | ១០៣ |
| | -លិខិតអញ្ជើញចុះកិច្ចសន្យា | ១០៤ |
| | -ទម្រង់ឯកសារកិច្ចសន្យា | ១០៥ |
| | -កំណត់ហេតុប្រគល់ ទទួល | ១០៩ |
| ៤ | **ឯកសារដេញថ្លៃប្រកួតប្រជែងជាសាធារណៈស្តីពីការងារសាងសង់/ជួសជុល....(លទ្ធកម្មសំណង់)** | ១១១ |
| | -សេចក្តីជូនដំណឹងស្តីពីការអញ្ជើញចូលរួមដេញថ្លៃ | ១១៣ |
| | -សេចក្តីណែនាំចំពោះអ្នកដេញថ្លៃ | ១១៥ |
| | -លក្ខខណ្ឌនៃកិច្ចសន្យា | ១[illegible] |
| | -គំនូសប្លង់ | ១២៩ |

| | | |
|---|---|---|
| | -លម្អិតលក្ខណៈបច្ចេកទេស | ១៣០ |
| | -ពាក្យសុំដេញថ្លៃ | ១៣១ |
| | -សេចក្តីប្រកាសស្តីពីក្រមសីលធមិលទ្ធកម្មរបស់អ្នកដេញថ្លៃ | ១៣២ |
| | -បញ្ជីប៉ាន់តម្លៃ "សរុប ពលកម្ម សម្ភារៈ" | ១៣៣ |
| | -ទម្រង់លិខិតធានាប្រាក់កក់ធានាការដេញថ្លៃ | ១៣៧ |
| | -ទម្រង់លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា | ១៣៨ |
| | -បញ្ជីឈ្មោះអ្នកទិញឯកសារដេញថ្លៃ | ១៣៩ |
| | -បញ្ជីឈ្មោះអ្នកដាក់សំណើដេញថ្លៃ | ១៤០ |
| | -បញ្ជីវត្តមានអ្នកចូលរួមបើកសំណើដេញថ្លៃ | ១៤១ |
| | -កំណត់ហេតុបើកសំណើដេញថ្លៃ | ១៤២ |
| | -សេចក្តីប្រកាសស្តីពីក្រមសីលធមិលទ្ធកម្មរបស់គណៈកម្មាធិការលទ្ធកម្ម | ១៤៤ |
| | -កំណត់ហេតុវាយតម្លៃប្រគល់កិច្ចសន្យា | ១៤៥ |
| | -លិខិតសម្រេច ប្រគល់កិច្ចសន្យា | ១៤៩ |
| | -លិខិតអញ្ជើញចុះកិច្ចសន្យា | ១៥០ |
| | -ទម្រង់ឯកសារកិច្ចសន្យា | ១៥១ |
| | -កំណត់ហេតុប្រគល់ ទទួល | ១៥៩ |
| ៥ | ឯកសារពិគ្រោះថ្លៃស្តីពីការងារសាងសង់/ជួសជុល....(លទ្ធកម្មសំណង់) | ១៦២ |
| | -សេចក្តីជូនដំណឹងស្តីពីការអញ្ជើញចូលរួមពិគ្រោះថ្លៃ | ១៦៤ |
| | -សេចក្តីណែនាំចំពោះអ្នកពិគ្រោះថ្លៃ | ១៦៥ |
| | -លក្ខខណ្ឌនៃកិច្ចសន្យា | ១៧២ |
| | -គំនូសប្លង់ | ១៧៨ |
| | -លម្អិតលក្ខណៈបច្ចេកទេស | ១៧៩ |
| | -ពាក្យសុំពិគ្រោះថ្លៃ | ១៨០ |
| | -សេចក្តីប្រកាសស្តីពីក្រមសីលធមិលទ្ធកម្មរបស់អ្នកពិគ្រោះថ្លៃ | ១៨១ |
| | -បញ្ជីប៉ាន់តម្លៃ "សរុប ពលកម្ម សម្ភារៈ" | ១៨២ |
| | -ទម្រង់លិខិតធានាប្រាក់កក់ធានាការដេញថ្លៃ | ១៨៦ |
| | -ទម្រង់លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា | ១៨៧ |
| | -បញ្ជីឈ្មោះអ្នកទិញឯកសារពិគ្រោះថ្លៃ | ១៨៨ |
| | -បញ្ជីឈ្មោះអ្នកដាក់សំណើពិគ្រោះថ្លៃ | ១៨៩ |
| | -បញ្ជីវត្តមានអ្នកចូលរួមបើកសំណើពិគ្រោះថ្លៃ | ១៩០ |
| | -កំណត់ហេតុបើកសំណើពិគ្រោះថ្លៃ | ១៩២ |
| | -សេចក្តីប្រកាសស្តីពីក្រមសីលធមិលទ្ធកម្មរបស់គណៈកម្មាធិការលទ្ធកម្ម | ១៩៣ |
| | -កំណត់ហេតុវាយតម្លៃប្រគល់កិច្ចសន្យា | [illegible] |

| | | |
|---|---|---|
| | -លិខិតសម្រេច ប្រគល់កិច្ចសន្យា | ១៩៨ |
| | -លិខិតអញ្ជើញចុះកិច្ចសន្យា | ១៩៩ |
| | -ទម្រង់ឯកសារកិច្ចសន្យា | ២០០ |
| | -កំណត់ហេតុប្រគល់ ទទួល | ២០៧ |
| ៦ | **ឯកសារស្នង់តម្លៃស្តីពីការងារសាងសង់/ជួសជុល....(លទ្ធកម្មសំណង់)** | ២១០ |
| | -សេចក្តីជូនដំណឹងស្តីពីការអញ្ជើញចូលរួមស្នង់តម្លៃ | ២១២ |
| | -សេចក្តីណែនាំចំពោះអ្នកស្នង់តម្លៃ | ២១៣ |
| | -គំនូសប្លង់ | ២១៥ |
| | -លម្អិតលក្ខណៈបច្ចេកទេស | ២១៦ |
| | -ពាក្យសុំស្នង់តម្លៃ | ២១៧ |
| | -សេចក្តីប្រកាសស្តីពីក្រមសីលធមិលទ្ធកម្មរបស់អ្នកស្នង់តម្លៃ | ២១៨ |
| | -បញ្ជីប៉ាន់តម្លៃ "សរុប ពលកម្ម សម្ភារៈ" | ២១៩ |
| | -បញ្ជីឈ្មោះអ្នកទទួលឯកសារស្នង់តម្លៃ | ២២៣ |
| | -បញ្ជីឈ្មោះអ្នកដាក់សំណើស្នង់តម្លៃ | ២២៤ |
| | -បញ្ជីវត្តមានអ្នកចូលរួមបើកសំណើស្នង់តម្លៃ | ២២៥ |
| | -កំណត់ហេតុបើកសំណើស្នង់តម្លៃ | ២២៦ |
| | -សេចក្តីប្រកាសស្តីពីក្រមសីលធមិលទ្ធកម្មរបស់គណៈកម្មាធិការលទ្ធកម្ម | ២២៩ |
| | -កំណត់ហេតុវាយតម្លៃប្រគល់កិច្ចសន្យា | ២៣០ |
| | -លិខិតសម្រេច ប្រគល់កិច្ចសន្យា | ២៣៣ |
| | -លិខិតអញ្ជើញចុះកិច្ចសន្យា | ២៣៤ |
| | -ទម្រង់ឯកសារកិច្ចសន្យា | ២៣៥ |
| | -កំណត់ហេតុប្រគល់ ទទួល | ២៤០ |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង/ស្ថាប័ន/រាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ....**
**លេខ :** ................................

# ឯកសារដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈ
## ស្ដីពី
## ការផ្គត់ផ្គង់.........................

**ឈ្មោះក្រុមហ៊ុន/សហគ្រាស :** ..................................................................
**អាសយដ្ឋានទាក់ទង :** ..................................................................
..................................................................
**ទូរស័ព្ទ :** ........................................... **ទូរសារ :** ........................................
**គេហទំព័រ :** ..................................................................

កាលបរិច្ឆេទទទួលសំណើដេញថ្លៃ រៀងរាល់ម៉ោងធ្វើការ ចាប់ពីថ្ងៃទី ............ ខែ .............. ឆ្នាំ..........
កាលបរិច្ឆេទឈប់ទទួល និងបើកសំណើដេញថ្លៃ នៅម៉ោង ............... ថ្ងៃទី ........... ខែ ............ ឆ្នាំ

# មាតិកា


| ល.រ | បរិយាយ | ទំព័រ |
|---|---|---|
| ១. | សេចក្តីជូនដំណឹងស្តីពីការអញ្ជើញចូលរួមដេញថ្លៃ | |
| ២. | សេចក្តីណែនាំចំពោះអ្នកដេញថ្លៃ | |
| ៣. | លក្ខខណ្ឌនៃកិច្ចសន្យា | |
| ៤. | ពាក្យសុំដេញថ្លៃ (ឧបសម្ព័ន្ធទី១) | |
| ៥. | តារាងតម្លៃ និងបញ្ជាក់លក្ខណៈបច្ចេកទេស (ឧបសម្ព័ន្ធទី២) | |
| ៦. | សេចក្តីប្រកាសស្តីពីក្រមសីលធម៌លទ្ធកម្មរបស់អ្នកដេញថ្លៃ | |
| ៧. | ប៉ាន់គំរូ កាតាឡុក | |
| ៨. | ទម្រង់លិខិតធានាប្រាក់កក់ធានាការដេញថ្លៃ (ឧបសម្ព័ន្ធទី៣) | |
| ៩. | ទម្រង់លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា (ឧបសម្ព័ន្ធទី៤) | |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង/ស្ថាប័ន/រាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ....**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ : ...............................

# សេចក្តីជូនដំណឹង
## ស្តីពី

ការអញ្ជើញចូលរួមដេញថ្លៃការផ្គត់ផ្គង់...........................

ក្រសួង/ស្ថាប័ន/រាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ...................... សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា ក្រសួង/ស្ថាប័ន/រាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ............ នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីផ្គត់ផ្គង់................ ។

ក្រសួង/ស្ថាប័ន/រាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ.................. បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាស បំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មក្រសួង/ស្ថាប័ន/រាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ...... ដែលមានអាសយដ្ឋាន.........................ចាប់ពីថ្ងៃទី ............ ខែ ...............ឆ្នាំ ............... តទៅ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ.................. ) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង.......... ថ្ងៃទី............ ខែ.................... ឆ្នាំ...............។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង............ ថ្ងៃទី .............. ខែ ...................... ឆ្នាំ.................... ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ធ្វើនៅ ................ ថ្ងៃទី ............. ខែ ............. ឆ្នាំ .............

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

ចម្លងជូន ៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-......

# សេចក្តីណែនាំចំពោះអ្នកដេញថ្លៃ

**១- វិសាលភាព**

ក្រសួង/ស្ថាប័ន/រាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ............ មានបំណងដាក់ឱ្យដេញថ្លៃដើម្បីផ្គត់ផ្គង់.................. តាមវិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈ ដូចមានបរិយាយនៅក្នុងតារាងតម្លៃ និងលក្ខណៈបច្ចេកទេស ក្នុងឯកសារដេញថ្លៃនេះ ។

អ្នកដេញថ្លៃឈ្នះ នឹងត្រូវធ្វើការផ្គត់ផ្គង់ទំនិញ......................... ឱ្យបានចប់សព្វគ្រប់ក្នុងរយៈពេល .......ថ្ងៃ.(សរសេរជាអក្សរ.....) ក្រោយពីកិច្ចសន្យាចូលជាធរមាន ។

**២- ប្រភពឥណទាន**

ប្រភពឥណទានសម្រាប់ការផ្គត់ផ្គង់នេះ បានមកពីថវិការដ្ឋឆ្នាំ............ ។

**៣- សិទ្ធិចូលរួមដេញថ្លៃ**

ការដេញថ្លៃនេះ បើកចំហចំពោះក្រុមហ៊ុន/សហគ្រាសទាំងអស់ គិតទាំងក្រុមហ៊ុនបរទេស ដែលបានចុះបញ្ជីត្រឹមត្រូវនៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែក្រុមហ៊ុន/សហគ្រាសដែលកំពុងស្ថិតក្នុងបញ្ជីខ្មៅ ឬត្រូវបានហាមឃាត់ដោយតុលាការ ។

**៤- សមាសធាតុនៃឯកសារដេញថ្លៃ**

សមាសធាតុនៃឯកសារដេញថ្លៃរួមមាន ៖

១- សេចក្តីជូនដំណឹងស្តីពីការអញ្ជើញចូលរួមដេញថ្លៃ
២- សេចក្តីណែនាំចំពោះអ្នកដេញថ្លៃ
៣- លក្ខខណ្ឌនៃកិច្ចសន្យា
៤- ពាក្យសុំដេញថ្លៃ "បិទតែមប្រិ៍ប្រៃសណីយ៍ ៥.០០០រៀល"
៥- តារាងតម្លៃ និងបញ្ជាក់លក្ខណៈបច្ចេកទេស
៦- ប៉ាន់គំរូ កាតាឡុក
៧- ទម្រង់លិខិតធានាប្រាក់កក់ធានាការដេញថ្លៃ
៨- ទម្រង់លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា

(៤–៨) "ឧបសម្ព័ន្ធត្រូវបំពេញដោយអ្នកដេញថ្លៃ

អ្នកដេញថ្លៃត្រូវយកចិត្តទុកដាក់ពិនិត្យខ្លឹមសារ និងបំពេញឯកសារដេញថ្លៃឱ្យបានម៉ត់ចត់ ហើយសំណើដេញថ្លៃណាដែលមិនឆ្លើយតបសមស្របតាមការតម្រូវ គឺជាបុព្វបទនៃការពិនិត្យពិចារណាបដិសេធ ។

**៥- ឯកសារភ្ជាប់បញ្ជាក់លក្ខណសម្បត្តិអ្នកចូលរួមដេញថ្លៃ**

អ្នកដេញថ្លៃ ត្រូវភ្ជាប់ជាមួយនូវឯកសារភស្តុតាង បង្ហាញពីលក្ខណសម្បត្តិរបស់ខ្លួនដូចខាងក្រោម ៖

- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន (ចម្លងត្រឹមត្រូវតាមច្បាប់ដើម) ០៣ ច្បាប់
- ប័ណ្ណប៉ាតង់ឆ្នាំដេញថ្លៃ (ចម្លងត្រឹមត្រូវតាមច្បាប់ដើម) ០៣ ច្បាប់
- វិញ្ញាបនប័ត្រចុះបញ្ជីអាករលើតម្លៃបន្ថែម អ.ត.ប (ចម្លងត្រឹមត្រូវតាមច្បាប់ដើម) ០៣ ច្បាប់
- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម (ចម្លងត្រឹមត្រូវតាមច្បាប់ដើម) ០៣ ច្បាប់

- ច្បាប់អនុញ្ញាតឱ្យធ្វើអាជីវកម្ម ចេញដោយក្រសួងជំនាញពាក់ព័ន្ធ
  (ចម្លងត្រឹមត្រូវតាមច្បាប់ដើម) ០៣ ច្បាប់
- វិញ្ញាបនប័ត្រចុះបញ្ជីអ្នកផ្គត់ផ្គង់ទំនិញ ចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  (ចម្លងត្រឹមត្រូវតាមច្បាប់ដើម) ០៣ ច្បាប់
- ប៉ាន់គំរូ ឬកាតាឡុក (ប្រសិនបើមាន) ០១ ច្បាប់
- ឯកសារភស្តុតាងសម្រាប់បញ្ជាក់ពីសមត្ថភាព "ហិរញ្ញវត្ថុ បច្ចេកទេស បទពិសោធន៍"
  (ចម្លងត្រឹមត្រូវតាមច្បាប់ដើម) ០៣ ច្បាប់

**៦- សំណើដេញថ្លៃមួយសម្រាប់អ្នកដេញថ្លៃតែមួយគត់**

ក្រុមហ៊ុន/សហគ្រាសដែលមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់ ក្នុងករណីពិនិត្យឃើញថា ក្រុមហ៊ុន/សហគ្រាសដែលបានចូលរួមធ្វើការដេញថ្លៃ ជាក្រុមហ៊ុនមានសម្ពន្ធ័ភាពជាមួយគ្នា ឬមានប្រភពតែមួយ នឹងត្រូវបដិសេធដោយស្វ័យប្រវត្តិ ។

**៧- ភាសា**

អ្នកដេញថ្លៃត្រូវបំពេញសំណើដេញថ្លៃជាភាសាខ្មែរ លើកលែងតែពាក្យបច្ចេកទេសខ្លះដែលត្រូវសរសេរជាភាសាបរទេស ។ ក្នុងករណីចាំបាច់ អាចសរសេរជាភាសាបរទេសដោយត្រូវបកប្រែចេញពីឯកសារដេញថ្លៃជាភាសាខ្មែរ ។ ក្នុងករណីមានខ្លឹមសារមិនស្របគ្នារវាងភាសាខ្មែរ និងភាសាបរទេស ឯកសារដេញថ្លៃជាភាសាខ្មែរ គឺជាឯកសារផ្លូវការ ។

**៨- ពាក្យសុំដេញថ្លៃ**

អ្នកដេញថ្លៃត្រូវបំពេញពាក្យសុំដេញថ្លៃ ដែលបញ្ជាក់ពីការប្តេជ្ញាចិត្តគោរពតាមកិច្ចសន្យា បញ្ជាក់ពីការផ្តល់តារាងតម្លៃសមរម្យ ដែលបានផ្តល់នៅក្នុងសំណើដេញថ្លៃ និងកំណត់ពីមុខទំនិញដែលត្រូវផ្គត់ផ្គង់ដោយបរិយាយច្បាស់លាស់ពីលក្ខណៈបច្ចេកទេស ប្រភព គុណភាព តម្លៃ រយៈពេលប្រគល់ ទទួល ។ល។

**៩- រូបិយប័ណ្ណដាក់ដេញថ្លៃ**

តម្លៃដាក់ដេញថ្លៃត្រូវជារូបិយប័ណ្ណជាតិ (ប្រាក់រៀល) ។ ប្រសិនបើដាក់ជារូបិយប័ណ្ណបរទេស ត្រូវប្តូរជាប្រាក់រៀលតាមអត្រាប្តូរប្រាក់របស់ធនាគារជាតិនាថ្ងៃបើកសំណើដេញថ្លៃ ។

**១០- ការដាក់តម្លៃដេញថ្លៃ**

អ្នកដេញថ្លៃត្រូវពិនិត្យឱ្យបានត្រឹមត្រូវលើតារាងតម្លៃ ដោយពិនិត្យអំពីបរិមាណ តម្លៃឯកតា និងតម្លៃសរុបនៃមុខទំនិញដែលស្នើសុំឱ្យផ្គត់ផ្គង់តាមកិច្ចសន្យា (មើលឧបសម្ព័ន្ធទី ២) ។

អ្នកដេញថ្លៃត្រូវដាក់តម្លៃដេញថ្លៃតែមួយគត់ ហើយជាតម្លៃថេរក្នុងរយៈពេលអនុវត្តកិច្ចសន្យារបស់ខ្លួន និងមិនមែនជាកម្មវត្ថុសម្រាប់ធ្វើការផ្លាស់ប្តូរទេ ។ សំណើដេញថ្លៃណាមួយដែលដាក់តម្លៃដេញថ្លៃលើសពីមួយ ឬតម្លៃប្រែប្រួល ត្រូវចាត់ទុកជាមោឃៈ ។

**១១- ការចំណាយសម្រាប់ការដេញថ្លៃ**

អ្នកដេញថ្លៃត្រូវទទួលខុសត្រូវលើរាល់ការចំណាយផ្សេងៗ ដែលទាក់ទិននឹងការរៀបចំ និងការដាក់សំណើដេញថ្លៃរបស់ខ្លួន ។

## ១២- សុពលភាពសំណើដេញថ្លៃ

សំណើដេញថ្លៃត្រូវមានសុពលភាព រយៈពេលយ៉ាងតិចហុកសិប(៦០)ថ្ងៃ គិតចាប់ពីថ្ងៃបើកសំណើដេញថ្លៃ ។ សំណើដេញថ្លៃដែលមានសុពលភាពខ្លីជាងនេះ នឹងត្រូវបដិសេធ ។

ក្នុងករណីចាំបាច់ គណៈកម្មាធិការលទ្ធកម្មអាចស្នើសុំឱ្យអ្នកដេញថ្លៃពន្យារពេលសុពលភាពនៃសំណើដេញថ្លៃ តាមរយៈលិខិត ឬទូរសារដល់អ្នកដេញថ្លៃទាំងអស់ ។ អ្នកដេញថ្លៃអាចបដិសេធសំណើពន្យារពេលនេះ ហើយអាចដកសំណើដេញថ្លៃវិញបាន ដោយមិនមានការខាតបង់ប្រាក់កក់ធានាការដេញថ្លៃរបស់ខ្លួនឡើយ ។ ចំណែកអ្នកដេញថ្លៃដែលយល់ព្រមលើសំណើសុំពន្យារពេលនេះ នឹងមិនអនុញ្ញាតឱ្យធ្វើការផ្លាស់ប្តូរសំណើដេញថ្លៃរបស់ខ្លួនឡើយ ។

## ១៣- លិខិតធានាប្រាក់កក់ធានាការដេញថ្លៃ

អ្នកដេញថ្លៃត្រូវកក់ប្រាក់ធានាការដេញថ្លៃ ដែលមានទឹកប្រាក់យ៉ាងតិចពីរ(០២)ភាគរយ នៃតម្លៃដាក់ដេញថ្លៃសរុប នៅធនាគារជាតិនៃកម្ពុជា ឬសាខាធនាគារជាតិ........ ឬធនាគារពាណិជ្ជដែលបានចុះអនុស្សារណៈជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងគណនីរបស់អគ្គនាយកដ្ឋានរតនាគារជាតិលេខ.......... ។

បន្ទាប់ពីបានកក់ប្រាក់រួច អ្នកដេញថ្លៃត្រូវស្នើសុំអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគារ........ ចេញនូវលិខិតធានាប្រាក់កក់ធានាការដេញថ្លៃ (មានទម្រង់ និងខ្លឹមសារដូចក្នុងគំរូភ្ជាប់ជាមួយឯកសារដេញថ្លៃ) សម្រាប់ភ្ជាប់ជាមួយសំណើដេញថ្លៃរបស់ខ្លួន ។ លិខិតធានាប្រាក់កក់ធានាការដេញថ្លៃនេះមានសុពលភាព រយៈពេលយ៉ាងតិចសាមសិប(៣០)ថ្ងៃ ក្រោយសុពលភាពសំណើដេញថ្លៃ ។ ក្នុងករណីមានការពន្យារពេលសុពលភាពនៃសំណើដេញថ្លៃ សុពលភាពនៃប្រាក់កក់ធានាការដេញថ្លៃក៏ត្រូវពន្យារពេលស្របគ្នាផងដែរ ។

សំណើដេញថ្លៃណាដែលមិនបានភ្ជាប់មកជាមួយនូវលិខិតធានាប្រាក់កក់ខាងលើ ឬបំពេញប្រាក់កក់មិនបានត្រឹមត្រូវ ឬមិនគ្រប់ចំនួនទេនោះនឹងត្រូវបានចាត់ទុកជាមោឃៈ ឬមិនត្រូវបានជ្រើសរើសមកវាយតម្លៃប្រគល់កិច្ចសន្យាឡើយ ។

ចំពោះប្រាក់កក់របស់អ្នកដេញថ្លៃចាញ់ នឹងត្រូវបង្វែរជូនវិញមិនឱ្យហួសពីប្រាំពីរ(០៧)ថ្ងៃ បន្ទាប់ពីអ្នកដេញថ្លៃឈ្នះបានបង់ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា និងចុះហត្ថលេខាលើកិច្ចសន្យា ។

ចំពោះអ្នកដេញថ្លៃឈ្នះ ប្រាក់កក់នឹងត្រូវបង្វែរជូនវិញ នៅពេលបង់ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យារួច។ ប្រាក់កក់នេះនឹងត្រូវរឹបអូសបង្វែរចូលថវិការដ្ឋប្រសិនបើ ៖

- អ្នកដេញថ្លៃដកសំណើរបស់ខ្លួនវិញមុន និងក្នុងរយៈពេលសុពលភាពនៃសំណើដេញថ្លៃដែលមិនទាន់ប្រកាសលទ្ធផលជ័យលាភីអ្នកដេញថ្លៃឈ្នះ
- អ្នកដេញថ្លៃឈ្នះមិនព្រមចុះហត្ថលេខាលើកិច្ចសន្យា ឬមិនព្រមផ្តល់លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ។

## ១៤- ការចុះហត្ថលេខាលើសំណើដេញថ្លៃ

អ្នកដេញថ្លៃត្រូវរៀបចំសំណើដេញថ្លៃជាបីច្បាប់(ច្បាប់ដើមមួយច្បាប់ និងច្បាប់ចម្លងពីរច្បាប់) ។ ក្នុងករណីមានភាពមិនស្របគ្នារវាងច្បាប់ដើម និងច្បាប់ចម្លងនោះ ច្បាប់ដើមជាឯកសារផ្លូវការ ។ ច្បាប់ដើមត្រូវបំពេញដោយដៃ និងប្រើប្រាស់ទឹកខ្មៅដែលមិនអាចលប់ជ្រះ ហើយត្រូវចុះហត្ថលេខាដោយអ្នកដេញថ្លៃ ឬអ្នកតំណាងដែលមានលិខិតផ្ទេរសិទ្ធិត្រឹមត្រូវ ។ លិខិតផ្ទេរសិទ្ធិនេះ ត្រូវភ្ជាប់មកជាមួយសំណើដេញថ្លៃ ។ គ្រប់ទំព័រនៃសំណើដេញថ្លៃ រួមទាំងទំព័រដែលបំពេញបន្ថែម ឬកែតម្រូវ ត្រូវចុះហត្ថលេខាសង្ខេបដោយអ្នកដែលត្រូវចុះហត្ថលេខាលើសំណើដេញថ្លៃ ដើម្បីចៀសវាងការក្លែងបន្លំ ។

[1] គំរូឯកសារដេញថ្លៃ ពិគ្រោះថ្លៃ ស្ទង់តម្លៃ (ដេញថ្លៃ ទំនិញ) ទំព័រ 6/241

**១៥- ការបិទភ្ជិត និងការធ្វើកំណត់សម្គាល់លើសំណើដេញថ្លៃ**

ឯកសារច្បាប់ដើម និងច្បាប់ចម្លងត្រូវដាក់ក្នុងស្រោមសំបុត្របីផ្សេងគ្នាបិទភ្ជិត ដោយមានធ្វើសញ្ញាសម្គាល់លើស្រោមសំបុត្រថា "ច្បាប់ដើម" និង "ច្បាប់ចម្លង" រួចដាក់ក្នុងស្រោមសំបុត្ររួមធំមួយទៀតបិទភ្ជិត។ លើស្រោមសំបុត្រខាងក្នុង និងខាងក្រៅត្រូវសរសេរ ៖

- មិនត្រូវបើកមើលមុនពេលវេលា និងកាលបរិច្ឆេទកំណត់សម្រាប់ការបើកសំណើដេញថ្លៃ
- ផ្ញើជូនអង្គភាពលទ្ធកម្ម (*បញ្ចូលអាសយដ្ឋានដូចមានបញ្ជាក់ក្នុងឯកសារដេញថ្លៃ*)
- ឈ្មោះ អាសយដ្ឋានអ្នកដេញថ្លៃ (*បញ្ចូលឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ អ៊ីមែល របស់អ្នកដេញថ្លៃ*)។

ប្រសិនបើស្រោមសំបុត្រណាមួយមិនបានបិទភ្ជិត និងមិនមានធ្វើកំណត់សម្គាល់ដូចការតម្រូវខាងលើទេនោះ គណៈកម្មាធិការលទ្ធកម្មនឹងមិនទទួលខុសត្រូវចំពោះការផ្ញើត្រឡប់ទៅវិញខុសទីកន្លែង និងការបើកមើលមុនឡើយ ។

**១៦- ការកំណត់ពេលដាក់សំណើដេញថ្លៃ**

- អ្នកដេញថ្លៃ ត្រូវដាក់សំណើដេញថ្លៃរបស់ខ្លួន នៅអង្គភាពលទ្ធកម្ម ឱ្យបានមុនពេលវេលា និងកាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ ។
- សំណើដេញថ្លៃណាមួយដែលដាក់ក្រោយពេលវេលា និងកាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃនោះនឹងត្រូវបដិសេធ ។
- ក្រោយពេលវេលា និងកាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ ការកែតម្រូវរាល់កំហុសឆ្គងក្នុងសំណើដេញថ្លៃមិនត្រូវបានអនុញ្ញាតឡើយ ។

**១៧- ការផ្លាស់ប្តូរ និងការដកសំណើដេញថ្លៃ**

អ្នកដេញថ្លៃ អាចផ្លាស់ប្តូរ ឬដកសំណើដេញថ្លៃរបស់ខ្លួន មុនបី(០៣)ថ្ងៃ មុនពេលផុតកំណត់កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ ។ ការជូនដំណឹងរបស់អ្នកដេញថ្លៃ ពីការផ្លាស់ប្តូរ ឬដកសំណើដេញថ្លៃរបស់ខ្លួនត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដោយត្រូវបោះត្រា កាឌ្ញង ហើយបញ្ជូនទៅអង្គភាពលទ្ធកម្ម ដោយផ្ទាល់ ឬផ្ញើតាមទូរសារ ប៉ុន្តែត្រូវមានចុះហត្ថលេខាធានាអះអាង ។ ការដកសំណើដេញថ្លៃក្នុងរយៈពេលសុពលភាពនៃសំណើដេញថ្លៃ អាចបណ្តាលឱ្យមានការរឹបអូសប្រាក់កក់ធានាការដេញថ្លៃ ។ មិនអនុញ្ញាតឱ្យមានការកែប្រែសំណើដេញថ្លៃណាមួយ បន្ទាប់ពីផុតកាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ ។

**១៨- កិច្ចប្រជុំមុនពេលបើកសំណើដេញថ្លៃ**

អ្នកដេញថ្លៃអាចស្នើសុំបំភ្លឺអំពីចំណុចខ្លះៗ នៃឯកសារដេញថ្លៃ ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅស្ថាប័នអនុវត្តលទ្ធកម្ម តាមអាសយដ្ឋានដូចបានកំណត់ក្នុងសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ យ៉ាងតិចដប់បួន (១៤)ថ្ងៃ មុនកាលបរិច្ឆេទបើកសំណើដេញថ្លៃ ។

ស្ថាប័នអនុវត្តលទ្ធកម្មនឹងឆ្លើយតបជាលាយលក្ខណ៍អក្សរ ទៅគ្រប់អ្នកដេញថ្លៃដែលបានទទួលឯកសារដេញថ្លៃ មិនលើសបី(៣)ថ្ងៃ មុនកាលបរិច្ឆេទបើកសំណើដេញថ្លៃ ។ ការឆ្លើយតបនេះពិពណ៌នាអំពីសំណួរ ប៉ុន្តែមិនត្រូវបានបញ្ជាក់អំពីប្រភពសំណួរទេ ។

ក្នុងករណីមានចម្ងល់ច្រើនពាក់ព័ន្ធនឹងឯកសារដេញថ្លៃ ស្ថាប័នអនុវត្តលទ្ធកម្ម អាចធ្វើកិច្ចប្រជុំមុនកាលបរិច្ឆេទបើកសំណើដេញថ្លៃ ដើម្បីឆ្លើយបំភ្លឺដោយអញ្ជើញអ្នកដេញថ្លៃដែលបានទទួលឯកសារដេញថ្លៃមកចូលរួម ។

**១៩- ការបើកសំណើដេញថ្លៃ**

រាល់សំណើដេញថ្លៃទាំងអស់ត្រូវបើកជាសាធារណៈភ្លាមៗ តាមពេលវេលា កាលបរិច្ឆេទនិងទីកន្លែង ដូចបានកំណត់ក្នុងសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ ក្រោមការដឹកនាំរបស់ប្រធានគណៈកម្មាធិការលទ្ធកម្ម ដោយមានការចូលរួមពីសមាជិកគណៈកម្មាធិការលទ្ធកម្ម អ្នកដេញថ្លៃ និងអ្នកពាក់ព័ន្ធដទៃទៀត ។ ព័ត៌មានសំខាន់ៗ ដូចជាឈ្មោះអ្នកដេញថ្លៃ ប្រាក់កក់ធានាការដេញថ្លៃ តម្លៃដាក់ដេញថ្លៃសរុប ការបញ្ចុះតម្លៃនានា ការកែប្រែ ឬការដកសំណើវិញ ត្រូវបានប្រកាស អាន បង្ហាញនិងកត់ត្រាឱ្យបានច្បាស់លាស់ នៅពេលបើកសំណើដេញថ្លៃ ។ កំណត់ហេតុបើកសំណើដេញថ្លៃ ត្រូវបានចែកជូនគ្រប់អ្នកចូលរួមទាំងអស់ ។

ការបើកសំណើដេញថ្លៃនេះ ពុំមានន័យថាជាការប្រកាសលទ្ធផលឈ្នះ ចាញ់ឡើយ ។ ការកំណត់ឈ្នះចាញ់ គឺអាស្រ័យទៅលើការវាយតម្លៃលើសំណើដេញថ្លៃនីមួយៗ ។

**២០- ការវាយតម្លៃលើសំណើដេញថ្លៃ**

ការវាយតម្លៃជ្រើសរើសអ្នកដេញថ្លៃ និងប្រគល់កិច្ចសន្យា ធ្វើឡើងជាសម្ងាត់ និងដោយម៉ត់ចត់ស្របតាមលក្ខខណ្ឌតម្រូវ និងលក្ខណៈវិនិច្ឆ័យដូចមានចែងក្នុងឯកសារដេញថ្លៃ និងផ្អែកលើព័ត៌មានសំខាន់ៗ ក្នុងកំណត់ហេតុស្តីពីការបើកសំណើដេញថ្លៃ ។ ចាប់ពីពេលបើកសំណើដេញថ្លៃរហូតដល់ពេលសម្រេចប្រគល់កិច្ចសន្យាជាផ្លូវការ ការទាក់ទងណាមួយរវាងអ្នកដេញថ្លៃនិងគណៈកម្មាធិការលទ្ធកម្មដែលពាក់ព័ន្ធនឹងសំណើដេញថ្លៃ មិនត្រូវបានអនុញ្ញាតឡើយ ។

គណៈកម្មាធិការលទ្ធកម្មនឹងពិនិត្យមើលជាបឋមនូវសំណើដេញថ្លៃ ដោយកំណត់ថាតើមានកំហុសក្នុងការគិតលេខនព្វន្តឬទេ? មានលិខិតធានាប្រាក់កក់ធានាដេញថ្លៃត្រឹមត្រូវឬទេ? មានចុះហត្ថលេខាត្រឹមត្រូវ និងថាតើសំណើដេញថ្លៃជាទូទៅបានបំពេញតាមលក្ខខណ្ឌតម្រូវក្នុងឯកសារដេញថ្លៃឬទេ?

ក្នុងករណីដែលមានភាពមិនស្របគ្នារវាងចំនួនជាតួលេខ និងអក្សរនោះ ចំនួនដែលសរសេរជាអក្សរចាត់ទុកជាបានការ ។

*<u>កំហុសលេខនព្វន្ត នឹងធ្វើការកែតម្រូវលើមូលដ្ឋានដូចខាងក្រោម</u>* ៖

- ប្រសិនបើមានភាពមិនស្របគ្នារវាងតម្លៃសរុបដែលបានមកពីការគុណតម្លៃឯកតា និងបរិមាណនោះ តម្លៃឯកតាត្រូវរក្សានៅដដែលដោយធ្វើការកែតម្រូវលើតម្លៃសរុប
- ប្រសិនបើមានភាពមិនស្របគ្នារវាងតម្លៃដាក់ដេញថ្លៃសរុប និងផលបូកតម្លៃសរុបនីមួយៗនោះ ផលបូកតម្លៃសរុបនីមួយៗ ត្រូវរក្សាទុកនៅដដែល ហើយធ្វើការកែតម្រូវលើតម្លៃដាក់ដេញថ្លៃសរុប
- ប្រសិនបើអ្នកដេញថ្លៃណាមិនព្រមទទួលយកនូវការកែតម្រូវទេ សំណើដេញថ្លៃរបស់អ្នកដេញថ្លៃនោះនឹងត្រូវបដិសេធ ។

មុនពេលវាយតម្លៃលម្អិត គណៈកម្មាធិការលទ្ធកម្មនឹងកំណត់ពីការឆ្លើយតបរបស់សំណើនីមួយៗ ទៅនឹងឯកសារដេញថ្លៃ ។ សំណើដេញថ្លៃដែលត្រូវបានចាត់ទុកថាបានឆ្លើយតបពេញលេញ គឺជាសំណើដែលឆ្លើយតបគ្រប់លក្ខខណ្ឌដែលមានចែងនៅក្នុងឯកសារដេញថ្លៃ ។ គណៈកម្មាធិការលទ្ធកម្មនឹងពិចារណាមិនយកសំណើដេញថ្លៃណាដែលឆ្លើយតបមិនសមស្រប ។ គណៈកម្មាធិការលទ្ធកម្មធ្វើការប្រៀបធៀបសំណើដេញថ្លៃដែលត្រូវបានកំណត់ថាជាសំណើដេញថ្លៃមានការឆ្លើយតបតាមលក្ខខណ្ឌតម្រូវ ដើម្បីធ្វើចំណាត់ថ្នាក់អ្នកដេញថ្លៃ ។

**២១- ការត្រួតពិនិត្យលក្ខណសម្បត្តិតាមក្រោយ**

មុនសម្រេចប្រគល់កិច្ចសន្យា គណៈកម្មាធិការលទ្ធកម្មនឹងធ្វើការត្រួតពិនិត្យលក្ខណសម្បត្តិតាមក្រោយរបស់អ្នកដេញថ្លៃនាំមុខទី១ ដោយធ្វើការផ្ទៀងផ្ទាត់ឡើងវិញលើឯកសារភស្តុតាងនានា ដើម្បីធានាភាពត្រឹមត្រូវនៃតម្រូវការផ្លូវច្បាប់ តម្រូវការសមត្ថភាព "ហិរញ្ញវត្ថុ បច្ចេកទេស បទពិសោធន៍" ជាមួយនឹងស្ថានភាពជាក់ស្តែងរបស់អ្នកដេញថ្លៃនាំមុខ ដើម្បីធានាការអនុវត្តកិច្ចសន្យា ។ ប្រសិនបើអ្នកដេញថ្លៃនាំមុខទី១ មិនមានលក្ខណសម្បត្តិគ្រប់គ្រាន់ គណៈកម្មាធិការលទ្ធកម្មនឹងបដិសេធសំណើដេញថ្លៃនោះ ហើយបន្តធ្វើការត្រួតពិនិត្យលក្ខណសម្បត្តិតាមក្រោយរបស់អ្នកដេញថ្លៃនាំមុខបន្ទាប់ទៀត ។

**២២- លក្ខណៈវិនិច្ឆ័យនៃការសម្រេចប្រគល់កិច្ចសន្យា**

គណៈកម្មាធិការលទ្ធកម្ម នឹងសម្រេចប្រគល់កិច្ចសន្យាទៅឱ្យអ្នកដេញថ្លៃឈ្នះ ដែលសំណើរបស់អ្នកដេញថ្លៃនោះត្រូវបានវាយតម្លៃថាឆ្លើយតបសមស្រប និងមានតម្លៃទាបជាងគេ ហើយត្រូវបានកំណត់ថាមានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងការអនុវត្តកិច្ចសន្យា ។

**២៣- សេចក្តីជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យា**

បន្ទាប់ពីបញ្ចប់ការវាយតម្លៃជ្រើសរើសអ្នកដេញថ្លៃ គណៈកម្មាធិការលទ្ធកម្មនឹងចេញសេចក្តីជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យាឱ្យអ្នកដេញថ្លៃឈ្នះ ដោយចម្លងជូនគ្រប់អ្នកដេញថ្លៃចាញ់ និងផ្សព្វផ្សាយជាសាធារណៈ ព្រមទាំងទុករយៈពេលដប់(១០)ថ្ងៃធ្វើការ ដើម្បីឱ្យអ្នកដេញថ្លៃទាំងនោះជំទាស់តវ៉ា ទៅនឹងលទ្ធផលនៃការដេញថ្លៃ មុននឹងអញ្ជើញអ្នកដេញថ្លៃឈ្នះមកចុះហត្ថលេខាលើកិច្ចសន្យា ។

**២៤- បណ្តឹងតវ៉ា**

បណ្តឹងតវ៉ាអាចត្រូវបានធ្វើឡើង នៅគ្រប់ដំណាក់កាលនៃដំណើរការកិច្ចលទ្ធកម្ម មុនពេលចុះកិច្ចសន្យា ។ បណ្តឹងតវ៉ាដែលបានធ្វើឡើងក្នុងរយៈពេលនៃការវាយតម្លៃសំណើដេញថ្លៃ នឹងមិនត្រូវបានឆ្លើយតបឡើយ ។ ការឆ្លើយតបនោះ នឹងត្រូវបានធ្វើឡើង បន្ទាប់ពីការវាយតម្លៃបានបញ្ចប់ ។

បណ្តឹងតវ៉ាត្រូវធ្វើជូនគណៈកម្មាធិការលទ្ធកម្ម ដូចមានឈ្មោះ និងអាសយដ្ឋានក្នុងឯកសារដេញថ្លៃ ។ គណៈកម្មាធិការលទ្ធកម្មធ្វើអង្កេតលើមូលដ្ឋាននៃបណ្តឹងតវ៉ានិងធ្វើការឆ្លើយតបជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេលដប់ប្រាំ(១៥)ថ្ងៃធ្វើការ បន្ទាប់ពីបានទទួលបណ្តឹងតវ៉ានោះ លើកលែងតែក្នុងករណីការតវ៉ាទាំងឡាយដែលបានទទួលក្នុងកំឡុងពេលវាយតម្លៃ ។

ក្នុងករណីការឆ្លើយតបរបស់គណៈកម្មាធិការលទ្ធកម្ម មិនបំពេញតាមបំណងអ្នកដេញថ្លៃចាញ់ ឬក៏ពុំមានការឆ្លើយតបណាមួយត្រូវបានធ្វើឡើងនោះ បណ្តឹងតវ៉ានឹងត្រូវបានបញ្ជូនទៅអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈធ្វើការឆ្លើយតប ក្នុងរយៈពេលដប់ប្រាំ(១៥)ថ្ងៃធ្វើការ ។ ករណីនេះមិនបណ្តាលឱ្យមានការបាត់បង់សិទ្ធរបស់អ្នកដេញថ្លៃចំពោះបណ្តឹងតវ៉ាបន្តណាមួយផ្សេងទៀតដែលអ្នកដេញថ្លៃអាចជ្រើសរើសនោះទេ ។

**២៥- ការចុះហត្ថលេខាលើកិច្ចសន្យា**

បន្ទាប់ពីរយៈពេលដប់(១០)ថ្ងៃធ្វើការ នៃការចេញសេចក្តីជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យា ប្រសិនបើពុំមានការជំទាស់តវ៉ាណាមួយ ឬបន្ទាប់ពីការជំទាស់តវ៉ាទាំងអស់ត្រូវបានដោះស្រាយ គណៈកម្មាធិការលទ្ធកម្មធ្វើការអញ្ជើញអ្នកដេញថ្លៃឈ្នះមកចុះហត្ថលេខាលើកិច្ចសន្យា ដោយភ្ជាប់ជាមួយនូវលិខិតធានាប្រាក់ត្រូវធានាការអនុវត្តកិច្ចសន្យា ក្នុងរយៈពេលយ៉ាងយូរប្រាំពីរ(០៧)ថ្ងៃ ។ ក្នុងករណីដែលអ្នកដេញថ្លៃឈ្នះមិនព្រមចុះ

ហត្ថលេខាលើកិច្ចសន្យា ឬពន្យារពេលចុះហត្ថលេខាលើកិច្ចសន្យា ដោយពុំមានមូលហេតុសមស្របនោះ ប្រាក់កក់ធានាការដេញថ្លៃត្រូវបានរឹបអូសបង់ចូលថវិការដ្ឋ ហើយអ្នកដេញថ្លៃនោះត្រូវបានកំណត់ថាជាមុខសញ្ញាសម្រាប់ការចុះឈ្មោះក្នុងបញ្ជីខ្មៅ ។ ជាមួយគ្នានេះគណៈកម្មាធិការលទ្ធកម្ម ពិនិត្យ និងវាយតម្លៃលក្ខណសម្បត្តិតាមក្រោយរបស់អ្នកដេញថ្លៃនាំមុខបន្ទាប់ ។

**២៦- ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា**

អ្នកដេញថ្លៃឈ្នះត្រូវកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា ដែលមានទឹកប្រាក់ស្មើនឹងដប់(១០)ភាគរយ នៃតម្លៃកិច្ចសន្យាសរុប នៅធនាគារជាតិនៃកម្ពុជា ឬសាខាធនាគារជាតិ.............. ឬធនាគារពាណិជ្ជដែលបានចុះអនុស្សារណៈជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងគណនីរបស់អគ្គនាយកដ្ឋានរតនាគារជាតិលេខ...... ។

បន្ទាប់ពីបានកក់ប្រាក់រួច អ្នកដេញថ្លៃឈ្នះត្រូវស្នើសុំអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគារ.............. ចេញនូវលិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា (មានទម្រង់ និងខ្លឹមសារដូចក្នុងគំរូភ្ជាប់ជាមួយឯកសារដេញថ្លៃ) រួចប្រគល់ជូន "អ្នកទិញ" មុនពេលចុះកិច្ចសន្យា ។

ការខកខានក្នុងការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា គឺជាមូលដ្ឋានគ្រប់គ្រាន់ក្នុងការរឹបអូសប្រាក់កក់ធានាការដេញថ្លៃ ។

ប្រាក់កក់នេះត្រូវប្រគល់ជូន "អ្នកផ្គត់ផ្គង់" វិញ យ៉ាងយូរក្នុងរយៈពេលដប់ប្រាំ(១៥)ថ្ងៃ ក្រោយពេលប្រគល់ ទទួលទំនិញ ចប់ជាស្ថាពរ ឬក្រោយពេលផុតរយៈពេលធានាគុណភាពទំនិញ ។

ក្នុងករណី "អ្នកផ្គត់ផ្គង់" មិនបានអនុវត្តតាមប្រការណាមួយនៃកិច្ចសន្យា ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យានេះនឹងត្រូវរឹបអូសបង់ចូលថវិការដ្ឋ ហើយនឹងត្រូវបានកំណត់ថាជាមុខសញ្ញាសម្រាប់ការចុះឈ្មោះក្នុងបញ្ជីខ្មៅ ។

# លក្ខខណ្ឌនៃកិច្ចសន្យា

## ១-និយមន័យ

-ក្រសួង/ស្ថាប័ន/រាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ................... ជាអ្នកទិញ ហៅកាត់ថា ភាគី "ក" តំណាងដោយ........................... មុខងារ........................មានអាសយដ្ឋាន........................ ។

-ក្រុមហ៊ុន/សហគ្រាស.......................... ដែលបានចូលរួមដេញថ្លៃ ហើយដែលត្រូវបានជ្រើសរើសប្រគល់កិច្ចសន្យាស្តីពីការផ្គត់ផ្គង់......... ជាអ្នកផ្គត់ផ្គង់ ហៅកាត់ថាភាគី "ខ" តំណាងដោយ..................... មុខងារ......................... អាសយដ្ឋាន................. លេខទូរស័ព្ទ............. អ៊ីមែល.............. ។

-តម្លៃសរុបនៃការផ្គត់ផ្គង់......... ដែលចុះកិច្ចសន្យាហៅថា "តម្លៃកិច្ចសន្យា" ។

## ២- ការបរិយាយ និង លក្ខណៈបច្ចេកទេសទំនិញ

ទំនិញដែលត្រូវធ្វើការផ្គត់ផ្គង់តាមកិច្ចសន្យានេះ គឺជាទំនិញដែលបានបរិយាយនៅក្នុងតារាងតម្លៃ និងបញ្ជាក់លក្ខណៈបច្ចេកទេស ។

## ៣- ការវេចខ្ចប់

"អ្នកផ្គត់ផ្គង់" ត្រូវធ្វើការវេចខ្ចប់ទំនិញតាមការតម្រូវ ដើម្បីទប់ស្កាត់ការខូចខាត ឬការថយចុះគុណភាពក្នុងអំឡុងពេលចរាចរទៅកាន់ទីកន្លែងចុងក្រោយ ។ ការវេចខ្ចប់ត្រូវមានលក្ខណៈគ្រប់គ្រាន់ដើម្បីការពារនៅពេលលើកដាក់ធ្ងន់ធ្ងរ ការប៉ះពាល់នឹងសីតុណ្ហភាពខ្ពស់ ការប៉ះពាល់សារធាតុប្រៃ ក្នុងពេលចរាចរ និងការស្តុកទុកដោយចំហ ។ ទំហំ និងទម្ងន់នៃប្រអប់វេចខ្ចប់ ត្រូវគិតគូរដល់ចម្ងាយផ្លូវដឹកជញ្ជូន និងអវត្តមាននៃគ្រឿងបរិក្ខារសម្រាប់លើកដាក់ទំនិញធ្ងន់ៗ នៅគ្រប់ចំណុចក្នុងពេលចរាចរ ។

## ៤- ការប្រគល់ ទទួល

អ្នកផ្គត់ផ្គង់(ភាគី "ខ") ត្រូវប្រគល់មុខទំនិញទាំងអស់ជូនអ្នកទិញ (ភាគី "ក") តាមទីតាំងដែលបានកំណត់យ៉ាងយូរក្នុងរយៈពេល........... ថ្ងៃ (សរសេរជាអក្សរ.....) បន្ទាប់ពីកិច្ចសន្យាចូលជាធរមាន ។ ការប្រគល់ ទទួលត្រូវពិនិត្យឱ្យបានហ្មត់ចត់ត្រឹមត្រូវតាមបរិមាណ គុណភាព លក្ខណៈបច្ចេកទេស ម៉ាក់គំរូ កាតាឡុករបស់ទំនិញដូចមានចែងក្នុងតារាងតម្លៃ និងបញ្ជាក់លក្ខណៈបច្ចេកទេស ។

ការប្រគល់ ទទួលអាចធ្វើឡើងជាដំណាក់កាលៗ តាមតម្រូវការចាំបាច់ ដោយមានកំណត់ហេតុប្រគល់ទទួលច្បាស់លាស់របស់គណៈកម្មការប្រគល់ ទទួល និងមានការយល់ព្រមពីប្រធានគណៈកម្មាធិការលទ្ធកម្ម ។

*ចំពោះកិច្ចលទ្ធកម្មដែលត្រូវពិនិត្យ និងសម្រេចដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវមានការចូលរួមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។*

## ៥- ការធានាគុណភាពទំនិញ

"អ្នកផ្គត់ផ្គង់" ត្រូវធានាថា រាល់គុណភាពទំនិញត្រូវឆ្លើយតបទៅនឹងម៉ាក់គំរូ កាតាឡុក និង[illegible]ទំនិញដែលត្រូវប្រគល់ ជាទំនិញដែលមានលក្ខណៈបច្ចេកទេសស្របតាមលក្ខខណ្ឌដែល "អ្នកទិញ" បាន[illegible] "អ្នកផ្គត់ផ្គង់" យល់ព្រមផ្លាស់ប្តូរជំនួស ឬកែតម្រូវដោយចំណាយផ្ទាល់ខ្លួន ចំពោះមុខទំនិញដែលខូចខាត ឬផ្នែកណាមួយនៃទំនិញ ក្រោយពី "អ្នកទិញ" បានប្រាប់ឱ្យដឹងអំពីលក្ខណៈនៃការខូចខាតនោះ ។ ប្រសិនបើ "អ្នកផ្គត់ផ្គង់" [illegible]

ខកខានមិនបានសងការខូចខាត ឬជំនួសទេនោះ "អ្នកទិញ" អាចចាត់វិធានការចាំបាច់ទិញពីអ្នកផ្សេងទៀត ដែលការចំណាយជាបន្ទុករបស់ "អ្នកផ្គត់ផ្គង់" ដោយមិនធ្វើឱ្យខូចខាតដល់សិទ្ធិណាមួយរបស់ "អ្នកទិញ" ដែលមាននៅក្នុងកិច្ចសន្យា ។ ករណីមានការធានាលើសេវាប្រើប្រាស់ ត្រូវចែងឱ្យបានច្បាស់ក្នុងកិច្ចសន្យា ។

## ៦- ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា

"អ្នកផ្គត់ផ្គង់" ត្រូវកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា ដែលមានទឹកប្រាក់ស្មើនឹងដប់(១០)ភាគរយ នៃតម្លៃកិច្ចសន្យាសរុប នៅធនាគារជាតិនៃកម្ពុជា ឬសាខាធនាគារជាតិ.............. ឬធនាគារពាណិជ្ជដែលបានចុះអនុស្សារណៈជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងគណនីរបស់អគ្គនាយកដ្ឋានរតនាគារជាតិលេខ...... ។

បន្ទាប់ពីបានកក់ប្រាក់រួច "អ្នកផ្គត់ផ្គង់" ត្រូវស្នើសុំអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគារ.............. ចេញនូវលិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា (មានទម្រង់ និងខ្លឹមសារដូចក្នុងគំរូភ្ជាប់ជាមួយឯកសារដេញថ្លៃ) រួចប្រគល់ជូន "អ្នកទិញ" មុនពេលចុះកិច្ចសន្យា ។

ការខកខានក្នុងការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា គឺជាមូលដ្ឋានគ្រប់គ្រាន់ក្នុងការរឹបអូសប្រាក់កក់ធានាការដេញថ្លៃ ។

ប្រាក់កក់នេះត្រូវប្រគល់ជូន"អ្នកផ្គត់ផ្គង់"វិញយ៉ាងយូរក្នុងរយៈពេលដប់ប្រាំ(១៥)ថ្ងៃ ក្រោយពេលប្រគល់ទទួលទំនិញចប់ជាស្ថាពរ ឬក្រោយពេលផុតរយៈពេលធានាគុណភាពទំនិញ ។

ក្នុងករណី"អ្នកផ្គត់ផ្គង់"មិនបានអនុវត្តតាមប្រការណាមួយនៃកិច្ចសន្យា ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យានេះនឹងត្រូវរឹបអូសបង់ចូលថវិការដ្ឋ ហើយនឹងត្រូវបានកំណត់ថាជាមុខសញ្ញាសម្រាប់ការចុះឈ្មោះក្នុងបញ្ជីខ្មៅ ។

## ៧- ការកែប្រែបញ្ជាទិញ

-ប្រសិនបើ "អ្នកទិញ" មានបំណងផ្លាស់ប្តូរការបញ្ជាទិញ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ "អ្នកផ្គត់ផ្គង់" និងត្រូវប្រជុំដោះស្រាយការកែប្រែលើកិច្ចសន្យា ។ ការកែប្រែអាចធ្វើឡើងក្នុងលក្ខណៈបច្ចេកទេស បរិមាណ និងទីកន្លែងប្រគល់ ទទួល ។

-ប្រសិនបើ"អ្នកផ្គត់ផ្គង់"ទទួលយកនូវការកែប្រែនេះតាមលក្ខខណ្ឌដែលបានព្រមព្រៀងនោះ ការកែប្រែនឹងក្លាយទៅជាឯកសារឧបសម្ព័ន្ធបន្ថែមនៃកិច្ចសន្យា ។ ការកែប្រែត្រូវមានការឯកភាពជាចុងក្រោយពីប្រធានគណៈកម្មាធិការលទ្ធកម្ម ។

*ចំពោះកិច្ចលទ្ធកម្មដែលត្រូវពិនិត្យ និងសម្រេចដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការកែប្រែនោះ ត្រូវមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។*

## ៨- ការត្រួតពិនិត្យ និងការសាកពិសោធន៍

ប្រសិនបើ "អ្នកទិញ" ចាត់ទុកថាការសាកពិសោធន៍ ឬការត្រួតពិនិត្យជាការចាំបាច់នោះ ក្នុងកិច្ចសន្យាត្រូវមានបញ្ជាក់ពីចំណុចស្តីពីការសាកពិសោធន៍ ឬការត្រួតពិនិត្យ ដោយបញ្ជាក់ពីទីកន្លែងនិងពេលវេលាច្បាស់លាស់ ។

"អ្នកផ្គត់ផ្គង់" ត្រូវបង្កភាពងាយស្រួលក្នុងការផ្តល់ប៉ាន់គំរូ កាតាឡុក ទិន្នន័យនៃផលិតផល លិខិតធានាផ្សេងៗ ដើម្បីឱ្យដំណើរការសាកពិសោធន៍ ឬការត្រួតពិនិត្យប្រព្រឹត្តទៅបានឆាប់រហ័ស ដោយមិនគិតសោហ៊ុយចំណាយពី "អ្នកទិញ" បន្ថែមទៀតទេ ។ ប្រសិនបើទំនិញដែលបានត្រួតពិនិត្យ ឬសាកពិសោធន៍ហើយមិនសមស្របតាមលក្ខណៈបច្ចេកទេសនោះ "អ្នកទិញ" អាចបដិសេធ ហើយ"អ្នកផ្គត់ផ្គង់"ចាំបាច់ត្រូវធ្វើការកែតម្រូវតាមលក្ខណៈបច្ចេកទេសដែលបានកំណត់ ហើយសោហ៊ុយចំណាយជាបន្ទុករបស់ "អ្នកផ្គត់ផ្គង់" ។

**៩- ការពន្យារពេលផ្គត់ផ្គង់**

"អ្នកផ្គត់ផ្គង់" អាចស្នើសុំពន្យារពេលផ្គត់ផ្គង់ បានដោយមានការយល់ព្រមពី "អ្នកទិញ" ផ្អែកលើមូលហេតុជាក់ស្តែង ។ "អ្នកផ្គត់ផ្គង់" ត្រូវជូនដំណឹងពីរាល់ព្រឹត្តិការណ៍ដែលបណ្តាលឱ្យមានការយឺតយ៉ាវ ហើយ "អ្នកទិញ" ត្រូវពិនិត្យ និងសម្រេចលើការសុំពន្យារពេលផ្គត់ផ្គង់ មិនឱ្យលើសពីប្រាំពីរ(០៧)ថ្ងៃ បន្ទាប់ពីបានទទួលលិខិតស្នើសុំរបស់ "អ្នកផ្គត់ផ្គង់" ។ ប្រសិនបើ "អ្នកផ្គត់ផ្គង់" ខកខានក្នុងការប្រកាសជូនដំណឹងជាមុនអំពីការយឺតយ៉ាវ ឬខកខានក្នុងការធ្វើកិច្ចសហការ ដើម្បីដោះស្រាយការយឺតយ៉ាវនោះ ការយឺតយ៉ាវបែបនេះ មិនត្រូវបានពិចារណាដើម្បីផ្តល់ការពន្យារពេលបន្ថែមឡើយ ។

*ចំពោះកិច្ចលទ្ធកម្មដែលត្រូវពិនិត្យ និងសម្រេចដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការពន្យារពេលនោះ ត្រូវមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។*

**១០- ករណីប្រធានសក្តិ**

ក្នុងករណីប្រធានសក្តិ ដូចជាភ្លើងឆេះ ទឹកជំនន់ រញ្ជួយផែនដី ជម្ងឺរាលដាល បាតុកម្ម កុបកម្ម ទណ្ឌកម្មសេដ្ឋកិច្ច និង វិបត្តិភ័យដទៃទៀត ឬព្រឹត្តិការណ៍ដែលធ្វើឱ្យ "អ្នកផ្គត់ផ្គង់" មានការលំបាកខ្លាំងក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាមពេលកំណត់ "អ្នកផ្គត់ផ្គង់" ត្រូវផ្តល់ព័ត៌មានជូន "អ្នកទិញ" ឱ្យបានឆាប់តាមតែអាចធ្វើបានដើម្បីស្វែងរកដំណោះស្រាយ ។

ប្រសិនបើ"អ្នកផ្គត់ផ្គង់" មិនបានផ្តល់ព័ត៌មានឱ្យបានទាន់ពេលវេលាទេនោះ "អ្នកទិញ" នឹងមិនទទួលខុសត្រូវចំពោះបញ្ហានេះឡើយ ។

ការយឺតយ៉ាវ ឬការខកខានក្នុងការអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យា ដែលបណ្តាលពីករណីប្រធានសក្តិ នេះ "អ្នកផ្គត់ផ្គង់" មិនត្រូវបានទទួលរងនូវការផាកពិន័យ ឬរឹបអូសប្រាក់កក់ធានាការអនុវត្តឡើយ ។

**១១- កិច្ចសន្យាបន្ត**

ការចុះកិច្ចសន្យាបន្តនៃកិច្ចសន្យាទាំងមូលមិនត្រូវបានអនុញ្ញាតជាដាច់ខាត ។ "អ្នកផ្គត់ផ្គង់ទំនិញដើម" អាចចុះកិច្ចសន្យាបន្តឱ្យ "អ្នកផ្គត់ផ្គង់ទំនិញបន្ត" ដើម្បីឱ្យអនុវត្តផ្នែកណាមួយនៃកិច្ចសន្យាបាន ដរាបណាមានការយល់ព្រមពី "អ្នកទិញ" ។ "អ្នកផ្គត់ផ្គង់ទំនិញបន្ត" ត្រូវចុះកិច្ចសន្យាជាមួយ "អ្នកផ្គត់ផ្គង់ទំនិញដើម" មិនមែនចុះកិច្ចសន្យាជាមួយ "អ្នកទិញ" នោះទេ ។ ប្រសិនបើ "អ្នកផ្គត់ផ្គង់បន្ត" មានកំហុសឆ្គងណាមួយ "អ្នកផ្គត់ផ្គង់ទំនិញដើម" ត្រូវទទួលខុសត្រូវទាំងស្រុង ដោយធានាថាកំហុសទាំងនោះត្រូវបានកែតម្រូវ ។ "អ្នកទិញ" មិនធ្វើការដោះស្រាយបញ្ហាណាមួយដោយផ្ទាល់ជាមួយ "អ្នកផ្គត់ផ្គង់ទំនិញបន្ត" ឡើយ ។

*ចំពោះកិច្ចលទ្ធកម្មដែលត្រូវពិនិត្យ និងសម្រេចដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការចុះកិច្ចសន្យាបន្តត្រូវមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។*

**១២- ការបញ្ចប់កិច្ចសន្យា**

"អ្នកទិញ" អាចពិចារណាលើការលុបចោលកិច្ចសន្យាទាំងមូល ឬផ្នែកខ្លះ តាមកាលៈទេសៈដូចខាងក្រោម ៖

- ប្រសិនបើ "អ្នកផ្គត់ផ្គង់" មិនមានលទ្ធភាពប្រគល់នូវមុខទំនិញតាមកាលកំណត់ដូចមានចែងក្នុងកិច្ចសន្យា
- ប្រសិនបើ "អ្នកផ្គត់ផ្គង់" មិនអាចបំពេញកាតព្វកិច្ចរបស់ខ្លួនតាមលក្ខខណ្ឌនៃកិច្ចសន្យា
- ប្រសិនបើ "អ្នកផ្គត់ផ្គង់" ក្ស័យធន ឬក៏ស្ថិតក្នុងស្ថានភាពក្ស័យធន ដែលមិនអាចសងបំណុលបាន

ក្នុងករណីដែល "អ្នកទិញ" បញ្ចប់កិច្ចសន្យាតាមចំណុចទី១ និងទី២ ខាងលើ "អ្នកទិញ" អាចទិញទំនិញដែលខកខានមិនបានប្រគល់ ប្រសិនបើខ្លួនគិតថាចាំបាច់ ហើយ "អ្នកផ្គត់ផ្គង់" ត្រូវទទួលខុសត្រូវចំពោះការចំណាយលើការទិញទំនិញដែលមិនបានប្រគល់នោះ ។ ក្នុងករណីដែលបញ្ចប់កិច្ចសន្យាដោយហេតុផលក្ស័យធន ការលុបចោលកិច្ចសន្យា នឹងមិនប៉ះពាល់ដល់សិទ្ធិ ឬសកម្មភាពណាមួយរបស់ "អ្នកទិញ" ឡើយ ។

*ចំពោះកិច្ចលទ្ធកម្មដែលត្រូវពិនិត្យ និងសម្រេចដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការបញ្ចប់កិច្ចសន្យានេះ ត្រូវមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។*

**១៣- ការទូទាត់**

ការទូទាត់អាចធ្វើឡើងជាដំណាក់កាលៗ តាមលទ្ធផលប្រគល់ ទទួលជាក់ស្តែង ដោយមានកំណត់ហេតុប្រគល់ ទទួលច្បាស់លាស់ ។

រូបិយវត្ថុសម្រាប់ធ្វើការទូទាត់ គឺប្រាក់រៀល ។ ការទូទាត់ត្រូវធ្វើឡើងតាមរយៈអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគារ......... ដោយបង្វែរចូលគណនីរបស់"អ្នកផ្គត់ផ្គង់" លេខ.................... នៅធនាគារ................ ក្នុងរយៈពេលយ៉ាងយូរសែសិបប្រាំ(៤៥)ថ្ងៃ ក្រោយការប្រគល់ ទទួល ។

**១៤- ពន្ធ អាករ**

"អ្នកផ្គត់ផ្គង់" ត្រូវបង់ជូនរដ្ឋនូវពន្ធ អាករគ្រប់ប្រភេទ រួមទាំង "អាករលើតម្លៃបន្ថែម" តាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។ "អាករលើតម្លៃបន្ថែម" ត្រូវបង់តាម "វិធីកាត់ទុក" ដោយអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគារ........ នាពេលទូទាត់ រហូតអស់តម្លៃកិច្ចសន្យា ។

**១៥- ការផាកពិន័យ**

ក្នុងករណី "អ្នកផ្គត់ផ្គង់" មិនបានប្រគល់នូវមុខទំនិញតាមពេលកំណត់នោះ "អ្នកផ្គត់ផ្គង់" ត្រូវទទួលរងនូវការផាកពិន័យជាប្រាក់ចំនួន ០,១០% ក្នុងមួយថ្ងៃ នៃតម្លៃទំនិញដែលប្រគល់យឺតយ៉ាវ តាមចំនួនថ្ងៃដែលយឺតយ៉ាវនោះ ។ ចំនួនទឹកប្រាក់ពិន័យនេះ មិនត្រូវឱ្យលើសពី ១០% នៃតម្លៃកិច្ចសន្យាទេ នៅពេលដែលចំនួនទឹកប្រាក់ពិន័យលើសកម្រិតអតិបរមានេះ "អ្នកទិញ" អាចពិចារណាពីការលុបកិច្ចសន្យា ។

ក្នុងករណីដែល"អ្នកទិញ" និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិ/មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ..... រតនាគារ....... ) ធ្វើការទូទាត់យឺតយ៉ាវនោះ "អ្នកទិញ" និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរងការពិន័យជាប្រាក់ជូន "អ្នកផ្គត់ផ្គង់" ចំនួន ០,០៥% ក្នុងមួយថ្ងៃ លើចំនួនទឹកប្រាក់ដែលត្រូវទូទាត់ តាមចំនួនថ្ងៃដែលយឺតយ៉ាវនោះ ។

**១៦- ការទប់ទល់នឹងលាភសក្ការៈ**

"អ្នកផ្គត់ផ្គង់" ត្រូវប្រកាសអះអាងថាខ្លួនពុំបានផ្តល់ ឬសន្យានឹងផ្តល់ប្រាក់ចំណាយ ឬលាភសក្ការៈណាមួយចំពោះមន្ត្រីនិយោជិតរដ្ឋាភិបាលណាមួយ ឬអ្នកដេញថ្លៃណាមួយដើម្បីទទួលបានកិច្ចសន្យា ហើយសកម្មភាពទាំងនេះ គឺជាមូលដ្ឋានគ្រប់គ្រាន់សម្រាប់ផ្អាក ឬលុបកិច្ចសន្យា ។

**១៧- ការដោះស្រាយវិវាទ**

កិច្ចសន្យានេះត្រូវគ្រប់គ្រង និងត្រូវបកស្រាយតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។ ជម្លោះណាមួយដែលកើតឡើងរវាងភាគី "អ្នកទិញ" និងភាគី "អ្នកផ្គត់ផ្គង់" អំពីលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យា ឬទាក់ទិននឹងការអនុវត្តកិច្ចសន្យា ត្រូវដោះស្រាយតាមការសម្របសម្រួលជាមុនរវាងភាគីទាំងពីរ ។ ប្រសិនបើបរាជ័យនោះ ភាគីទាំងពីរត្រូវយល់ព្រមដោះស្រាយតាមរយៈមេធាវី ដោយភាគី "អ្នកទិញ" និងភាគី "អ្នកផ្គត់ផ្គង់" មានសិទ្ធិជ្រើសតាំងមេធាវីម្នាក់មួយ ហើយអាជ្ញាកណ្តាលមួយរូបនឹងត្រូវតែងតាំងដោយមានការយល់ព្រមរវាងភាគីទាំងពីរ ។ ប្រសិនបើភាគីទាំងពីរមិនយល់ស្របគ្នាលើការតែងតាំង ឬមិនឯកភាពតាមការសម្រេចរបស់អាជ្ញាកណ្តាលនោះ ត្រូវដោះស្រាយតាមផ្លូវតុលាការនៃព្រះរាជាណាចក្រកម្ពុជា ។

**១៨- សោហ៊ុយចាក់ចងរឿងក្តី**

ក្នុងករណីមានរឿងក្តីក្តាំកើតឡើង ដែលបណ្តាលមកពីភាគី "អ្នកផ្គត់ផ្គង់" រំលោភលើលក្ខខណ្ឌនានានៃកិច្ចសន្យាភាគី "អ្នកផ្គត់ផ្គង់" ត្រូវទទួលខុសត្រូវចំពោះភាគី "អ្នកទិញ" រាល់ការចំណាយក្នុងការជួលមេធាវី ។ ការចំណាយលើការខូចខាត និងចំណាយដទៃទៀតក្នុងរឿងក្តីនោះ ត្រូវកំណត់ដោយច្បាប់ ។

**១៩- ការប្រើប្រាស់ឯកសារកិច្ចសន្យា**

ប្រសិនបើគ្មានការយល់ព្រមពីភាគី "អ្នកទិញ" នោះភាគី "អ្នកផ្គត់ផ្គង់" មិនត្រូវប្រើប្រាស់ឯកសារកិច្ចសន្យា ឬមិនត្រូវបង្ហាញ ឬផ្តល់ព័ត៌មានដែលមាននៅក្នុងឯកសារកិច្ចសន្យាឱ្យអ្នកដទៃដឹងឡើយ លើកលែងតែប្រើប្រាស់ក្នុងបំណងអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាមកិច្ចសន្យា ។

ធ្វើនៅ................ ថ្ងៃទី ........ ខែ ........ ឆ្នាំ ..........

**ប្រធានអង្គភាពលទ្ធកម្ម**

បានឃើញ និង ឯកភាព

................. ថ្ងៃទី............ខែ.............ឆ្នាំ .............

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ទិដ្ឋាការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

លេខ: .................................................. សហវ.លសា

រាជធានីភ្នំពេញ ថ្ងៃទី .............. ខែ ............... ឆ្នាំ............

**បានឃើញ និងឯកភាព**

**រដ្ឋមន្ត្រី**

*(ចំពោះកិច្ចលទ្ធកម្មដែលត្រូវពិនិត្យ និងសម្រេចដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)*

# គំរូ កាតាឡូក

ឧបសម្ព័ន្ធទី១

# ពាក្យសុំដេញថ្លៃ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ .................................................... ភេទ ........................ សញ្ជាតិ ..................
ថ្ងៃ ខែ ឆ្នាំកំណើត ........................................ ទីកន្លែងកំណើត ..............................................................
មុខងារ............................................ តំណាងក្រុមហ៊ុន/សហគ្រាស.................... ដែលមានអាសយដ្ឋាន ......
.................... ទូរស័ព្ទ ................. ទូរសារ/អ៊ីមែល ........................... គេហទំព័រ ...................... ។

**សូមគោរពជូន**

**ឯកឧត្តម/លោកជំទាវ/លោក/លោកស្រី ប្រធានគណៈកម្មាធិការលទ្ធកម្ម.........**

**កម្មវត្ថុ** ៖ សំណើសុំចូលរួមដេញថ្លៃការផ្គត់ផ្គង់............

**យោង** ៖ សេចក្តីជូនដំណឹងស្តីពីការអញ្ជើញចូលរួមដេញថ្លៃការផ្គត់ផ្គង់............

សេចក្តីដូចមានក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមជម្រាបជូន ឯកឧត្តម/លោកជំទាវ/លោក/លោកស្រី ប្រធានគណៈកម្មាធិការលទ្ធកម្ម......... ជ្រាបថា ខ្ញុំបាទ/នាងខ្ញុំមានបំណងចូលរួមដេញថ្លៃការផ្គត់ផ្គង់.......... ដោយដាក់តម្លៃដេញថ្លៃសរុបចំនួន......................... (សរសេរជាអក្សរ ...............................) ។ ចំនួនទឹកប្រាក់នេះ មានបញ្ជាក់លម្អិតក្នុងបញ្ជីប៉ាន់តម្លៃ ដែលបានភ្ជាប់មកជាមួយ ។

សំណើដេញថ្លៃរបស់ខ្ញុំបាទ/នាងខ្ញុំមានសុពលភាព រយៈពេល.....(*បំពេញចំនួន*).....ថ្ងៃ បន្ទាប់ពីថ្ងៃបើកសំណើដេញថ្លៃ ។

ប្រសិនបើសំណើដេញថ្លៃរបស់ខ្ញុំបាទ/នាងខ្ញុំបានទទួលជោគជ័យនោះ ខ្ញុំបាទ/នាងខ្ញុំនឹងបំពេញតាមគ្រប់នីតិវិធីដែលបានកំណត់ ព្រមទាំងគោរពឱ្យបានពេញលេញនូវលក្ខខណ្ឌដែលមានចែងនៅក្នុងកិច្ចសន្យា ។

សូមឯកឧត្តម/លោកជំទាវ/លោក/លោកស្រី ទទួលនូវក្តីគោរពអំពីខ្ញុំបាទ/នាងខ្ញុំ ។

ធ្វើនៅ................. ថ្ងៃទី...........ខែ............ឆ្នាំ ............

**ហត្ថលេខាអ្នកដេញថ្លៃ**

*គំរូឯកសារដេញថ្លៃ ពិគ្រោះថ្លៃ ស្ទង់តម្លៃ (ដេញថ្លៃ ទំនិញ) ទំព័រ 17/241*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## សេចក្តីប្រកាស
## ស្តីពីក្រមសីលធម៌លទ្ធកម្មរបស់អ្នកដេញថ្លៃ

ខ្ញុំបាទ/នាងខ្ញុំជាប្រធានក្រុមហ៊ុន/សហគ្រាស........... សូមធ្វើការអះអាងក្នុងការរៀបចំសំណើដេញថ្លៃលើការផ្គត់ផ្គង់......... ដូចខាងក្រោម ៖

១- មិនមាននិយោជិត សហការី ភ្នាក់ងារ ម្ចាស់ភាគហ៊ុន ទីប្រឹក្សា ដៃគូ ឬញាតិសន្តានរបស់ខ្ញុំបាទ/នាងខ្ញុំ មានទំនាក់ទំនងណាមួយដែលអាចចាត់ទុកថាជាទំនាស់ផលប្រយោជន៍ ពាក់ព័ន្ធនឹងការដេញថ្លៃនេះទេ។

២- ប្រសិនបើខ្ញុំបាទ/នាងខ្ញុំដឹងពីលទ្ធភាពដែលអាចកើតមាននូវទំនាស់ផលប្រយោជន៍នេះ ខ្ញុំបាទ/នាងខ្ញុំនឹងរាយការណ៍ជាបន្ទាន់ជូនស្ថាប័នអនុវត្តលទ្ធកម្ម ។

៣- មិនមានការប្រព្រឹត្តអំពើពុករលួយ ក្លែងបន្លំ ឃុបឃិត ឬបង្ខិតបង្ខំ ទាក់ទិននឹងការដាក់សំណើដេញថ្លៃរបស់ក្រុមហ៊ុន/សហគ្រាសរបស់ខ្ញុំបាទ/នាងខ្ញុំ ។

៤- ខ្ញុំបាទ/នាងខ្ញុំយល់ច្បាស់ពីកាតព្វកិច្ចរបស់ខ្លួន ក្នុងការអនុញ្ញាតឱ្យស្ថាប័នមានសមត្ថកិច្ចនៃរាជរដ្ឋាភិបាល ឬដៃគូអភិវឌ្ឍន៍ ធ្វើអធិការកិច្ចលើរាល់លិខិតស្នាមទាំងអស់ទាក់ទងនឹងការដាក់សំណើដេញថ្លៃរបស់ក្រុមហ៊ុន/សហគ្រាសរបស់ខ្ញុំបាទ/នាងខ្ញុំនិងកិច្ចសន្យាណាមួយ ដែលជាលទ្ធផលនៃការដាក់ដេញថ្លៃនេះ ដោយមិនគិតថាក្រុមហ៊ុន/សហគ្រាសរបស់ខ្ញុំបាទ/នាងខ្ញុំបាន ឬមិនបានទទួលការសម្រេចប្រគល់កិច្ចសន្យានោះទេ ។

៥- គ្មានការទូទាត់ណាមួយ ទាក់ទងនឹងដំណើរការលទ្ធកម្មនេះ ត្រូវបានធ្វើឡើងដោយខ្ញុំបាទ/នាងខ្ញុំ សហការី ភ្នាក់ងារ ម្ចាស់ភាគហ៊ុន ទីប្រឹក្សា ដៃគូរបស់ខ្ញុំបាទ/នាងខ្ញុំ ឬញាតិសន្តានរបស់ពួកគេ ទៅឱ្យភ្នាក់ងារ ទីប្រឹក្សា និយោជិត ឬញាតិសន្តានរបស់ពួកគេ ដែលចូលរួមក្នុងដំណើរការលទ្ធកម្មនេះ ជំនួសមុខឱ្យស្ថាប័នអនុវត្តលទ្ធកម្ម អតិថិជន ឬនិយោជកនោះទេ ។

ធ្វើនៅ ................. ថ្ងៃទី ............. ខែ ............. ឆ្នាំ ..............

ហត្ថលេខា

ឈ្មោះ.....................

ឧបសម្ព័ន្ធទី២

# តារាងតម្លៃ និងបញ្ជាក់លក្ខណៈបច្ចេកទេស

| **ល.រ** | **រាយមុខទំនិញ និងបញ្ជាក់លក្ខណៈបច្ចេកទេស** | **ឯកតា** | **បរិមាណ** | **តម្លៃឯកតា** (រៀល) | **តម្លៃសរុប** (រៀល) | **ប្រភព** |
|---|---|---|---|---|---|---|
| ១ | ក្រដាសរ៉ាម A4 (២១សមx២៤សម) | រ៉ាម | ៥០ | ........... | ........... | ........... |
| ២ | សៀវភៅសរសេរ ១០០ទំព័រ (២១សមx២៤សម) | ក្បាល | ១០០ | ........... | ........... | ........... |
| ៣ | ប៊ិចពណ៌ខៀវ ............ | ដើម | ១៥០ | ........... | ........... | ........... |
| ៤ | .................... | ........... | ........... | ........... | ........... | ........... |
| | **សរុប** | | | | ........... | |

បញ្ឈប់ទឹកប្រាក់ត្រឹមចំនួន ៖ ...................................................... រៀល

សរសេរជាអក្សរ ៖ ........................................................................................................................ ។

ធ្វើនៅ................. ថ្ងៃទី............ខែ.............ឆ្នាំ .............

**ហត្ថលេខាអ្នកដេញថ្លៃ**

ឧបសម្ព័ន្ធទី ៣

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ** .............

## លិខិតធានា
## ប្រាក់កក់ធានាការដេញថ្លៃ

**សូមគោរពជូន**
**ឯកឧត្តម/លោកជំទាវ/លោក/លោកស្រី ប្រធានគណៈកម្មាធិការលទ្ធកម្ម......**

ដោយហេតុថាក្រុមហ៊ុន/សហគ្រាស ......................................... មានបំណងដាក់សំណើដេញថ្លៃដើម្បីធ្វើការផ្គត់ផ្គង់...................... ដែលត្រូវបើកសំណើដេញថ្លៃនៅថ្ងៃទី......... ខែ........ឆ្នាំ...................។

អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ.......... សូមធានាចំពោះមុខគណៈកម្មាធិការលទ្ធកម្ម...................... នូវប្រាក់កក់ធានាការដេញថ្លៃចំនួន ...................................... (សរសេរជាអក្សរ....................................)។

ក្នុងករណីមានលក្ខខណ្ឌណាមួយកើតមានឡើងក្នុងចំណោមលក្ខខណ្ឌទាំងបីខាងក្រោម ៖

១-ប្រសិនបើអ្នកដេញថ្លៃ ដកសំណើដេញថ្លៃរបស់ខ្លួន ក្នុងរយៈពេលសុពលភាពនៃសំណើដេញថ្លៃ
២-ប្រសិនបើអ្នកដេញថ្លៃ បដិសេធការចុះហត្ថលេខាលើកិច្ចសន្យា ក្នុងរយៈពេលសុពលភាពនៃសំណើដេញថ្លៃ
៣-ប្រសិនបើអ្នកដេញថ្លៃ មិនព្រមកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា ។

នោះអគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ.......... នឹងធ្វើការបង្វែរចូលថវិការដ្ឋនូវចំនួនប្រាក់កក់ខាងលើ នៅពេលដែលបានទទួលលិខិតស្នើសុំពីគណៈកម្មាធិការលទ្ធកម្ម ដែលបញ្ជាក់ថាអ្នកដេញថ្លៃមិនគោរពតាមលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌទាំងបីខាងលើ ។

លិខិតធានាប្រាក់កក់ធានាការដេញថ្លៃនេះមានសុពលភាព រយៈពេលយ៉ាងតិចសាមសិប(៣០)ថ្ងៃ ក្រោយសុពលភាពសំណើដេញថ្លៃ ។

................ ថ្ងៃទី............ ខែ ............ ឆ្នាំ............
**អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ........**

*គំរូឯកសារដេញថ្លៃ ពិគ្រោះថ្លៃ ស្នងតម្លៃ (*[illegible]

ឧបសម្ព័ន្ធទី ៤

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ** .............

# លិខិតធានា

# ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា

**សូមគោរពជូន**

**ឯកឧត្តម/លោកជំទាវ/លោក/លោកស្រី ប្រធានគណៈកម្មាធិការលទ្ធកម្ម**...............

ដោយហេតុថាក្រុមហ៊ុន/សហគ្រាស........................................................ បានទទួលលិខិតស្តីពីការចុះកិច្ចសន្យាការផ្គត់ផ្គង់....................... លេខ ............. ចុះថ្ងៃទី........ ខែ ........... ឆ្នាំ............. ដែលមានតម្លៃកិច្ចសន្យាចំនួន............................ (សរសេរជាអក្សរ..............................................)។

ដោយមានចែងនៅក្នុងលិខិតស្តីពីការចុះកិច្ចសន្យាថា "អ្នកផ្គត់ផ្គង់" ត្រូវផ្តល់លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ចេញដោយអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគារ............. ដែលមានតម្លៃទឹកប្រាក់ស្មើនឹងដប់(១០%)ភាគរយ នៃតម្លៃកិច្ចសន្យាសរុប ដើម្បីធានាការអនុវត្តកាតព្វកិច្ចស្របតាមលក្ខខណ្ឌកិច្ចសន្យា ។

អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ............. សូមធានា និងទទួលខុសត្រូវ នូវប្រាក់កក់ចំនួន.................. (សរសេរជាអក្សរ ..............................................)។

ប្រាក់កក់ខាងលើនេះ នឹងត្រូវបង្វែរចូលថវិការដ្ឋ នៅពេលបានទទួលលិខិតស្នើសុំពី "អ្នកទិញ" ដែលបញ្ជាក់ថា "អ្នកផ្គត់ផ្គង់" មិនគោរពតាមលក្ខខណ្ឌនៃកិច្ចសន្យា ហើយក្រុមហ៊ុន/សហគ្រាស .............................. គ្មានសិទ្ធិប្រកែកឬតវ៉ាឡើយ ។

លិខិតធានានេះមានសុពលភាពរហូតដល់ ក្រោយថ្ងៃប្រគល់ ទទួលទំនិញគ្រប់ចំនួន ឬក្រោយរយៈពេលធានាគុណភាពទំនិញ ។

............... ថ្ងៃទី ............ ខែ........... ឆ្នាំ...........

**អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ**............

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង/ស្ថាប័ន/រាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ....**

**បញ្ជីឈ្មោះអ្នកទិញឯកសារដេញថ្លៃ**
**ស្តីពីការផ្គត់ផ្គង់...................**

| ល.រ | ឈ្មោះក្រុមហ៊ុន/សហគ្រាស | ឈ្មោះអ្នកតំណាង | ភេទ | លេខទូរស័ព្ទ | កាលបរិច្ឆេទ<br>ម៉ោង.....ថ្ងៃទី.....ខែ.....ឆ្នាំ...... | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |
| ...... | | | | | | |
| | | | | | | |

................. ,ថ្ងៃទី............ខែ.............ឆ្នាំ .............

**ប្រធានអង្គភាពលទ្ធកម្ម**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង/ស្ថាប័ន/រាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ....**

## បញ្ជីឈ្មោះអ្នកដាក់សំណើដេញថ្លៃ
## ស្តីពីការផ្គត់ផ្គង់...................

| ល.រ | ឈ្មោះក្រុមហ៊ុន/សហគ្រាស | ឈ្មោះអ្នកតំណាង | ភេទ | លេខទូរស័ព្ទ | កាលបរិច្ឆេទ<br>ម៉ោង....ថ្ងៃទី....ខែ....ឆ្នាំ...... | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |
| ...... | | | | | | |
| | | | | | | |

................. ថ្ងៃទី............ខែ.............ឆ្នាំ .............

**ប្រធានអង្គភាពលទ្ធកម្ម**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង/ស្ថាប័ន/រាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ....**

**បញ្ជីវត្តមាន**
**អ្នកចូលរួមបើកសំណើដេញថ្លៃ**
**ស្តីពីការផ្គត់ផ្គង់..................**

ថ្ងៃទី ........... ខែ ................ ឆ្នាំ ...................

| ល.រ | នាម និងគោត្តនាម | ភេទ | មុខងារ | ស្ថាប័ន/អង្គភាព | ហត្ថលេខា | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |
| ...... | | | | | | |
| | | | | | | |

................ ថ្ងៃទី...........ខែ.............ឆ្នាំ .............

**ប្រធានអង្គប្រជុំ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង/ស្ថាប័ន/រាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ....**

## កំណត់ហេតុបើកសំណើដេញថ្លៃ
## ស្តីពីការផ្គត់ផ្គង់...................

ឆ្នាំពីរពាន់.......... ខែ.......... ថ្ងៃទី........... វេលាម៉ោង................ នៅ.................. មានកិច្ចប្រជុំបើកសំណើដេញថ្លៃស្តីពីការផ្គត់ផ្គង់.................. ក្រោមអធិបតីភាព....................... ។

-ប្រភេទលទ្ធកម្ម ..................................

-វិធីសាស្ត្រលទ្ធកម្ម ................................

-ប្រភពឥណទាន ..................... ក្នុងផែនការឆ្នាំ ............. ជំពូក .......... គណនី .................. អនុគណនី .............

-កាលបរិច្ឆេទលក់ឯកសារដេញថ្លៃ : ចាប់ពីថ្ងៃទី.........ខែ........ឆ្នាំ ....... ដល់ថ្ងៃទី...........ខែ............ឆ្នាំ .........

-កាលបរិច្ឆេទទទួលសំណើដេញថ្លៃ: ចាប់ពីថ្ងៃទី...........ខែ............ឆ្នាំ ............ រៀងរាល់ម៉ោងធ្វើការ

-កាលបរិច្ឆេទឈប់ទទួល និងបើកសំណើដេញថ្លៃ: ថ្ងៃទី...........ខែ............ឆ្នាំ ............ វេលាម៉ោង................

-អត្រាប្តូរប្រាក់ ១ដុល្លារ=.................រៀល នៅថ្ងៃទី...........ខែ............ឆ្នាំ ............

១-ការលក់ឯកសារដេញថ្លៃ:

| ល.រ | ឈ្មោះក្រុមហ៊ុន/សហគ្រាស | ឈ្មោះអ្នកតំណាង | ភេទ | កាលបរិច្ឆេទ<br>ម៉ោង....ថ្ងៃទី....ខែ....ឆ្នាំ...... | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ...... | | | | | |

២-ការទទួលសំណើដេញថ្លៃ:

| ល.រ | ឈ្មោះក្រុមហ៊ុន/សហគ្រាស | ឈ្មោះអ្នកតំណាង | ភេទ | កាលបរិច្ឆេទ<br>ម៉ោង....ថ្ងៃទី....ខែ....ឆ្នាំ...... | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ...... | | | | | |

៣-ការបើកសំណើដេញថ្លៃ:

| ល.រ | ឈ្មោះក្រុមហ៊ុន/សហគ្រាស | ប្រាក់កក់ធានាការដេញថ្លៃ | តម្លៃដាក់ដេញថ្លៃសរុប | | សេចក្ដីផ្សេងៗ |
|---|---|---|---|---|---|
| | | | ប្រាក់រៀល | ប្រាក់ដុល្លារ | |
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ...... | | | | | |

៤-ការតវ៉ា ឬបាតុភាពក្នុងពេលបើកសំណើដេញថ្លៃ:

| ល.រ | ឈ្មោះក្រុមហ៊ុន/សហគ្រាស | ប្រភេទនៃការតវ៉ា |
|---|---|---|
| ១ | | |
| ២ | | |
| ៣ | | |
| ...... | | |

៥-តំណាងផ្លូវការរបស់អ្នកដេញថ្លៃចូលរួមបើកសំណើដេញថ្លៃ:

| ល.រ | ឈ្មោះក្រុមហ៊ុន/សហគ្រាស | ឈ្មោះអ្នកតំណាង | ហត្ថលេខា | សេចក្ដីផ្សេងៗ |
|---|---|---|---|---|
| ១ | | | | |
| ២ | | | | |
| ៣ | | | | |
| ...... | | | | |

៦-សមាសភាពគណៈកម្មាធិការលទ្ធកម្មចូលរួមបើកសំណើដេញថ្លៃ:

| ល.រ | នាម និងគោត្តនាម | មុខងារ | ហត្ថលេខា | សេចក្ដីផ្សេងៗ |
|---|---|---|---|---|
| ១ | | | | |
| ២ | | | | |
| ៣ | | | | |
| ...... | | | | |

កិច្ចប្រជុំបើកសំណើដេញថ្លៃត្រូវបានបញ្ចប់ នៅថ្ងៃទី............ខែ.............ឆ្នាំ ............ វេលាម៉ោង............

ធ្វើនៅ................ ថ្ងៃទី ........ ខែ ........ឆ្នាំ........

**ប្រធានអង្គភាពលទ្ធកម្ម**

បានឃើញ និង ឯកភាព

.............. ថ្ងៃទី ............ ខែ.........ឆ្នាំ ..................

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## សេចក្តីប្រកាស
## ស្តីពីក្រមសីលធម៌លទ្ធកម្មរបស់គណៈកម្មាធិការលទ្ធកម្ម

យើងខ្ញុំសូមធ្វើការអះអាងថា ៖

១- ក្នុងអំឡុងពេលដំណើរការលទ្ធកម្ម និងការវាយតម្លៃសំណើដេញថ្លៃ យើងខ្ញុំប្រកាន់ខ្ជាប់នូវក្រមសីលធម៌លទ្ធកម្មដូចមានបញ្ជាក់នៅក្នុងសៀវភៅលទ្ធកម្ម ស្តីពីការអនុវត្តវិធាននិងបទប្បញ្ញត្តិ ស្តីពីលទ្ធកម្មសាធារណៈ ។

២- នៅក្នុងការអនុវត្តតួនាទីរបស់យើងខ្ញុំ យើងខ្ញុំពុំទទួលនូវផលប្រយោជន៍ ទោះជារូបិយវត្ថុ ឬជាសម្ភារៈ ពីសំណាក់ស្ថាប័នខាងក្រៅ អ្នកដេញថ្លៃ ឬទីប្រឹក្សាណាមួយនោះទេ ក្រៅអំពីប្រាក់បៀវត្សផ្លូវការដែលយើងខ្ញុំបានទទួលក្នុងឋានៈជាមន្ត្រីរាជការ ។

៣- តាមដែលយើងខ្ញុំបានដឹង គ្មានសហសេវិក សហការី ឬញាតិសន្តាន បានទទួលនូវផលប្រយោជន៍ ទោះជារូបិយវត្ថុ ឬជាសម្ភារៈពីសំណាក់ស្ថាប័នខាងក្រៅ អ្នកដេញថ្លៃ ឬទីប្រឹក្សាណាមួយនោះទេក្រៅអំពីប្រាក់បៀវត្សផ្លូវការ ។

៤- យើងខ្ញុំមិនបានដឹងអំពីការអនុវត្តដែលកេងបន្លំ ពុករលួយ ឃុបឃិត ឬបង្ខិតបង្ខំនានា ដែលបានកើតឡើង នៅក្នុងដំណើរការលទ្ធកម្មនោះទេ ហើយយល់យ៉ាងច្បាស់ថា យើងខ្ញុំមានកាតព្វកិច្ចខាងសីលធម៌ក្នុងការរាយការណ៍អំពីការអនុវត្តបែបនេះ ប្រសិនបើយើងខ្ញុំបានដឹង ។

៥- គ្មានទំនាស់ផលប្រយោជន៍ណាមួយកើតឡើង ទោះជាចំពោះយើងខ្ញុំ ឬចំពោះអ្នកដេញថ្លៃ ឬទីប្រឹក្សាដែលត្រូវបានសម្រេចប្រគល់កិច្ចសន្យាឱ្យ ឬចំពោះសហសេវិក សហការី និងញាតិសន្តាននោះទេ ។

ធ្វើនៅ ................ ថ្ងៃទី ............ ខែ ........... ឆ្នាំ ............

-ឈ្មោះ...................... (ហត្ថលេខា)

-ឈ្មោះ ...................... (ហត្ថលេខា)

-ឈ្មោះ...................... (ហត្ថលេខា)

-ឈ្មោះ ...................... (ហត្ថលេខា)

.........................

*ឝ គំរូឯកសារដេញថ្លៃ ពិគ្រោះថ្លៃ ស្ទង់តម្លៃ (ដេញថ្លៃ ទំនិញ) ទំព័រ 27/241*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង/ស្ថាប័ន/រាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ....**

**កំណត់ហេតុ**
**ស្តីពី**
**ការវាយតម្លៃប្រគល់កិច្ចសន្យា**

ឆ្នាំពីរពាន់......... ខែ......... ថ្ងៃទី.......... វេលាម៉ោង............... នៅ................. មានកិច្ចប្រជុំវាយតម្លៃប្រគល់កិច្ចសន្យាស្តីពីការផ្គត់ផ្គង់................. ក្រោមអធិបតីភាព...................... ។

-ប្រភេទលទ្ធកម្ម .................................

-វិធីសាស្ត្រលទ្ធកម្ម .................................

-ប្រភពឥណទាន .................... ក្នុងផែនការឆ្នាំ ............. ជំពូក ......... គណនី ................. អនុគណនី ............

-កាលបរិច្ឆេទលក់ឯកសារដេញថ្លៃ : ចាប់ពីថ្ងៃទី.........ខែ........ឆ្នាំ ....... ដល់ថ្ងៃទី............ខែ............ឆ្នាំ .........

-កាលបរិច្ឆេទទទួលសំណើដេញថ្លៃ: ចាប់ពីថ្ងៃទី...........ខែ............ឆ្នាំ ............ រៀងរាល់ម៉ោងធ្វើការ

-កាលបរិច្ឆេទឈប់ទទួល និងបើកសំណើដេញថ្លៃ: ថ្ងៃទី...........ខែ............ឆ្នាំ ............ វេលាម៉ោង................

-អត្រាប្តូរប្រាក់ ១ដុល្លារ=................រៀល នៅថ្ងៃទី...........ខែ............ឆ្នាំ ............

១-ឈ្មោះក្រុមហ៊ុន/សហគ្រាសដែលបានដាក់សំណើដេញថ្លៃ:

| ល.រ | ឈ្មោះក្រុមហ៊ុន/សហគ្រាស | កាលបរិច្ឆេទ ទិញឯកសារដេញថ្លៃ | កាលបរិច្ឆេទ ដាក់សំណើដេញថ្លៃ | ផ្សេងៗ |
|---|---|---|---|---|
| ១ | | | | |
| ២ | | | | |
| ៣ | | | | |
| ...... | | | | |

**២-តារាងតម្លៃសំណើដេញថ្លៃ:**

| ល.រ | ឈ្មោះក្រុមហ៊ុន/ សហគ្រាស | ប្រាក់កក់ ធានាការដេញថ្លៃ | តម្លៃដាក់ដេញថ្លៃសរុប | | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|
| | | | ប្រាក់រៀល | ប្រាក់ដុល្លារ | |
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ...... | | | | | |

៣- តារាងបង្ហាញភាពឆ្លើយតបតាមការណែនាំ នៃឯកសារដេញថ្លៃ (ការវាយតម្លៃបឋម):

| **សេចក្តីណែនាំអំពីលក្ខខណ្ឌ** | ក្រុមហ៊ុន/សហគ្រាស... | ក្រុមហ៊ុន/សហគ្រាស... | ក្រុមហ៊ុន/សហគ្រាស... |
|---|---|---|---|
| ១-ការបិទភ្ជិត និងកាខ្ទងលើស្រោមសំបុត្រ | ត្រឹមត្រូវ/មិនត្រឹមត្រូវ | ត្រឹមត្រូវ/មិនត្រឹមត្រូវ | ត្រឹមត្រូវ/មិនត្រឹមត្រូវ |
| ២-ភាសានៃសំណើដេញថ្លៃ | ខ្មែរ | ខ្មែរ | ខ្មែរ |
| ៣-ចំនួនច្បាប់នៃសំណើដេញថ្លៃ | ០៣ច្បាប់ | ០៣ច្បាប់ | ០៣ច្បាប់ |
| ៤-ពាក្យសុំដេញថ្លៃ | ត្រឹមត្រូវ/មិនត្រឹមត្រូវ | ត្រឹមត្រូវ/មិនត្រឹមត្រូវ | ត្រឹមត្រូវ/មិនត្រឹមត្រូវ |
| ៥-តម្រូ និងការចុះហត្ថលេខាលើសំណើដេញថ្លៃ | ត្រឹមត្រូវ/មិនត្រឹមត្រូវ | ត្រឹមត្រូវ/មិនត្រឹមត្រូវ | ត្រឹមត្រូវ/មិនត្រឹមត្រូវ |
| ៦-តារាងតម្លៃ និងបញ្ជាក់លក្ខណៈបច្ចេកទេស | គ្រប់គ្រាន់/មិនគ្រប់គ្រាន់ | គ្រប់គ្រាន់/មិនគ្រប់គ្រាន់ | គ្រប់គ្រាន់/មិនគ្រប់គ្រាន់ |
| ៧-ឯកសារភ្ជាប់សំណើដេញថ្លៃ ៖ | | | |
| *-អត្តសញ្ញាណប័ណ្ណ (ចម្លងត្រឹមត្រូវតាមច្បាប់ដើម)* | ត្រឹមត្រូវ/មិនត្រឹមត្រូវ | ត្រឹមត្រូវ/មិនត្រឹមត្រូវ | ត្រឹមត្រូវ/មិនត្រឹមត្រូវ |
| *-ប័ណ្ណប៉ាតង់ឆ្នាំដេញថ្លៃ (ចម្លងត្រឹមត្រូវតាមច្បាប់ដើម)* | ត្រឹមត្រូវ/មិនត្រឹមត្រូវ | ត្រឹមត្រូវ/មិនត្រឹមត្រូវ | ត្រឹមត្រូវ/មិនត្រឹមត្រូវ |
| *-វិញ្ញាបនប័ត្រចុះបញ្ជីអាករលើតម្លៃបន្ថែម អ.ត.ប (ចម្លងត្រឹមត្រូវតាមច្បាប់ដើម)* | ត្រឹមត្រូវ/មិនត្រឹមត្រូវ | ត្រឹមត្រូវ/មិនត្រឹមត្រូវ | ត្រឹមត្រូវ/មិនត្រឹមត្រូវ |
| *-វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម (ចម្លងត្រឹមត្រូវតាមច្បាប់ដើម)* | ត្រឹមត្រូវ/មិនត្រឹមត្រូវ | ត្រឹមត្រូវ/មិនត្រឹមត្រូវ | ត្រឹមត្រូវ/មិនត្រឹមត្រូវ |
| *-ច្បាប់អនុញ្ញាតឱ្យធ្វើអាជីវកម្ម ចេញដោយក្រសួងជំនាញពាក់ព័ន្ធ (ចម្លងត្រឹមត្រូវតាមច្បាប់ដើម)* | ត្រឹមត្រូវ/មិនត្រឹមត្រូវ | ត្រឹមត្រូវ/មិនត្រឹមត្រូវ | ត្រឹមត្រូវ/មិនត្រឹមត្រូវ |
| *-វិញ្ញាបនប័ត្រចុះបញ្ជីអ្នកផ្គត់ផ្គង់ទំនិញ ចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(ចម្លងត្រឹមត្រូវតាមច្បាប់ដើម)* | ត្រឹមត្រូវ/មិនត្រឹមត្រូវ | ត្រឹមត្រូវ/មិនត្រឹមត្រូវ | ត្រឹមត្រូវ/មិនត្រឹមត្រូវ |
| *-ប៉ាន់គំរូ ឬកាតាឡុកច្បាប់ដើម* | ត្រឹមត្រូវ/មិនត្រឹមត្រូវ | ត្រឹមត្រូវ/មិនត្រឹមត្រូវ | ត្រឹមត្រូវ/មិនត្រឹមត្រូវ |
| ៨-ប្រាក់កក់ធានាការដេញថ្លៃ ៖ | | | |
| *ក-ចំនួន* | .......រៀល/ដុល្លារ | .......រៀល/ដុល្លារ | .......រៀល/ដុល្លារ |
| *ខ-រយៈពេលសុពលភាព* | .....ថ្ងៃ | .....ថ្ងៃ | .....ថ្ងៃ |
| ៩-រយៈពេលសុពលភាពនៃសំណើដេញថ្លៃ | .....ថ្ងៃ | .....ថ្ងៃ | .....ថ្ងៃ |
| ១០-តម្រូវការក្រុមហ៊ុនរកស៊ីចូលគ្នា | មាន/គ្មាន | មាន/គ្មាន | មាន/គ្មាន |
| ១១-តម្រូវការផ្សេងទៀត (ប្រសិនបើមាន) | ......... | ......... | [illegible] |
| ភាពឆ្លើយតបនៃសំណើដេញថ្លៃ | ពេញលេញ | ឆ្លើយតបច្រើន | ឆ្លើយតបតិច |

៤-តារាងឈ្មោះក្រុមហ៊ុន/សហគ្រាសដែលមិនបានយកមកវាយតម្លៃ :

| ល.រ | ឈ្មោះក្រុមហ៊ុន/សហគ្រាស | មូលហេតុដែលមិនបានយកមកវាយតម្លៃ |
|---|---|---|
| ១ | ..... | ....... |
| ២ | ..... | |
| ៣ | | |
| ...... | | |

៥-តារាងកែតម្រូវលេខនព្វន្ត :

| ល.រ | ឈ្មោះក្រុមហ៊ុន/សហគ្រាស | តម្លៃដាក់ដេញថ្លៃ | តម្លៃកែតម្រូវលេខនព្វន្តរួច | ផ្ទេរជាប្រាក់រៀល |
|---|---|---|---|---|
| ១ | | | | |
| ២ | | | | |
| ៣ | | | | |
| ...... | | | | |

៦-ឈ្មោះក្រុមហ៊ុន/សហគ្រាស ដែលបានដាក់សំណើដេញថ្លៃសមស្រប និងត្រូវបានយកមកវាយតម្លៃ (រៀបតាមលំដាប់តម្លៃដាក់ដេញថ្លៃ ពីទាបទៅខ្ពស់) :

| ល.រ | ឈ្មោះក្រុមហ៊ុន/សហគ្រាស | តម្លៃដាក់ដេញថ្លៃ | ផ្សេងៗ |
|---|---|---|---|
| ១ | | | |
| ២ | | | |
| ៣ | | | |
| ...... | | | |

៧-តារាងបង្ហាញពីភាពឆ្លើយតបតាមតម្រូវការបច្ចេកទេស/លក្ខខណ្ឌពាណិជ្ជកម្ម :

| តម្រូវការបច្ចេកទេស/ ពាណិជ្ជកម្ម | ក្រុមហ៊ុន/ សហគ្រាស... | ក្រុមហ៊ុន/ សហគ្រាស... | ក្រុមហ៊ុន/ សហគ្រាស... | ក្រុមហ៊ុន/ សហគ្រាស... |
|---|---|---|---|---|
| -ភាពឆ្លើយតបនៃសំណើដេញថ្លៃ | | | | |
| -យថាប្រភេទនៃមុខទំនិញ | | | | |
| -លក្ខណៈបច្ចេកទេស | | | | |
| -បទពិសោធន៍ | | | | |
| -រយៈពេលផ្គត់ផ្គង់ | | | | |
| -លក្ខខណ្ឌទូទាត់ | | | | |
| -លក្ខខណ្ឌផ្សេងទៀត (ប្រសិនបើមាន) | | | | |

**៨-ការប្រៀបធៀបតម្លៃសំណើដេញថ្លៃដែលបានវាយតម្លៃរួច :**

| តម្លៃជាមូលដ្ឋានសម្រាប់សម្រប សម្រួល | ក្រុមហ៊ុន/ សហគ្រាស... | ក្រុមហ៊ុន/ សហគ្រាស... | ក្រុមហ៊ុន/ សហគ្រាស... | ក្រុមហ៊ុន/ សហគ្រាស... |
|---|---|---|---|---|
| ១-តម្លៃដាក់ដេញថ្លៃបន្ទាប់ពីបានកែតម្រូវលេខនព្វន្តរួច | | | | |
| ២-សម្របសម្រួលសម្រាប់ : | | | | |
| -ពន្ធ អាករ | | | | |
| -ដឹកជញ្ជូន | | | | |
| -ការខ្វះខាតមុខទំនិញខ្លះ | | | | |
| -ភាពខុសគ្នាជាបច្ចេកទេស | | | | |
| -លក្ខខណ្ឌទូទាត់ | | | | |
| -ពេលវេលាប្រគល់ ទទួល (ការផាកពិន័យ) | | | | |
| ៣-បញ្ចុះតម្លៃ(អប្បហា) | | | | |
| ៤-តម្លៃដែលត្រូវបានវាយតម្លៃរួច | | | | |
| ៥-ចំណាត់ថ្នាក់អ្នកដេញថ្លៃនាំមុខ | លេខ | លេខ | លេខ | លេខ |

៩-ការត្រួតពិនិត្យលក្ខណសម្បត្តិតាមក្រោយ :

គណៈកម្មាធិការលទ្ធកម្ម បានធ្វើការត្រួតពិនិត្យលក្ខណសម្បត្តិតាមក្រោយរបស់អ្នកដេញថ្លៃនាំមុខទី១ (*ឬបន្តបន្ទាប់ ក្នុងករណីអ្នកដេញថ្លៃនាំមុខទី១ មិនឆ្លើយតប*) ដោយធ្វើការផ្ទៀងផ្ទាត់ឡើងវិញលើឯកសារភស្តុតាងនានា ដើម្បីធានាភាពត្រឹមត្រូវ នៃតម្រូវការផ្លូវច្បាប់ តម្រូវការសមត្ថភាព "ហិរញ្ញវត្ថុ បច្ចេកទេស បទពិសោធន៍" ជាមួយនឹងស្ថានភាពជាក់ស្តែង បង្ហាញថាអ្នកដេញថ្លៃនាំមុខទី... មានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងការអនុវត្តកិច្ចសន្យា ។

**<u>សន្និដ្ឋាន</u>**

គណៈកម្មាធិការលទ្ធកម្ម បានឯកភាពសម្រេចប្រគល់កិច្ចសន្យាជូនក្រុមហ៊ុន/សហគ្រាស ................ ក្នុងតម្លៃកិច្ចសន្យាចំនួន..................... (សរសេរជាអក្សរ.................................................. ) ដែលទាបជាងឥណទានធានាចំណាយចំនួន................................ ។

អង្គប្រជុំបានចប់សព្វគ្រប់នៅវេលាម៉ោង.........ថ្ងៃ..........ខែ.......ឆ្នាំ........... ក្រោមស្មារតីយកចិត្តទុកដាក់ និងទទួលខុសត្រូវខ្ពស់ ។

ធ្វើនៅ............... ថ្ងៃទី ....... ខែ ....... ឆ្នាំ.........

**ប្រធានអង្គភាពលទ្ធកម្ម**

សមាសភាពគណៈកម្មាធិការចូលរួម:

១-............... (ហត្ថលេខា)

២-............... (ហត្ថលេខា

៣-............... (ហត្ថលេខា)

......

បានឃើញ និង ឯកភាព

................ ថ្ងៃទី .............. ខែ..........ឆ្នាំ ..................

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង/ស្ថាប័ន/រាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ...**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ ........../............

**<u>ជម្រាបមក</u>**
**លោក/លោកស្រី ប្រធានក្រុមហ៊ុន/សហគ្រាស ...................**

**<u>កម្មវត្ថុ</u>** ៖ ការសម្រេចជ្រើសរើស និងប្រគល់កិច្ចសន្យាស្តីពីការផ្គត់ផ្គង់.............................. ។
**<u>យោង</u>** ៖ កំណត់ហេតុបើកសំណើដេញថ្លៃចុះថ្ងៃទី.......... ខែ.......... ឆ្នាំ......... និងកំណត់ហេតុវាយតម្លៃប្រគល់កិច្ចសន្យាចុះថ្ងៃទី............ ខែ........... ឆ្នាំ........ របស់គណៈកម្មាធិការលទ្ធកម្ម............។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូមលោក/លោកស្រីប្រធាន ក្រុមហ៊ុន/សហគ្រាស............ ជ្រាបថា ដោយផ្អែកលើកំណត់ហេតុវាយតម្លៃរបស់គណៈកម្មាធិការលទ្ធកម្ម........................ (ក្រសួង/ស្ថាប័ន/រាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ) សម្រេចជ្រើសរើស និងប្រគល់កិច្ចសន្យាជូនក្រុមហ៊ុន/សហគ្រាស ................ ដើម្បីធ្វើការផ្គត់ផ្គង់........................................ ក្នុងតម្លៃទឹកប្រាក់សរុបចំនួន .................................. (សរសេរជាអក្សរ ................................................) ជាតម្លៃកិច្ចសន្យា ។

សូមលោក/លោកស្រីប្រធាន មេត្តាទទួលនូវការរាប់អានអំពីខ្ញុំ ។

................ ថ្ងៃទី ............. ខែ..........ឆ្នាំ ..................
**ហត្ថលេខា**
**ប្រធានស្ថាប័ន និងជាប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ចម្លងជូន**
-..............
-..................
-..................
*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង/ស្ថាប័ន/រាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ...**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ ........../............

**ជម្រាបមក**
**លោក/លោកស្រី ប្រធានក្រុមហ៊ុន/សហគ្រាស ..................**

**កម្មវត្ថុ** ៖ ការចុះកិច្ចសន្យាស្តីពីការផ្គត់ផ្គង់.............................. ។
**យោង** ៖ លិខិតលេខ........ ចុះថ្ងៃទី.......... ខែ.......... ឆ្នាំ......... ស្តីពីសម្រេចជ្រើសរើស និងប្រគល់កិច្ចសន្យា ស្តីពីការផ្គត់ផ្គង់..............................។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូមលោក/លោកស្រីប្រធាន ក្រុមហ៊ុន/សហគ្រាស............ អញ្ជើញមកចុះកិច្ចសន្យាស្តីពីការផ្គត់ផ្គង់........................ នៅអង្គភាពលទ្ធកម្ម.................... ក្នុងរយៈពេលប្រាំពីរ (០៧)ថ្ងៃយ៉ាងយូរ បន្ទាប់ពីបានទទួលលិខិតនេះ ដោយភ្ជាប់មកជាមួយនូវលិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ចេញដោយអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគារ...... ដែលមានតម្លៃទឹកប្រាក់ស្មើនឹង ១០% នៃតម្លៃកិច្ចសន្យាសរុប ។

សូមលោក/លោកស្រីប្រធាន មេត្តាទទួលនូវការរាប់អានអំពីខ្ញុំ ។

................ ថ្ងៃទី ............. ខែ.........ឆ្នាំ .................
**ហត្ថលេខា**
**ប្រធានស្ថាប័ន និងជាប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ចម្លងជូន**
-...............
-..................
-..................
*-ឯកសារ-កាលប្បវត្តិ*

ត ទៅរាជកិច្ចលេខ ៣៤

*ត្រូវឯកសារដេញថ្លៃ ពិគ្រោះថ្លៃ សូង់តម្លៃ (ដេញថ្លៃ ទំនិញ) ទំព័រ 34/241*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ០៩១ MIH / 2014

# ប្រកាស
## ស្តីពីការបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
